ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# កម្មវិធីសកម្មភាព សម្រាប់អនុវត្ត យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ

នាថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥

# រៀបចំដោយ
# ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
# មាតិកា


ទំព័រ

**ពាក្យសរសេរកោត់**........................................ ២

**សេចក្តីផ្តើម**........................................ ៤

**បញ្ហាប្រឈមមុខដែលត្រូវដោះស្រាយជាបន្ទាន់**........................................ ៨

**កម្មវិធីសកម្មភាពរយៈពេលខ្លី**

-សកម្មភាពអាទិភាពរយៈពេលខ្លី........................................ ១០

-តារាងសង្ខេបអាទិភាពរយៈពេលខ្លី........................................ ១៣

-ផែនការអនុវត្តរយៈពេលខ្លី........................................ ១៤

-តារាងកម្មវិធីសកម្មភាពរយៈពេលខ្លី........................................ ១៧

**កម្មវិធីសកម្មភាពរយៈពេលមធ្យម**

-សកម្មភាពអាទិភាពរយៈពេលមធ្យម........................................ ៣៩

-តារាងសង្ខេបអាទិភាពរយៈពេលមធ្យម........................................ ៤១

-ផែនការអនុវត្តរយៈពេលមធ្យម........................................ ៤២

-តារាងកម្មវិធីសកម្មភាពរយៈពេលមធ្យម........................................ ៤៥

**កម្មវិធីសកម្មភាពរយៈពេលវែង**

-សកម្មភាពអាទិភាពរយៈពេលវែង........................................ ៦៥

-តារាងសង្ខេបអាទិភាពរយៈពេលវែង........................................ ៦៨

-តារាងកម្មវិធីសកម្មភាពរយៈពេលវែង........................................ ៦៩

**ដំណើរការនៅពេលខាងមុខ**........................................ ៨៥

# ពាក្យសរសេរកាត់

| | |
|---|---|
| ក.ក.ច.ន.យ | ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ |
| ក.ក.រ | ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល |
| ក្រ.អប់រំ | ក្រសួងអប់រំ យុវជន និងកីឡា |
| ក្រ.ព័ត៌មាន | ក្រសួងព័ត៌មាន |
| ក្រ.ក.ប | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ក្រ.កិច្ចការនារី | ក្រសួងកិច្ចការនារី |
| ក្រ.យុត្តិធម៌ | ក្រសួងយុត្តិធម៌ |
| ក្រ.មហាផ្ទៃ | ក្រសួងមហាផ្ទៃ |
| ក្រ.រៀបចំ.ដី | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| ក្រ.ទំនាក់ទំនង | ក្រសួងទំនាក់ទំនងជាមួយ រដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច |
| ក្រ.សេដ្ឋ.ហិរ | ក្រសួងសេដ្ឋកិច្ច  និងហិរញ្ញវត្ថុ |
| ក្រ.ពាណិជ្ជ | ក្រសួងពាណិជ្ជកម្ម |
| ក្រុ.ធម្មនុញ្ញ | ក្រុមប្រឹក្សាធម្មនុញ្ញ |
| ក្រុ.អ្នកច្បាប់ | ក្រុមប្រឹក្សាអ្នកច្បាប់ |
| ក្រុ.អភិវឌ្ឍន៍កម្ពុជា | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| គណៈមេធាវី | គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា |
| ទី.គ.មន្ត្រី | ទីស្តីការគណៈរដ្ឋមន្ត្រី |
| មហា.ច្បាប់ | មហាវិទ្យាល័យច្បាប់ |
| មជ្ឈមណ្ឌល.មេធាវី | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និងសុក្រិតការមេធាវី |
| មុខងារសាធារណៈ | រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ |
| ស.នីតិសាស្ត្រ | សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច |
| សា.ចៅក្រម | សាលាភូមិន្ទចៅក្រម |
| អ.គ.គ | អង្គភាពគ្រប់គ្រងគម្រោងកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ |
| អ.ម.រ | អង្គការមិនមែនរដ្ឋាភិបាល |

| | |
|---|---|
| អ.រ.ភ | អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល |
| ឧត្តម. ចៅក្រម | ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម |

| | |
|---|---|
| ACT | សម្ព័ន្ធដើម្បីការផ្លាស់ប្តូរវិវាទ |
| ADHOC | អង្គការដើម្បីសិទ្ធិមនុស្ស និងការអភិវឌ្ឍន៍ |
| CAS | មជ្ឈមណ្ឌលសម្រាប់ការសិក្សាជាន់ខ្ពស់ |
| CDP | ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា |
| CDRI | វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា |
| CICP | វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព |
| CLEC | មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ |
| LAC | ជំនួយផ្នែកច្បាប់នៃកម្ពុជា |
| LICADHO | សម្ព័ន្ធខ្មែរដើម្បីជំរុញ និងការពារសិទ្ធិមនុស្ស |
| SEACSN | បណ្តាញអាស៊ីអាគ្នេយ៍ដើម្បីសិក្សាវិវាទ |
| SILAKA | អង្គការគ្រប់គ្រងវិវាទ |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| Aus-Aid | ភ្នាក់ងារ-អូស្ត្រាលី ដើម្បីអភិវឌ្ឍន៍អន្តរជាតិ |
| CCJAP | កម្មវិធីជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា |
| CIDA | ភ្នាក់ងារកាណាដាដើម្បីអភិវឌ្ឍន៍អន្តរជាតិ |
| DIHR | វិទ្យាស្ថានដាណឺម៉ាកដើម្បីសិទ្ធិមនុស្ស |
| EWMI | វិទ្យាស្ថានគ្រប់គ្រងកើត-លិច |
| GTZ | សហប្រតិបត្តិការបច្ចេកទេសអាល្លឺម៉ង់ |
| ICRC | គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ |
| ILO | អង្គការពលកម្មអន្តរជាតិ |
| JICA | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន |
| KAF | មូលនិធិខុនរ៉ាដ អដេណូអ៊ែរ |
| UNDP | កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ |
| UNESCO | អង្គការសម្រាប់អប់រំវិទ្យាសាស្ត្រ និងវប្បធម៌នៃអង្គការសហប្រជាជាតិ |
| UNHCHR | ការិយាល័យតំណាងជាន់ខ្ពស់នៃអង្គការសហប្រជាជាតិសម្រាប់សិទ្ធិមនុស្ស |
| UNICEF | មូលនិធិសម្រាប់កុមារនៃអង្គការសហប្រជាជាតិ |
| WB | ធនាគារពិភពលោក |

# សេចក្ដីផ្ដើម

ភាពជឿនលឿននៃដំណើរការកំណែទម្រង់ច្បាប់និងតុលាការ បានឈានទៅមុខគួរឱ្យកត់សំគាល់ ។ យុទ្ធ-សាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ដែលត្រូវបានអនុម័តកាលពីចុងឆ្នាំ២០០២ បានគូសបង្ហាញនូវចំណុចសំខាន់ៗនៃយុទ្ធសាស្ត្រ និងកម្មវិធីសកម្មភាពរបស់កំណែទម្រង់ច្បាប់ និងតុលាការ ។

យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ ត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលនៅខែមិថុនា ឆ្នាំ២០០៣ ឈរលើទស្សនទានជាមូលដ្ឋានចំនួន ៤ ស្រង់ចេញពីរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា ។ ទស្សនទានទាំង ៤ នោះគឺ : សិទ្ធិបុគ្គល ប្រជាធិបតេយ្យសេរី ការបែងចែកអំណាចដាច់ពីគ្នា និងនីតិរដ្ឋ ។

យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការមានទិសដៅជាយុទ្ធសាស្ត្រ ៧ ដូចខាងក្រោមនេះ ÷

១- ពង្រឹងការការពារសិទ្ធិ និងសេរីភាពបុគ្គល ដោយបង្កើត និងគាំទ្រវិធានការសម្រាប់ការពារសិទ្ធិ និងបង្កើនការយល់ដឹងក្នុងចំណោមមហាជន និងស្ថាប័នពាក់ព័ន្ធ សំដៅជំរុញឱ្យមានការអភិវឌ្ឍន៍ដោយសមធមិ និងចីរភាព ដំណាលគ្នា និងជាចំណែកនៃការធ្វើឱ្យសម្រេចបាននូវសិទ្ធិ ។

២- ធ្វើទំនើបកម្មក្របខ័ណ្ឌច្បាប់ ដោយកសាងក្របខ័ណ្ឌច្បាប់មួយដែលសព្វគ្រប់ តាមរយៈដំណើរការធ្វើច្បាប់ ដែលផ្ដល់លទ្ធផលល្អ ស៊ីសង្វាក់គ្នា ហើយនិងមានការចូលរួម សំដៅធានាឱ្យបាននូវច្បាប់មួយ ដែលមានតុល្យភាព និងការអនុវត្តដោយពេញលេញនូវនីតិរដ្ឋ ។

៣- ផ្ដល់លទ្ធភាពទទួលបានព័ត៌មានអំពីច្បាប់ និងតុលាការ ឱ្យកាន់តែប្រសើរឡើង ដោយជំរុញនូវការផ្សព្វផ្សាយចំណេះដឹងច្បាប់ជាមូលដ្ឋាន តាមរយៈការបោះពុម្ពផ្សាយជាផ្លូវការ ប្រព័ន្ធផ្សព្វផ្សាយអេឡិច-ត្រូនិច និងបណ្ណាល័យព័ត៌មាន និងធានានូវភាពងាយស្រួលក្នុងការទទួលបានព័ត៌មានច្បាប់ និងតុលាការដល់អ្នកប្រកបមុខវិជ្ជាជីវៈផ្នែកច្បាប់ និងដល់អ្នកដែលយកចិត្តទុកដាក់ផ្សេងទៀត ។

៤- ធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃដំណើររឿងក្ដី និងសេវាកម្មពាក់ព័ន្ធ ដោយពង្រឹងវិជ្ជាជីវៈផ្នែកច្បាប់ ធ្វើឱ្យបានប្រសើរឡើងនូវជំនួយផ្នែកច្បាប់ ហើយនិងសម្រួលនីតិវិធីតុលាការ ដើម្បីធានានូវយុត្តិធម៌ និងដំណើរការត្រឹមត្រូវសម្រាប់ប្រជាពលរដ្ឋ ។

៥- ពង្រឹងសេវាកម្មយុត្តិធម៌ រួមមានអំណាចតុលាការ និងសេវាកម្មផ្នែកអយ្យការ ដោយបញ្ចូលវិធានការចាំបាច់នានា ផ្នែកអប់រំ ច្បាប់ នីតិវិធី និងរចនាសម្ព័ន្ធ ដើម្បីធានាភាពទទួលបានយុត្តិធម៌ពីស្ថាប័នយុត្តិធម៌មួយដែលត្រឹមត្រូវ គួរឱ្យជឿទុកចិត្តបាន ឯករាជ្យ និងទទួលការគោរពពីសាធារណជនទូទៅ ។

៦- បញ្ចូលយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដើម្បីផ្ដល់ដំណោះស្រាយវិវាទឱ្យបានឆាប់រហ័ស និងងាយស្រួលដល់ភាគីពាក់ព័ន្ធ ហើយនិងជួយសម្រាលដល់បន្ទុករបស់ប្រព័ន្ធតុលាការ ។

៧- ពង្រឹងស្ថាប័នវិស័យច្បាប់ និងតុលាការឱ្យបំពេញអាណត្តិរបស់ខ្លួនបានសម្រេច ដោយពង្រឹងការគ្រប់គ្រង ការធ្វើផែនការ យន្តការត្រួតពិនិត្យនានា និងសមត្ថភាពជាទូទៅ សំដៅផ្តល់នូវសេវាសាធារណៈមួយពេញលេញ និងធានាឱ្យការធ្វើសេចក្តីសម្រេចស្របទៅនឹងគោលការណ៍អភិបាលកិច្ចល្អ និងការអនុវត្តប្រកបដោយប្រសិទ្ធភាព ។

ក្នុងទស្សនៈបង្កើនល្បឿនកំណែទម្រង់ និងធ្វើឱ្យបានប្រសើរឡើងនូវការសម្របសម្រួលនៅក្នុងវិស័យនេះ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ត្រូវបានបង្កើតឡើងកាលពីខែមិថុនា ឆ្នាំ២០០២ ដោយព្រះរាជ-ក្រឹត្យលេខ នស/រក/០៦០២/១៤៨ ។ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានបេសកកម្មផ្តួចផ្តើម និងលើកទឹកចិត្តដល់ដំណើរការ និងតាមដានការអនុវត្តគោលនយោបាយ និងកម្មវិធីកំណែទម្រង់ច្បាប់ និងតុលាការស្របទៅនឹងទិសដៅរបស់ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ។ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ដែលមានសមាជិកមកពីក្រសួងគន្លឹះ និងស្ថាប័ននានានៃវិស័យច្បាប់ និងតុលាការ (អនុក្រឹត្យលេខ៨៧ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២) ជាជំនួយការ ។ អង្គភាពនេះទទួលខុសត្រូវក្នុងការទំនាក់ទំនងជាមួយថ្នាក់នយោបាយ(ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌) ដើម្បីធានាការប្តេជ្ញាចិត្ត ដែលកំពុងតែប្រព្រឹត្តទៅចំពោះដំណើរការ ។ អង្គភាពសម្របសម្រួលអចិន្ត្រៃយ៍មានអង្គភាពគ្រប់គ្រង-គម្រោងដែលបង្កើតឡើងដោយអនុក្រឹត្យលេខ១២៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០២ ជាជំនួយការ ។ អង្គភាពគ្រប់គ្រងគម្រោងនេះ ត្រូវបានបង្កើតឡើង ដើម្បីជួយអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ក្នុងការបំពេញតួនាទីរបស់ខ្លួន ជាសេនាធិការរបស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ។

ជាជំហានបន្ទាប់ពីការអនុម័តជាផ្លូវការនៃយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ ដែលអមដោយសេចក្តីព្រាងកម្មវិធីសកម្មភាព ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានចាប់ផ្តើមដំណាក់កាលអនុវត្តយុទ្ធសាស្ត្រ តាមរយៈសិក្ខាសាលាថ្នាក់ជាតិស្តីពីកំណែទម្រង់ច្បាប់ និងតុលាការ នាខែធ្នូ ឆ្នាំ២០០៣ ដើម្បីកំណត់សកម្មភាពជាអាទិភាព ។ សិក្ខាសាលានេះ ត្រូវបានប្រារព្ធធ្វើឡើង ដោយមានការឧបត្ថម្ភពីអ្នកផ្តល់ជំនួយសំខាន់ៗ និងត្រូវបានចូលរួមដោយអ្នកពាក់ព័ន្ធមកពីមជ្ឈដ្ឋាននានាយ៉ាងច្រើន ។ ក្នុងទស្សនៈដើម្បីជំរុញការចូលរួមបន្តពីសំណាក់អ្នកពាក់ព័ន្ធទាំងអស់ នៅក្នុងដំណាក់កាលនៃដំណើរការកំណែទម្រង់នេះ អង្គភាពគ្រប់គ្រងគម្រោងបានដឹកនាំកិច្ចប្រជុំក្រុមការងារពិភាក្សាជាបន្តបន្ទាប់មានចំនួន ១៣ដង និងប្រជុំទ្វេភាគីមួយចំនួនជាមួយអ្នកផ្តល់ជំនួយសំខាន់ៗ ។ សមាជិកចូលរួមប្រជុំមានតំណាងមកពីស្ថាប័នរដ្ឋវិស័យច្បាប់និងយុត្តិធម៌ ពីសង្គមស៊ីវិល និងសហគមន៍អន្តរជាតិ ។ លទ្ធផលបានមកពីកិច្ចប្រជុំទាំងនោះ ត្រូវបានយកមកប្រើជាទិន្នន័យបញ្ចូលក្នុងកម្មវិធីសកម្មភាពសំរាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការនាពេលនេះ ។

រាជរដ្ឋាភិបាលប្តេជ្ញានឹងបង្កើនល្បឿននៃដំណើរការកំណែទម្រង់ច្បាប់ និងតុលាការ។ គោលនយោបាយជាអាទិភាព គឺធ្វើឱ្យបានប្រសើរឡើងនូវការផ្តល់សេវាច្បាប់ និងតុលាការ ដែលជាលក្ខខណ្ឌគន្លឹះសម្រាប់ចីរភាពនៃ

ការអភិវឌ្ឍយុត្តិធម៌សង្គម និងការកាត់បន្ថយភាពក្រីក្រ ។ ប្រតិបត្តិការជាអាទិភាពមានដូចតទៅ : បំពេញឱ្យចប់សព្វគ្រប់នូវកិច្ចការទាក់ទងទៅនឹងក្រមរដ្ឋប្បវេណី និងក្រមព្រហ្មទណ្ឌ កំណត់របៀបវារៈមួយដែលមានការឯកភាពគ្នា ដើម្បីផ្តល់នីតិសម្បទាដល់សេដ្ឋកិច្ចទីផ្សារ ធ្វើឱ្យបានប្រសើរឡើងនូវលទ្ធភាពទទួលបានសេវា និងព័ត៌មានផ្នែកច្បាប់ និងយុត្តិធម៌ ពង្រឹងសមត្ថភាពក្នុងការគ្រប់គ្រងកំណែទម្រង់ កៀងគរដៃគូចាំបាច់ និងធានានូវការជួយឧបត្ថម្ភជាហិរញ្ញវត្ថុចាំបាច់សម្រាប់គម្រោងនិងកម្មវិធីនានា ។ ដើម្បីដោះស្រាយនូវបញ្ហាប្រឈមមុខពាក់ព័ន្ធដល់អំពើពុករលួយ និងការកកស្ទះសំណុំរឿងក្តីនៅក្នុងតុលាការ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌បានកំណត់នូវសកម្មភាពជាបន្ទាន់មួយចំនួនទៅតាមការជាក់ស្តែង ។ សកម្មភាពទាំងនេះ ក៏មានលើកឡើងនៅក្នុងឯកសារកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការនេះដែរ ។

ឯកសារនេះ មានរៀបរាប់ជាលំអិតអំពីអាទិភាពដែលបានកំណត់សម្រាប់រយៈពេលខ្លី និងរយៈពេលមធ្យម ។ សកម្មភាពនានាត្រូវបានដកស្រង់ពីសេចក្តីព្រាងកម្មវិធីសកម្មភាព ដែលបានបង្ហាញជូនជាមួយនឹងយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ កាលពីខែមិថុនា ឆ្នាំ២០០៣ ។ អន្តរាគមន៍ជាបន្តបន្ទាប់មួយចំនួនដែលឆ្លុះបញ្ចាំងនូវតម្រូវការពាក់ព័ន្ធដល់គោលនយោបាយ និងដល់គម្រោង ក៏មានបង្ហាញជាលំអិតជាមួយនឹងសកម្មភាពនីមួយៗនោះដែរ ។

រយៈពេលខ្លី និងមធ្យម មានឆ្លុះបញ្ចាំងនូវរយៈពេលប៉ាន់ស្មានសម្រាប់ការអនុវត្តសកម្មភាពជាក់លាក់មួយព្រមទាំងអន្តរាគមន៍ទាំងអស់ដែលពាក់ព័ន្ធ ។ រយៈពេលខ្លី គឺចាប់ពីឆ្នាំ២០០៤ ដល់ ២០០៥ ឬអាចតទៅក្នុងឆ្នាំ២០០៦ ។ រយៈពេលមធ្យមគឺចាប់ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៨ ឯចំណែករយៈពេលវែងគឺបន្តពីឆ្នាំ២០០៨ ឡើងទៅ ។

មានសកម្មភាពជាច្រើនដូចជា ការស្ទង់មតិ ឬការពិនិត្យឡើងវិញនូវច្បាប់ណាមួយ អាចចាប់ផ្តើមនៅក្នុងរយៈពេលខ្លី ប៉ុន្តែនឹងឈានចូលទៅក្នុងអន្តរាគមន៍ជាបន្តបន្ទាប់ ដែលអាចត្រូវអនុវត្តរហូតទៅដល់រយៈពេលមធ្យម ឬក៏វែងទៀតផង ។

សកម្មភាពរយៈពេលខ្លី និងមធ្យម មានចំនួនសរុបទាំងអស់ ៥៨ ក្នុងចំណោមសកម្មភាព ៩៣ ដែលបានកំណត់នៅក្នុងឯកសារសេចក្តីព្រាងកម្មវិធីសកម្មភាព ដែលបានដាក់បង្ហាញជូនកាលពីខែមិថុនា ឆ្នាំ២០០៣ ។ នៅក្នុងដំណាក់កាលនៃការពិភាក្សាជាបន្តបន្ទាប់ ក្រុមការងារបានបន្ថែមសកម្មភាពចំនួន ២ និងក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានបន្ថែមមួយ ហើយគណៈរដ្ឋមន្ត្រីនាសម័យប្រជុំពេញអង្គ ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ បន្ថែមមួយទៀត ។ ដូច្នេះចំនួននៅសល់មាន ៣៩ ។ សកម្មភាពទាំង៣៩នេះ ត្រូវបានចាត់ទុកជាសកម្មភាពសម្រាប់រយៈពេលវែងដែលត្រូវអនុវត្តបន្ត ឬបន្ទាប់ពីរយៈពេលខ្លី និងមធ្យម ដែលពុំទាន់ត្រូវបានធ្វើចប់សព្វគ្រប់នៅឡើយ ។

មកទល់ពេលនេះ ដៃគូទ្វេភាគីសំខាន់ៗក្នុងដំណើរការកំណែទម្រង់ មានប្រទេសជប៉ុន បារាំង អូស្ត្រាលី អាល្លឺម៉ង់ កាណាដា និងដាណឺម៉ាក ។ ចំណែកដៃគូពហុភាគីមានជាអាទិ៍ ធនាគារពិភពលោក(WB) កម្មវិធី

អភិវឌ្ឍន៍អង្គការសហប្រជាជាតិ(UNDP) និងធនាគារអភិវឌ្ឍន៍អាស៊ី(ADB) ។ ការចរចាកំពុងតែធ្វើបន្តជាមួយអ្នកផ្តល់ជំនួយដទៃទៀត ។ តាមរយៈការបង្ហាញជូននូវកម្មវិធីសកម្មភាពនេះ ក្រុមប្រឹក្សាកំណែទម្រង់ ច្បាប់ និងប្រព័ន្ធយុត្តិធម៌ សង្ឃឹមថានឹងអាចចលនាបាននូវដៃគូច្រើនទៀត ហើយនឹងអភិវឌ្ឍយុទ្ធសាស្ត្រសម្របសម្រួលការអនុវត្តន៍ដំណើរការកំណែទម្រង់បានល្អប្រសើរ ។

# បញ្ហាប្រឈមមុខ
# ដែលត្រូវដោះស្រាយជាបន្ទាន់

# បញ្ហាប្រឈមមុខដែលត្រូវដោះស្រាយជាបន្ទាន់

## ក-បញ្ហាទប់ស្កាត់អំពើពុករលួយក្នុងតុលាការ

**•ពង្រឹងអធិការកិច្ចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងក្រសួងយុត្តិធម៌ :**

-ពង្រឹងអធិការកិច្ចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម លើការងារបច្ចេកទេស និងរបស់ក្រសួងយុត្តិធម៌លើការងាររដ្ឋបាល ដើម្បីមានវិធានការដាក់វិន័យដល់ចៅក្រម និងព្រះរាជអាជ្ញាដែលមានកំហុស ។

**•ពង្រឹងប្រសិទ្ធិភាពឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម :**

-ពង្រឹងអំណាចក្រុមប្រឹក្សាវិន័យ និងប្រគល់សិទ្ធិចាត់វិធានការបណ្ដោះអាសន្ន ជូនក្រុមប្រឹក្សាវិន័យមុនការយល់ព្រមរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

-សិក្សាអំពីការធ្វើឱ្យដំណើរការ របស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកាន់តែសកម្ម និងមានប្រសិទ្ធភាព

-កំណត់ និងអនុវត្តគោលការណ៍ផ្លាស់ប្ដូរចៅក្រម និងព្រះរាជអាជ្ញា សម្រាប់រយៈពេល ៤ឆ្នាំម្ដង ។

**•កំណត់ថវិកាសំរាប់ការចុះស៊ើបអង្កេត :**

-កំណត់ថវិកាចុះស៊ើបអង្កេតសម្រាប់តុលាការគ្រប់ជាន់ថ្នាក់ ដោយប្រើខ្ទង់ប្រាក់បេសកកម្មនៃថវិកាជាតិ ។

**•ពង្រឹងសីលធម៌ចៅក្រម និងព្រះរាជអាជ្ញា :**

- ជំរុញការរៀបចំក្រមសីលធម៌សម្រាប់ចៅក្រម និងព្រះរាជអាជ្ញា ។

## ខ-បញ្ហាកកស្ទះសំណុំរឿងនៅតុលាការ

**•បញ្ហាខ្វះបន្ទប់សវនាការ :**

១-សម្រាប់តុលាការក្រុងភ្នំពេញ និងសាលាឧទ្ធរណ៍ :

ជាជំហានដំបូង និងជាបណ្ដោះអាសន្ន ស្នើសុំរាជរដ្ឋាភិបាល :

-ជួលភូមិគ្រឹះមួយដែលមាន ០៨ បន្ទប់ (បន្ទប់សវនាការមួយត្រូវការ ០៤ បន្ទប់ ) ដើម្បីធ្វើជាសភារដ្ឋប្បវេណីជូនតុលាការក្រុងភ្នំពេញ ។ អាគារបច្ចុប្បន្ន របស់តុលាការក្រុងភ្នំពេញ ទុកសម្រាប់កាត់ក្ដីរឿងព្រហ្មទណ្ឌ ។

-ជួលភូមិគ្រឹះ ០១ ដែលមាន ០៥ បន្ទប់ជូនសាលាឧទ្ធរណ៍ ។

ជាជំហានបន្ទាប់ ជំរុញការសាងសង់វិមានយុត្តិធម៌នៅលើដី ដែលរាជរដ្ឋាភិបាលបានផ្ដល់ជូនតុលាការ ។

២-សម្រាប់តុលាការខេត្តបន្ទាយមានជ័យ :

-ជួល និងលើកគម្រោងជួសជុលតុលាការបច្ចុប្បន្ន

៣-សម្រាប់តុលាការខេត្ត ក្រុងដទៃទៀត

-ដូចតុលាការក្រុងភ្នំពេញដែរ គឺអនុញ្ញាតអោយជួលអាគារ ក្នុងករណីខ្វះបន្ទប់សវនាការ ដោយចំណាយថវិកាពិសេសរបស់រាជរដ្ឋាភិបាល ។

**•បញ្ហាខ្វះខាតមេធាវី :**

-ពង្រឹងភារកិច្ចរបស់គណៈមេធាវីក្នុងការទទួលខុសត្រូវ ផ្តល់មេធាវីដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់តុលាការ ។

**•បញ្ហាបញ្ជូនជនជាប់ចោទពីពន្ធនាគារចូលសវនាការ :**

-ចេញបទបញ្ជាឱ្យនាយកដ្ឋានពន្ធនាគារ បំពេញភារកិច្ចបញ្ជូនជនជាប់ចោទចូលសវនាការដើម្បីជំរះក្តី អោយបានតាមតម្រូវការរបស់តុលាការ

-ស្នើដោះស្រាយរថយន្តចំនួន ០២គ្រឿង ជូនពន្ធនាគារព្រៃស សម្រាប់ដឹកជនជាប់ចោទចូលសវនាការ ។ ចំពោះខេត្ត ក្រុងដទៃទៀត ស្នើក្រសួងមហាផ្ទៃលើកគម្រោងទិញរថយន្តជូនពន្ធនាគារ ដែលមានការខ្វះខាត ។

**•បញ្ហាសំណុំរឿងចាស់ៗ :**

-ជំរុញឱ្យចៅក្រមយកសំណុំរឿងក្តីចាស់ៗទាំងអស់ មកចាត់ការឱ្យបានឆាប់ ។

**•បញ្ហាបង្វិលដីកាកោះ :**

-ចំពោះរឿងព្រហ្មទណ្ឌ កំណត់ឱ្យនគរបាលយុត្តិធមិទទួលខុសត្រូវក្នុងការបញ្ជូន និងបង្វិលដីកាកោះ

-ចំពោះរឿងរដ្ឋប្បវេណី តុលាការត្រូវធ្វើការទាក់ទងផ្ទាល់ជាមួយអាជ្ញាធរដែនដី ដោយឧបត្ថម្ភជាប្រាក់តាមរបបបេសកកម្ម ។

## គ-បញ្ហារឿងរដ្ឋប្បវេណី

-ក្រសួងយុត្តិធមិត្រូវពិនិត្យ និងកែសម្រួលសារាចរលេខ ០៤ សរច ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ១៩៨៤ ស្តីពីសេចក្តីណែនាំនីតិវិធីរដ្ឋប្បវេណី ។

# កម្មវិធីសកម្មភាព
# រយៈពេលខ្លី

# សកម្មភាពអាទិភាពរយៈពេលខ្លី

◆១.១.៤ ការបញ្ចូលមុខវិជ្ជាសិទ្ធិមនុស្ស/ពលរដ្ឋវិទ្យា ទៅក្នុងកម្មវិធីសាលារៀន

■១.២.២ ការស្ទង់មតិអំពីកម្មវិធីបណ្តុះបណ្តាលបច្ចុប្បន្នពីសិទ្ធិមូលដ្ឋានសម្រាប់ទីភ្នាក់ងារអនុវត្តច្បាប់ ដើម្បីរកឱ្យឃើញចន្លោះប្រហោង និងកន្លែងដែលត្រូវកែលំអ

◆១.២.៣ បង្កើតកម្មវិធីនិងសម្ភារៈបណ្តុះបណ្តាលរួមទាំងការបង្កើតមុខវិជ្ជាសិទ្ធិមនុស្សនៅកំរិតសាកល-វិទ្យាល័យ សម្រាប់កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងបណ្តុះបណ្តាលបន្ត (ការបណ្តុះបណ្តាលដោះស្រាយបញ្ហា និងឯកទេសចាំបាច់)

■១.៤.៥ ពិនិត្យលទ្ធភាពធ្វើឱ្យប្រសើរឡើងនូវការរួមចំណែករបស់សង្គមស៊ីវិលក្នុងវិស័យច្បាប់ និងតុលាការ

◆ ១.៤.៦ ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ

■២.១.២ ព្រាង អនុម័ត និងអនុវត្តក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី (ដំណាក់កាលទី ១)

■២.១.៣ ព្រាង អនុម័ត និងអនុវត្តក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ (ដំណាក់កាលទី ១)

◆២.១.៤ ច្បាប់អង្គការស្តីពីការរៀបចំតុលាការ (ដំណាក់កាលទី ១)

■២.១.៩ ការធ្វើវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

◆២.១.១០ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម (ដំណាក់កាលទី ១)

◆២.២.២ ការអនុវត្តកម្មវិធីកំណែទម្រង់ច្បាប់តាមផ្នែក(បញ្ជីមេ រួមទាំងច្បាប់តម្រូវដោយអង្គការពាណិជ្ជកម្មពិភពលោក)

◆២.២.៤ រៀបចំបញ្ជីច្បាប់ដែលមិនទាន់អនុម័ត រួមទាំងរយៈពេលសម្រាប់បញ្ចប់ និងការត្រួតពិនិត្យតាមដានការជឿនលឿន

◆២.៣.១ ច្បាប់/នីតិវិធី/សេចក្តីណែនាំសម្រាប់ការធ្វើច្បាប់ ដោយផ្តោតជាពិសេសទៅលើការធានានូវការចូលរួម និងតម្លាភាព

●២.៤.១ ច្បាប់ស្តីពីលទ្ធភាពទទួលបាននូវព័ត៌មាន និងបទប្បញ្ញត្តិនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ព្រហ្មទណ្ឌ និងរដ្ឋបាល ដើម្បីធានាលទ្ធភាពទទួលបាននូវព័ត៌មានដល់សាធារណជន

◆៣.១.៣ ការធ្វើឱ្យមានការបោះពុម្ពផ្សាយជាទៀងទាត់ និងជាលក្ខណៈស្ថាប័ននូវរាជកិច្ច ច្បាប់ និងទិន្នន័យព័ត៌មានច្បាប់

◆៣.២.២ ការប្រមូល និងការបោះពុម្ពសេចក្តីសម្រេចរបស់តុលាការកំពូល និងសេចក្តីសម្រេចជាស្ថាពរ នៃតុលាការផ្សេងទៀត

◆ ក- សេចក្តីសម្រេចរបស់តុលាការកំពូល

● ខ- សេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍

● គ- សេចក្តីសម្រេចរបស់តុលាការខេត្ត-ក្រុង

◆៤.១.១ គោលនយោបាយ និងលិខិតបទដ្ឋានស្តីពីតំណាងផ្នែកច្បាប់ និងជំនួយផ្នែកច្បាប់ រួមទាំងការធានានូវសេរីភាពរបស់អង្គការមិនមែនរដ្ឋាភិបាលដើម្បីផ្តល់ជំនួយផ្នែកច្បាប់ (ដំណាក់កាលទី ១)

●៤.១.២ ធ្វើការស្ទង់មតិអំពីលទ្ធភាព និងសេចក្តីត្រូវការសម្រាប់ជំនួយផ្នែកច្បាប់ ឈរលើទស្សនៈ ដើម្បីបំពេញចន្លោះប្រហោង

●៤.២.១ ការពិនិត្យឡើងវិញលើច្បាប់ស្តីពីលក្ខន្តិកៈមេធាវី និងការសម្រួលនីតិវិធីរួមទាំងលក្ខណៈវិនិច្ឆ័យមានតម្លាភាព ដើម្បីចូលជាសមាជិកគណៈមេធាវី

■៤.២.២ ការធានាឱ្យមានមជ្ឈមណ្ឌល ដែលមានដំណើរការល្អប្រសើរសម្រាប់បណ្តុះបណ្តាលមេធាវី ដោយផ្តល់នូវការបណ្តុះបណ្តាលមូលដ្ឋាន ឯកទេស និងដំណោះស្រាយបញ្ហាដល់មេធាវីទាំងអស់

●៥.២.២ លក្ខន្តិកៈចៅក្រម និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលមានដំណើរការយ៉ាងពេញលេញ ដែលធានានូវតម្លាភាពក្នុងការតែងតាំង ការតម្លើងស័ក្តិ ប្រាក់បៀវត្ស និងការដាក់វិន័យចៅក្រម និងព្រះរាជអាជ្ញា (ដំណាក់កាលទី ១)

◆៥.២.៤ រៀបចំក្រមសីលធម៌សម្រាប់ចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីយុត្តិធម៌ (ដំណាក់កាលទី ១)

◆៥.២.៦ វិធានការប្រឆាំងអំពើពុករលួយ រួមទាំងច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយ

■៥.៣.២ វិធីសាស្ត្របង្កើតតុលាការគំរូ

■៥.៤.២ សាលាចៅក្រម និងសាលាសម្រាប់មន្ត្រីយុត្តិធម៌ រួមទាំងកម្មវិធីបណ្តុះបណ្តាលបន្តសម្រាប់អ្នកមានតួនាទីទាំងអស់(ការបណ្តុះបណ្តាលមូលដ្ឋាន ឯកទេស និងដំណោះស្រាយបញ្ហា) ស្របទៅតាមសេចក្តីត្រូវការ

◆៥.៤.៤ វិធានការបង្កើតតុលាការ/សភាពាណិជ្ជកម្ម និងតុលាការ/សភាផ្សេងទៀត រួមទាំងបែបបទតុលាការពាណិជ្ជកម្ម និងការបណ្តុះបណ្តាលអ្នកឯកទេសផ្នែកច្បាប់ពាណិជ្ជកម្ម (ដំណាក់កាលទី ១)

●៥.៤.៥ វិធានការបង្កើតតុលាការរដ្ឋបាល (ដំណាក់កាលទី ១)

●៥.៥.១ ការស្ទង់មតិលើយន្តការអនុវត្តនៃច្បាប់បច្ចុប្បន្ន ដើម្បីរកឱ្យឃើញចំណុចកែលំអ

◆៦.១.១ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ដំណាក់កាលទី ១)

●៦.២.១ ស៊ើបអង្កេត កសាង និង ពង្រឹងវិធីសាស្ត្រជាប្រពៃណី នៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

◆៧.៤.១ បង្កើតប្រព័ន្ធពិនិត្យតាមដាននៃវិស័យយុត្តិធម៌ ដើម្បីវាស់វែងការអនុវត្តទូទៅ រួមទាំងរដ្ឋបាលនៃវិស័យនេះដើម្បីជាមគ្គុទ្ទេសក៍សម្រាប់កំណែទម្រង់ទាំងមូល

●៧.៥.១ ការអភិវឌ្ឍ និងការរក្សានូវប្រព័ន្ធរួមមួយអំពីការធ្វើផែនការ ការរៀបចំថវិកា និងសវនកម្ម ការតាមដាន និងការធ្វើរបាយការណ៍ ស្របទៅតាមផែនការរបស់រាជរដ្ឋាភិបាល និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម

◆៧.៥.២ ផែនការ ការងារសម្រាប់នគរបាល ប្រព័ន្ធពន្ធនាគារ អយ្យការ រដ្ឋបាលតុលាការ និងស្ថាប័នផ្សេងៗទៀតនៃវិស័យច្បាប់ និងតុលាការ រួមទាំងសាលារៀនរបស់វិស័យច្បាប់ និងតុលាការ

◆៧.៧.១ កសាងសមត្ថភាពចាំបាច់សម្រាប់ស្ថាប័ននីមួយៗ ដើម្បីបំពេញអាណត្តិរបស់ខ្លួន ដោយការអភិវឌ្ឍន៍គោលនយោបាយគ្រប់គ្រងធនធានមនុស្ស ។

**កំណត់សំគាល់**

■ សកម្មភាពរយៈពេលខ្លីដែលជឿនលឿនទៅមុខបានស្រួលបួលហើយ

◆ សកម្មភាពរយៈពេលខ្លីដែលកំពុងដំណើរការ ប៉ុន្តែត្រូវការអន្តរាគមន៍បន្ថែមជំនួយឧបត្ថម្ភ ។ល ។

● សកម្មភាពរយៈពេលខ្លីដែលពុំទាន់បានចាប់ផ្តើមនៅឡើយ ។

# តារាងសង្ខេបអាទិភាពរយៈពេលខ្លី

## ទិសដៅជាយុទ្ធសាស្ត្រទី ១:ការពារសិទ្ធិ-សេរីភាពរបស់បុគ្គល

- ការបញ្ចូលមុខវិជ្ជាសិទ្ធិមុនស្ស និងពលរដ្ឋវិទ្យាទៅក្នុងកម្មវិធីសាលារៀន
- ការស្ទង់មតិអំពីកម្មវិធីបណ្តុះបណ្តាលបច្ចុប្បន្នអំពីសិទ្ធិមូលដ្ឋានសម្រាប់ទីភ្នាក់ងារអនុវត្តច្បាប់
- បង្កើតមុខវិជ្ជាសិទ្ធិមនុស្សនៅកម្រិតសាកលវិទ្យាល័យ
- ពិនិត្យលទ្ធភាពធ្វើឱ្យប្រសើរឡើងនូវការរួមចំណែករបស់សង្គមស៊ីវិល ក្នុងវិស័យច្បាប់ និងតុលាការ
- ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ

## ទិសដៅជាយុទ្ធសាស្ត្រទី ២:ធ្វើទំនើបកម្មក្របខ័ណ្ឌច្បាប់

- ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី (ដំណាក់កាលទី ១)
- ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ (ដំ.១)
- ច្បាប់អង្គការស្តីពីការរៀបចំតុលាការ (ដំ.១)
- វិសោធនកម្មច្បាប់ឧត្តម-ក្រុមប្រឹក្សានៃអង្គចៅក្រម
- ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម (ដំណាក់កាលទី ១)
- កំណែទម្រង់ច្បាប់តាមផ្នែក (បញ្ជីមេរួមទាំងច្បាប់ដែលតម្រូវដោយ WTO
- រៀបចំបញ្ជីច្បាប់មិនទាន់អនុម័ត
- ច្បាប់/នីតិវិធីសម្រាប់ធ្វើច្បាប់
- ច្បាប់ស្តីពីលទ្ធភាពទទួលបានព័ត៌មាន

## ទិសដៅជាយុទ្ធសាស្ត្រទី ៣: ផ្តល់លទ្ធភាពឱ្យទទួលបានព័ត៌មានអំពីច្បាប់ និងតុលាការឱ្យកាន់តែប្រសើរឡើង

- ការបោះពុម្ពផ្សាយជាទៀងទាត់និងជាលក្ខណៈស្ថាប័ននូវរាជកិច្ច និងទិន្នន័យព័ត៌មានច្បាប់
- ការប្រមូល និងការបោះពុម្ពសេចក្តីសំរេចរបស់តុលាការកំពូល និងសេចក្តីសម្រេចជាស្ថាពរនៃតុលាការផ្សេងទៀត

## ទិសដៅជាយុទ្ធសាស្ត្រទី ៤: ធ្វើឱ្យប្រសើរឡើងនូវគុណ-ភាពនៃដំណើររឿងក្តី និងសេវាពាក់ព័ន្ធ

- គោលនយោបាយ និងលិខិតបទដ្ឋានស្តីពីតំណាងផ្នែកច្បាប់ និងជំនួយផ្នែកច្បាប់ (ដំណាក់កាលទី ១)
- ការស្ទង់មតិអំពីភាពអាចមាន និងតម្រូវការជំនួយផ្នែកច្បាប់
- ការពិនិត្យឡើងវិញលើច្បាប់ស្តីពីលក្ខន្តិកៈមេធាវី
- ពង្រឹងមជ្ឈមណ្ឌលបណ្តុះបណ្តាល និងសុក្រឹតការវិជ្ជាជីវៈមេធាវី

## ទិសដៅជាយុទ្ធសាស្ត្រទី ៥: ពង្រឹងសេវាកម្មយុត្តិធម៌ រួមមានអំណាចតុលាការ និងសេវាកម្មអយ្យការ

- ការពង្រឹងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម (ដំណាក់កាលទី ១)
- វិធានការប្រឆាំងអំពើពុករលួយ រួមទាំងច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយ
- វិធីសាស្ត្របង្កើតតុលាការគំរូ
- ពង្រឹងសាលាភូមិន្ទចៅក្រម
- វិធានការបង្កើតតុលាការពាណិជ្ជកម្ម
- ការស្ទង់មតិលើយន្តការអនុវត្តច្បាប់
- ក្រមសីលធម៌ចៅក្រម
- វិធានការបង្កើតតុលាការរដ្ឋបាល (ដំណាក់កាលទី ១)

## ទិសដៅជាយុទ្ធសាស្ត្រទី ៦: បញ្ចូលយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

- ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ដំណាក់កាលទី ១)
- អង្កេតអំពីវិធីសាស្ត្រជាប្រពៃណីនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

## ទិសដៅជាយុទ្ធសាស្ត្រទី ៧: ពង្រឹងស្ថាប័នវិស័យច្បាប់ និងតុលាការ ដើម្បីបំពេញអាណត្តិរបស់ខ្លួនបានសំរេច

- បង្កើតប្រព័ន្ធត្រួតពិនិត្យវិស័យយុត្តិធម៌
- កសាងសមត្ថភាពចាំបាច់សម្រាប់ស្ថាប័ននីមួយៗ ដើម្បីបំពេញអាណត្តិរបស់ខ្លួន
- ប្រព័ន្ធរួមអំពីការធ្វើផែនការ រៀបចំថវិកា ធ្វើសវនកម្ម តាមដាន និងរាយ-ការណ៍ (ដំណាក់កាលទី ១)
- ផែនការសកម្មភាពសម្រាប់ស្ថាប័នវិស័យយុត្តិធម៌ (ដំណាក់កាលទី ១ )

| ផែនការអនុវត្តរយៈពេលខ្លី | | | |
|---|---|---|---|
| | ២០០៤ | ២០០៥ | ២០០៦ |
| **ទិសដៅជាយុទ្ធសាស្ត្រទី ១ ការពារសិទ្ធិសេរីភាពរបស់បុគ្គល** | | | |
| ១.១.៤ ការបញ្ចូលសិទ្ធិមនុស្ស/ពលរដ្ឋវិទ្យាទៅក្នុងកម្មវិធីសិក្សាសាលារៀន | →→→→→→→→→→→→→ X | | |
| ១.២.២ ការស្ទង់មតិលើកម្មវិធីបណ្តុះបណ្តាលបច្ចុប្បន្នពីសិទ្ធិមូលដ្ឋានសម្រាប់ទីភ្នាក់ងារអនុវត្តច្បាប់ ដើម្បីរកឱ្យឃើញចន្លោះប្រហោង និងកន្លែងដែលត្រូវកែលំអ | →→→→→→→→→→→→→ X | | |
| ១.២.៣ បង្កើតកម្មវិធី និងសម្ភារៈបណ្តុះបណ្តាល រួមទាំងការបង្កើតមុខវិជ្ជាសិទ្ធិមនុស្សនៅកម្រិតសាកលវិទ្យាល័យ សម្រាប់កម្មវិធីបណ្តុះបណ្តាល វិជ្ជាជីវៈ និងបណ្តុះបណ្តាលបន្ត (ការបណ្តុះបណ្តាលដំណោះស្រាយបញ្ហា និងឯកទេសចាំបាច់) | →→→→→→→→→→→→→ X | | |
| ១.៤.៥ ពិនិត្យលទ្ធភាពធ្វើឱ្យប្រសើរឡើងនូវការរួមចំណែករបស់សង្គមស៊ីវិលក្នុងវិស័យច្បាប់ និងតុលាការ | →→→→→→→→→→→→→ X | | |
| ១.៤.៦ ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ | →→→→→→→→→→→→→ X | | |
| **ទិសដៅជាយុទ្ធសាស្ត្រទី ២ ធ្វើទំនើបកម្មក្របខ័ណ្ឌច្បាប់** | | | |
| ២.១.២ ព្រាង អនុម័ត និងអនុវត្តក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី (ដំណាក់កាលទី ១) | →→→→→→→→→→→→→ X | | |
| ២.១.៣ ព្រាង អនុម័ត និងអនុវត្តក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ (ដំណាក់កាលទី ១) | →→→→→→→→→→→→→ X | | |
| ២.១.៤ ច្បាប់អង្គការស្តីពីការរៀបចំតុលាការ (ដំណាក់កាលទី ១) | →→→→→→→→→→→→→ X | | |
| ២.១.៩ ការធ្វើវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម | →→→→→→→→→→→→→ X | | |
| ២.១.១០ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម (ដំណាក់កាលទី ១) | →→→→→→→→→→→→→ X | | |
| ២.២.២ ការអនុវត្តកម្មវិធីកំណែទម្រង់ច្បាប់តាមផ្នែក (បញ្ជីមេ រួមទាំងច្បាប់តម្រូវដោយអង្គការពាណិជ្ជកម្មពិភពលោក) | →→→→→→→→→→→→→ X | | |
| ២.២.៤ រៀបចំបញ្ជីច្បាប់ដែលមិនទាន់អនុម័ត រួមទាំងរយៈពេលសម្រាប់បញ្ចប់ និងការត្រួតពិនិត្យតាមដានការជឿនលឿន | →→→→→→→→→→→→→ X | | |
| ២.៣.១ ច្បាប់/នីតិវិធី/សេចក្តីណែនាំសម្រាប់ការធ្វើច្បាប់ ដោយផ្តោតជាពិសេសទៅលើការធានានូវការចូលរួម និងតម្លាភាព | →→→→→→→→→→→→→ X | | |
| ២.៤.១ ច្បាប់ស្តីពីលទ្ធភាពទទួលបាននូវព័ត៌មាន និងបទប្បញ្ញត្តិនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ព្រហ្មទណ្ឌ និងរដ្ឋបាល ដើម្បីធានាលទ្ធភាពទទួលបាននូវព័ត៌មានដល់សាធារណជន | →→→→→→→→→→→→→→→→→→→→X | | |

| | | | |
|---|---|---|---|
| **ទិសដៅជាយុទ្ធសាស្ត្រទី ៣ ផ្តល់លទ្ធភាពឱ្យទទួលបានព័ត៌មានច្បាប់ និងតុលាការឱ្យកាន់តែប្រសើរឡើង** | | | |
| ៣.១.៣ ការធ្វើឱ្យមានការបោះពុម្ពផ្សាយជាទៀងទាត់ និងជាលក្ខណៈស្ថាប័ននូវរាជកិច្ច និងទិន្នន័យព័ត៌មានច្បាប់ | →→→→→→→→→ →→→ X | | |
| ៣.២.២ ការប្រមូលនិងការបោះពុម្ពសេចក្តីសម្រេចរបស់តុលាការកំពូល និងសេចក្តីសម្រេចជាស្ថាពរនៃតុលាការផ្សេងទៀត | →→→→→→→→→ →→→ X | | |
| **ទិសដៅជាយុទ្ធសាស្ត្រទី ៤ ធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃមេធាវី និងសេវាពាក់ព័ន្ធ** | | | |
| ៤.១.១ គោលនយោបាយ និងលិខិតបទដ្ឋានស្តីពីតំណាងផ្នែកច្បាប់ និងជំនួយផ្នែកច្បាប់ រួមទាំងការធានានូវសេរីភាពរបស់អង្គការមិនមែនរដ្ឋាភិបាលដើម្បីផ្តល់ជំនួយផ្នែកច្បាប់ (ដំណាក់កាលទី ១) | →→→→→→→→→ →→→ X | | |
| ៤.១.២ ធ្វើការស្ទង់មតិអំពីលទ្ធភាព និងសេចក្តីត្រូវការសម្រាប់ជំនួយផ្នែកច្បាប់ ឈរលើទស្សនៈដើម្បីបំពេញចន្លោះប្រហោង | | →→→→→→→→ →→→ X | |
| ៤.២.១ ការពិនិត្យឡើងវិញលើច្បាប់ស្តីពីលក្ខន្តិកៈមេធាវី និងការសម្រួលនីតិវិធី រួមទាំងលក្ខណៈវិនិច្ឆ័យមានតម្លាភាព ដើម្បីចូលជាសមាជិកគណៈមេធាវី | →→→→→→→→→ →→→ X | | |
| ៤.២.២ ការធានាឱ្យមានមជ្ឈមណ្ឌលមានដំណើរការល្អប្រសើរសម្រាប់បណ្តុះបណ្តាលមេធាវី ដោយផ្តល់នូវការបណ្តុះបណ្តាលមូលដ្ឋាន និងបណ្តុះបណ្តាលឯកទេស និងការបណ្តុះបណ្តាលដំណោះស្រាយបញ្ហាដល់មេធាវីទាំងអស់ | →→→→→→→→→ →→→→→→→→→→X | | |
| **ទិសដៅជាយុទ្ធសាស្ត្រទី ៥ ពង្រឹងសេវាយុត្តិធម៌ រួមមានអំណាចតុលាការ និងសេវាកម្មអយ្យការ** | | | |
| ៥.២.២ លក្ខន្តិកៈចៅក្រម និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលដំណើរការយ៉ាងពេញលេញ ដែលធានានូវតម្លាភាព ក្នុងការតែងតាំង ការតម្លើងស័ក្តិ ប្រាក់បៀវត្ស និងការដាក់វិន័យចៅក្រម និងព្រះរាជអាជ្ញា (ដំណាក់កាលទី ១) | →→→→→→→→→ →→→→→→→→→→X | | |
| ៥.២.៤ ក្រមសីលធម៌សម្រាប់ចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីយុត្តិធម៌ (ដំណាក់កាលទី ១) | →→→→→→→→→ →→→ X | | |
| ៥.២.៦ វិធានការប្រឆាំងអំពើពុករលួយ រួមទាំងច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយ | →→→→→→→→→ →→→ X | | |
| ៥.៣.២ វិធីសាស្ត្របង្កើតតុលាការគំរូ | →→→→→→→→→ →→→ X | | |
| ៥.៤.២ សាលាចៅក្រម និងសាលាសម្រាប់មន្ត្រីយុត្តិធម៌ រួមទាំងកម្មវិធីបណ្តុះបណ្តាលបន្តសម្រាប់អ្នកមានតួនាទីទាំងអស់ (បណ្តុះបណ្តាលមូលដ្ឋាន ឯកទេស និងដំណោះស្រាយបញ្ហា) ស្របទៅតាមសេចក្តីត្រូវការ | →→→→→→→→→ →→→→→→→→→→X | | |
| ៥.៤.៤ វិធានការបង្កើតតុលាការ/សភាពាណិជ្ជកម្ម និងតុលាការ/សភាឯកទេសផ្សេងទៀត រួមទាំងបែបបទតុលាការពាណិជ្ជកម្ម និងការបណ្តុះបណ្តាលអ្នកឯកទេសផ្នែកច្បាប់ពាណិជ្ជកម្ម (ដំណាក់កាលទី ១) | →→→→→→→→→ →→→→→→→→→→X | | |

| | | | |
|---|---|---|---|
| ៥.៤.៥ វិធានការបង្កើតតុលាការរដ្ឋបាល (ដំណាក់កាលទី ១) | | →→ →→→ **X** | |
| ៥.៥.១ ការស្ទង់មតិលើយន្តការនៃការអនុវត្តច្បាប់បច្ចុប្បន្ន ដើម្បីរកឱ្យឃើញចំណុចកែលំអ | | →→ →→→ **X** | |
| **ទិសដៅជាយុទ្ធសាស្ត្រទី ៦ បញ្ចូលយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ** | | | |
| ៦.១.១ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ដំណាក់កាលទី ១) | →→→→→→→→→ →→→ **X** | | |
| ៦.២.១ ស៊ើបអង្កេត កសាង និងពង្រឹងវិធីសាស្ត្រជាប្រពៃណីនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ | →→→→→→→→→ →→→ **X** | | |
| **ទិសដៅជាយុទ្ធសាស្ត្រទី ៧ ពង្រឹងស្ថាប័នវិស័យច្បាប់ និងតុលាការដើម្បីបំពេញអាណត្តិរបស់ខ្លួនបានសម្រេច** | | | |
| ៧.៤.១ បង្កើតប្រព័ន្ធពិនិត្យតាមដាននៃវិស័យយុត្តិធម៌ ដើម្បីវាស់វែងការអនុវត្តទូទៅ រួមទាំងរដ្ឋបាលនៃវិស័យនេះ ដើម្បីជាមគ្គុទេសក៏សម្រាប់កំណែទម្រង់ទាំងមូល | →→→→→→→→→ →→→→→→→→→→X | | |
| ៧.៥.១ ការអភិវឌ្ឍ និងការរក្សានូវប្រព័ន្ធរួមមួយអំពីការធ្វើផែនការ ការរៀបចំថវិកា និងសនវកម្ម ការតាមដាន និងការធ្វើរបាយការណ៍ស្របទៅតាមផែនការរបស់រាជរដ្ឋាភិបាល និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម (ដំណាក់កាលទី ១) | →→→→→→→→→→→→→→→→→→→X | | |
| ៧.៥.២ ផែនការ ការងារសម្រាប់នគរបាល ប្រព័ន្ធពន្ធនាគារ អយ្យការ រដ្ឋបាលតុលាការ និងស្ថាប័នផ្សេងៗទៀត នៃវិស័យច្បាប់ និងតុលាការ រួមទាំងសាលារៀនរបស់វិស័យច្បាប់ និងតុលាការ (ដំណាក់កាលទី ១) | →→→→→→→→→ →→→→→→→→→→X | | |
| ៧.៧.១ កសាងសមត្ថភាពចាំបាច់សម្រាប់ស្ថាប័ននីមួយៗ ដើម្បីបំពេញអាណត្តិរបស់ខ្លួន ដោយការអភិវឌ្ឍគោលនយោបាយគ្រប់គ្រងធនធានមនុស្ស | →→→→→→→→→ →→→→→→→→→→X | | |

## តារាងកម្មវិធីសកម្មភាពរយៈពេលខ្លី **ទិសដៅយុទ្ធសាស្ត្រទី ១**

**អាទិភាពកំណត់:**

១.១.៤ ការបញ្ចូលសិទ្ធិមនុស្ស និងពលរដ្ឋវិទ្យាទៅក្នុងកម្មវិធីសាលារៀន

១.២.២ ការស្ទង់មតិអំពីកម្មវិធីបណ្តុះបណ្តាលបច្ចុប្បន្នពីសិទ្ធិមូលដ្ឋានសម្រាប់ទីភ្នាក់ងារអនុវត្តច្បាប់ ដើម្បីរកឱ្យឃើញចន្លោះប្រហោង និងកន្លែងដែលត្រូវកែលំអ

១.២.៣ បង្កើតកម្មវិធី និងសម្ភារៈបណ្តុះបណ្តាល រួមទាំងការបង្កើតមុខវិជ្ជាសិទ្ធិមនុស្សនៅកម្រិតសាកលវិទ្យាល័យ សម្រាប់កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងបណ្តុះបណ្តាលបន្ត (ការបណ្តុះបណ្តាលដំណោះស្រាយបញ្ហា និងឯកទេស ចាំបាច់)

១.៤.៥ ពិនិត្យលទ្ធភាពធ្វើឱ្យប្រសើរឡើងនូវការរួមចំណែករបស់សង្គមស៊ីវិលក្នុងវិស័យច្បាប់ និងតុលាការ

១.៤.៦ ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ

| **ទិសដៅយុទ្ធសាស្ត្រ:** ពង្រឹងការការពារសិទ្ធិ និងសេរីភាពរបស់បុគ្គល | | | **លទ្ធផលរំពឹងទុក :** សិទ្ធិ និងសេរីភាពបុគ្គលត្រូវបានជំរុញ និងបង្កលក្ខណៈ | | |
|---|---|---|---|---|---|
| **សកម្មភាពជាអាទិភាព** | **ស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ** | **ស្ថាប័នដទៃទៀតដែលកំពុងមានការពាក់ព័ន្ធ** | **រយៈពេល** | **សកម្មភាពដែលត្រូវធ្វើ** | **សេចក្តីសង្កេតបន្ថែម** |
| ១.១ ផ្តល់ការបណ្តុះបណ្តាលហ្វឹកហ្វឺន និងកម្មវិធីយល់ដឹងអំពីសិទ្ធិមនុស្ស និងសិទ្ធិជាមូលដ្ឋាន រួមទាំងសិទ្ធិពលរដ្ឋជាមូលដ្ឋានជាបឋមនៅកម្រិតសហគមន៍ គ្រឹះស្ថាន សហគ្រាសដោយយកចិត្តទុកដាក់ ជាពិសេសទៅលើស្ត្រី កុមារ និងអ្នកបាត់បង់ឱកាស រួមទាំងការបង្កើន និងការយល់ដឹងអំពីការចុះបញ្ជីសិទ្ធិ និងយន្តការបណ្តឹង | | | | | |
| ១.១.៤ ការបញ្ចូលសិទ្ធិមនុស្ស/ពលរដ្ឋវិទ្យាទៅក្នុងកម្មវិធីសាលារៀន | ក្រ.អប់រំ<br>ក.ក.ច.ន.យ<br>ក្រ.យុត្តិធម៌ | OSJI | ២០០៤-២០០៥ | ១-កំណត់កម្មវិធីសមស្របមួយ ដែលបញ្ចូលបញ្ញត្តិទូទៅអំពីសិទ្ធិមនុស្ស និងច្បាប់ទៅក្នុងកម្មវិធីសិក្សាមធ្យមភូមិ<br>២-រៀបចំសម្ភារៈឧបទេ្ទសសម្រាប់គ្រូ និងសៀវភៅសិក្សាសម្រាប់សិស្ស<br>៣-បណ្តុះបណ្តាលគ្រូនូវខ្លឹមសារនៃកម្មវិធីសិក្សាថ្មីនេះ | ក្នុងក្របខ័ណ្ឌនៃការប្រជុំបន្តពីសិក្ខាសាលាថ្នាក់ជាតិ ស្តីពីកំណែទម្រង់ អ.គ.គ បានដឹកនាំកិច្ចប្រជុំដំបូង ជាមួយក្រ.អប់រំ និងស្ថាប័នអន្តរជាតិដែលយកចិត្តទុកដាក់គាំទ្រគំនិតនេះ |
| ១.២ ផ្តល់ការបណ្តុះបណ្តាលហ្វឹកហ្វឺន និងការយល់ដឹងដល់មន្ត្រីទាំងឡាយ នៅក្នុងទីភ្នាក់ងារអនុវត្តច្បាប់អំពីសិទ្ធិមូលដ្ឋាន រួមទាំងសិទ្ធិពលរដ្ឋជាមូលដ្ឋាន និងសិទ្ធិមនុស្សដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងសមត្ថភាពអនុវត្តស្តង់ដាអន្តរជាតិ នៅពេលគ្មានច្បាប់ជាតិ ឬក្នុងករណីវិធាន/ច្បាប់ មានខ្លឹមសារប្រឆាំងគ្នាទៅវិញទៅមក | | | | | |

| | | | | | |
|---|---|---|---|---|---|
| ១.២.២ ការស្ទង់មតិអំពីកម្មវិធីបណ្តុះបណ្តាលបច្ចុប្បន្នពីសិទ្ធិមូលដ្ឋានសម្រាប់ទីភ្នាក់ងារអនុវត្តច្បាប់ ដើម្បីរកឱ្យឃើញចន្លោះប្រហោង និងកន្លែងដែលត្រូវកែលំអ | ក.ក.ច.ន.យ<br>ក្រ.យុត្តិធម៌<br>ក្រ.មហាផ្ទៃ | Aus-Aid<br>Licadho<br>Adhoc<br>គណៈកម្មការអន្តរជាតិសិទ្ធិមនុស្ស<br>កាកបាទក្រហមកម្ពុជា | ២០០៤-២០០៥ | ១-បង្កើតក្រុមការងារបច្ចេកទេសកំណត់វិស័យធ្វើការស្ទង់មតិ<br>២- ធ្វើការស្ទង់មតិ<br>៣- អនុវត្តអនុសាសន៍ទទួលបានពីការស្ទង់មតិ | ការបណ្តុះបណ្តាលជាច្រើនត្រូវបានអនុវត្តទៅលើនគរបាល និងទាហានរួចហើយ ។ ការស្ទង់មតិធ្វើឡើងដើម្បីចៀសវាងការ ខាតបង់កម្លាំង និងការជាន់ការងារគ្មានគតប្រយោជន៍ ។ អង្គការ CDP ស្នើសុំចូលពាក់-ព័ន្ធក្នុងការស្ទង់មតិនេះដែរ ។ |
| ១.២.៣ បង្កើតកម្មវិធី និងសម្ភារៈបណ្តុះបណ្តាលរួមទាំងការបង្កើតមុខវិជ្ជាសិទ្ធិមនុស្សនៅកម្រិតសាកលវិទ្យាល័យសម្រាប់កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងបណ្តុះបណ្តាលបន្ត (ការបណ្តុះបណ្តាលដំណោះស្រាយបញ្ហា និងឯកទេសចាំបាច់) | ក្រ.អប់រំ<br>ក្រ.មហាផ្ទៃ<br>ក្រ.យុត្តិធម៌<br>សា.ចៅក្រម<br>មជ្ឈមណ្ឌល. មេធាវី | | ២០០៤-២០០៥ | ១-ផ្តួចផ្តើមកិច្ចពិភាក្សាជាបឋមរវាងស្ថាប័នពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធទាំងអស់ ហើយកៀងគរដៃគូដែលយកចិត្តទុកដាក់គាំទ្រគំនិតនេះ<br>២-អភិវឌ្ឍន៍កម្មវិធីសិក្សា និងសម្ភារៈបណ្តុះបណ្តាល និងអនុវត្តកម្មវិធីបណ្តុះបណ្តាលដែលកំពុងដំណើរការ | មុខវិជ្ជាសិទ្ធិមនុស្សបានបញ្ចូលរួចខ្លះហើយទៅក្នុងកម្មវិធីសិក្សានៃសាកលវិទ្យាល័យមួយចំនួន |
| ១.៤ អនុម័ត និងពិនិត្យឡើងវិញនូវច្បាប់ការពារសិទ្ធិរបស់បុគ្គលក្នុងការរៀបចំអង្គការ បង្កើតសមាគម សម្តែងមតិ និងសិទ្ធិទទួលបានព័ត៌មាន ធានាឱ្យប្រព័ន្ធផ្សព្វផ្សាយ ស្ថាប័នស្រាវជ្រាវ និងសង្គមស៊ីវិល អាចអនុវត្តការត្រួតពិនិត្យមើល ប្រកបដោយប្រសិទ្ធភាពលើរចនាសម្ព័ន្ធរបស់រដ្ឋ អាចធ្វើរបាយការណ៍អំពីបញ្ហានោះ រួមទាំងផ្តល់ជាគំនិតដល់ដំណើរការនយោបាយ និងផ្តល់ចំណេះដឹងដោយមន្ត្រីអនុវត្តច្បាប់ ដើម្បីការពារសិទ្ធិទាំងនេះ | | | | | |
| ១.៤.៥ ពិនិត្យលទ្ធភាពធ្វើឱ្យប្រសើរឡើងនូវការរួមចំណែករបស់សង្គមស៊ីវិលក្នុងវិស័យច្បាប់ និងតុលាការ | ទី.គ.មន្ត្រី<br>ក.ក.ច.ន.យ<br>គ្រប់ក្រសួងស្ថាប័ន | | ២០០៤-២០០៥ | បន្តធ្វើការសម្របសម្រួលជាមួយសង្គមស៊ីវិលលើគ្រប់ទិដ្ឋភាពទាំងអស់នៃវិស័យ ហើយជាពិសេសក្នុងទំនាក់ទំនងជាមួយដំណើរការកំណែទម្រង់ច្បាប់ និងតុលាការ និងបង្កើតមធ្យោបាយទំនាក់ទំនង តួយ៉ាង ព្រឹត្តិបត្រប្រចាំត្រីមាសអំពីភាពជឿនលឿននៃដំណើរការកំណែទម្រង់ជាដើម | |

| | | | | | |
|---|---|---|---|---|---|
| ១.៤.៦ ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ | ក្រ.កិច្ចការនារី<br>ក.ក.ច.ន.យ<br>ក្រ.យុត្តិធម៌<br>រដ្ឋសភា<br>ព្រឹទ្ធសភា | GTZ | ២០០៤-២០០៥ | ១- ត្រួតពិនិត្យឡើងវិញនូវសេចក្តីព្រាងច្បាប់បច្ចុប្បន្ន ដើម្បីធានាការស៊ីសង្វាក់គ្នាជាមួយស្តង់ដារអន្តរជាតិ និងគោលដៅសហវត្សដែលកំណត់ដោយរាជរដ្ឋាភិបាល<br>២- អនុម័តច្បាប់នេះហើយ បញ្ជូនទៅរដ្ឋសភាវិញ | |

២.១.២ ព្រាង អនុម័ត និងអនុវត្តក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី (ដំណាក់កាលទី១)

២.១.៣ ព្រាង អនុម័ត និងអនុវត្តក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ (ដំណាក់កាលទី១)

២.១.៤ ច្បាប់អង្គការស្តីពីការរៀបចំតុលាការ (ដំណាក់កាលទី១)

២.១.៩ ការធ្វើវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

២.១.១០ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម (ដំណាក់កាលទី១)

២.២.២ ការអនុវត្តកម្មវិធីកំណែទម្រង់ច្បាប់តាមផ្នែក(បញ្ជីមេ រួមទាំងច្បាប់តម្រូវដោយអង្គការពាណិជ្ជកម្មពិភពលោក)

២.២.៤ រៀបចំបញ្ជីច្បាប់ដែលមិនទាន់អនុម័ត រួមទាំងរយៈពេលសម្រាប់បញ្ចប់ និងការត្រួតពិនិត្យតាមដានការជឿនលឿន

២.៣.១ ច្បាប់/នីតិវិធី/សេចក្តីណែនាំសម្រាប់ការធ្វើច្បាប់ ដោយផ្តោតជាពិសេសទៅលើការធានានូវការចូលរួម និងតម្លាភាព

២.៤.១ ច្បាប់ស្តីពីលទ្ធភាពទទួលបាននូវព័ត៌មាន និងបទប្បញ្ញត្តិនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ព្រហ្មទណ្ឌ និងរដ្ឋបាល ដើម្បីធានាលទ្ធភាពទទួលបាននូវព័ត៌មានដល់សាធារណជន

| **និសដៅវាយុទ្ធសាស្ត្រ:** ទំនើបកម្មក្របខ័ណ្ឌច្បាប់ | | **លទ្ធផលរំពឹងទុក:** ដំណើរការធ្វើច្បាប់ និងក្របខ័ណ្ឌច្បាប់ ត្រូវបានធ្វើទំនើបកម្ម ក្នុងគោលបំណងអនុវត្តនីតិរដ្ឋ ផ្អែកលើប្រព័ន្ធឋានានុក្រមនៃច្បាប់ | | | |
|---|---|---|---|---|---|
| **សកម្មភាពជាអាទិភាព** | **ស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ** | **ស្ថាប័នដទៃទៀតដែលកំពុងមានការពាក់ព័ន្ធ** | **រយៈពេល** | **សកម្មភាពដែលត្រូវធ្វើ** | **សេចក្តីសង្កេតបន្ថែម** |
| ២.១ បង្កើតក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធវិស័យច្បាប់ និងតុលាការ រួមទាំងច្បាប់អង្គការ សម្រាប់ស្ថាប័នវិសយ័ច្បាប់ និងតុលាការ ដែលរដ្ឋធម្មនុញ្ញតម្រូវឱ្យធ្វើ ហើយនិងអនុវត្តការចែកមុខងារដាច់ពីគ្នារវាងអំណាចនានា | | | | | |
| ២.១.២ ព្រាង អនុម័ត និងអនុវត្តក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី | ក្រ.យុត្តិធម៌<br>ក្រុ.អ្នកច្បាប់<br>ក.ក.ច.ន.យ<br>ទី.គ.មន្ត្រី<br>រដ្ឋសភា<br>ព្រឹទ្ធសភា<br>ស.នីតិសាស្ត្រ<br>មជ្ឈមណ្ឌល.មេធាវី | JICA | ដំណាក់កាលទី ១<br>២០០៤-២០០៥<br><br>(ដំណាក់កាលទី ២ : សូមអានកម្មវិធីរយៈពេលមធ្យម) | ១- ព្រាងក្រមទាំងពីរដោយគិតគូរ ជាពិសេសទៅលើភាពស៊ីសង្វាក់គ្នា<br>២-បណ្តុះបណ្តាលមន្ត្រី ក្រ.យុត្តិធម៌ អំពីខ្លឹមសារច្បាប់<br>៣-ពិនិត្យ និងបញ្ជូនសេចក្តីព្រាងក្រមទៅរដ្ឋសភា | គម្រោងបានឈានទៅមុខយ៉ាងល្អជាមួយនឹងកិច្ចព្រមព្រៀង (ដំណាក់កាលទី ២ ) ដែលត្រូវបានចុះហត្ថលេខារវាងរដ្ឋាភិបាលកម្ពុជា និងរាជរដ្ឋាភិបាលជប៉ុន កាលពីខែមីនា ឆ្នាំ២០០៤ |

| | | | | | |
|---|---|---|---|---|---|
| ២.១.៣ ព្រាង អនុម័ត និងអនុវត្តក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ | ក្រ.យុត្តិធម៌<br>ក្រុ.អ្នកច្បាប់<br>ក.ក.ច.ន.យ<br>ទី.គ.មន្ត្រី<br>រដ្ឋសភា<br>ព្រឹទ្ធសភា<br>ស.នីតិសាស្ត្រ<br>មជ្ឈមណ្ឌល-មេធាវី | ប្រទេសបារាំង | ដំណាក់កាលទី ១<br>២០០៤-២០០៥<br><br>(ដំណាក់កាលទី ២ : សូមអានកម្មវិធីរយៈពេលមធ្យម) | ១- ព្រាងក្រមទាំងពីរដោយគិតគូរជាពិសេសទៅលើភាពស៊ីសង្វាក់ ចែកចាយក្រមដើម្បីសុំយោបល់<br>២-បណ្តុះបណ្តាលមន្ត្រីក្រសួងយុត្តិធម៌ អំពីខ្លឹមសារច្បាប់<br>៣-ពិនិត្យ និងបញ្ជូនសេចក្តីព្រាងក្រមទៅរដ្ឋ-សភា | សេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមព្រហ្មទណ្ឌត្រូវបានក្រុមប្រឹក្សាអ្នកច្បាប់បញ្ជូនទៅអគ្គលេខាធិការរាជ-រដ្ឋាភិបាលពីខែសីហា ឆ្នាំ២០០៤ រួចហើយ |
| ២.១.៤ ច្បាប់អង្គការស្តីពីការរៀបចំតុលាការ | ក្រ.យុត្តិធម៌<br>ឧត្តម.ចៅក្រម<br>ទី.គ.មន្ត្រី<br>ក.ក.ច.ន.យ<br>រដ្ឋសភា<br>ព្រឹទ្ធសភា<br>សា.ចៅក្រម<br>ស.នីតិសាស្ត្រ<br>មជ្ឈមណ្ឌល.មេធាវី | | ដំណាក់កាលទី ១<br>២០០៤-២០០៥<br>(ដំណាក់កាលទី ២ : សូមអានកម្មវិធីរយៈពេលមធ្យម) | ពិនិត្យដោះស្រាយកង្វល់ចុងក្រោយនានា រួមទាំងការពិនិត្យសេចក្តីព្រាងឡើងវិញ មុននឹងដាក់ជូនរដ្ឋសភា | ការតាក់តែងច្បាប់នេះ និងច្បាប់សំខាន់៧ពាក់ព័ន្ធ ដែលកំណត់ពីយុត្តាធិការ និងការទទួលខុសត្រូវនៃវិស័យតុលា-ការ គួរតែធ្វើជាកញ្ចប់តែមួយ |
| ២.១.៥ ការធ្វើវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម | ឧត្តម.ចៅក្រម<br>ក្រ.យុត្តិធម៌<br>ក.ក.ច.ន.យ<br>រដ្ឋសភា<br>ព្រឹទ្ធសភា | | ២០០៤-២០០៥ | ១-ធ្វើសេចក្តីសម្រេចចិត្តលើកង្វល់ចុងក្រោយនានា(សមាជិកភាព យុត្តាធិការ) មុននឹងដាក់ជូនរដ្ឋសភា<br>២-រៀបចំបទបញ្ជាផ្ទៃក្នុង<br>៣-ពង្រឹងស្ថាប័ន និងលេខាធិការដ្ឋានទៅតាមខ្លឹមសារនៃច្បាប់ថ្មី(សូមអានទិសដៅលេខ៥) | សេចក្តីព្រាងបានស្នើជូនរដ្ឋសភាកាលពីខែមេសា ឆ្នាំ២០០៣ ហើយមិនទាន់បានទទួលការអនុម័តនៅឡើយទេ សេចក្តីព្រាងគួរពិនិត្យឡើងវិញដោយក្រុមការងារដែលពិនិត្យសេចក្តីព្រាងច្បាប់វិសោធនកម្ម |

| | | | | | |
|---|---|---|---|---|---|
| | | | | | ច្បាប់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងច្បាប់អង្គការតុលាការ ។ |
| ២.១.១០ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម | ក្រ.យុត្តិធម៌<br>ឧត្តម.ចៅក្រម<br>ក.ក.ច.ន.យ<br>រដ្ឋសភា<br>ព្រឹទ្ធសភា<br>ស.នីតិសាស្ត្រ<br>មជ្ឈមណ្ឌល.មេធាវី | | ដំណាក់កាលទី ១<br>២០០៤-២០០៥<br><br>( ដំណាក់កាលទី ២ : សូមអានកម្មវិធីរយៈពេលមធ្យម ) | ធ្វើសេចក្តីសម្រេចចិត្តលើកង្វល់ចុងក្រោយនានាមុននឹងដាក់ជូនរដ្ឋសភា ជាពិសេសឱ្យស្របជាមួយនឹងស្តង់ដាអន្តរជាតិអំពីឯករាជ្យភាពនៃតុលាការ និងឱ្យស៊ីសង្វាក់គ្នាជាមួយច្បាប់ជាមូលដ្ឋានផ្សេងៗទៀត | ក្រសួងយុត្តិធម៌ស្នើឱ្យមានលក្ខន្តិកៈមួយសំរាប់ចៅក្រម និងមួយទៀតសំរាប់ព្រះរាជ-អាជ្ញា<br><br>សេចក្តីព្រាងគួរពិនិត្យឡើងវិញដោយក្រុមការងារដែលពិនិត្យសេចក្តីព្រាងច្បាប់វិសោធនកម្មច្បាប់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងច្បាប់អង្គការតុលាការ ។<br><br>សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម គួរមានចែងអំពីចៅក្រម និងព្រះរាជអាជ្ញាដែលបម្រើការជាគ្រូ និងជាចៅក្រមនៅសាលាភូមិន្ទចៅក្រម |

| | | | | | |
|---|---|---|---|---|---|
| ២.២ បញ្ចប់ច្បាប់ដែលធ្វើមិនទាន់រួច និងដោយប្រើវិធីសាស្ត្រនៃការចូលរួម និងតាមការសិក្សាតាមផ្នែក កំណត់នូវចន្លោះប្រហោងក្នុងក្របខ័ណ្ឌច្បាប់ ហើយបំពេញចន្លោះប្រហោងនោះក្នុងគាលបំណងអនុវត្តនីតិរដ្ឋ | | | | | |
| ២.២.២ ការអនុវត្តកម្មវិធីកំណែទម្រង់ច្បាប់តាមផ្នែក (បញ្ជីមេ រួមទាំងច្បាប់តម្រូវដោយអង្គការពាណិជ្ជកម្មពិភពលោក)<br>+<br>២.២.៤ រៀបចំបញ្ជីច្បាប់ដែលមិនទាន់អនុម័ត រួមទាំងរយៈពេលសម្រាប់បញ្ចប់ និងការត្រួតពិនិត្យតាមដានការ-ជឿនលឿន | ទី.គ.មន្ត្រី<br>ក.ក.ច.ន.យ<br>ក្រ.យុត្តិធម៌<br>អគ្គនាយកដ្ឋានរាជកិច្ច<br>ក្រសួង និងរដ្ឋលេខា-ធិការដ្ឋានទាំងអស់<br>រដ្ឋសភា<br>ព្រឹទ្ធសភា | ADB<br>WB<br>IMF<br>JICA<br>FRANCE | ២០០៤-២០០៥ | ១-រៀបចំបញ្ជីមេនៃច្បាប់ក្នុងក្របខ័ណ្ឌកំណែទម្រង់ច្បាប់ដោយមានអនុផ្នែកទៅតាមច្បាប់ជាអាទិភាព តាមវិស័យ តាមប្រធានបទ និងច្បាប់ដែលមិនទាន់បានអនុម័ត<br>២- ពង្រឹងយន្តការត្រួតពិនិត្យដែលមានស្រាប់ ដើម្បីអនុវត្តបញ្ជីមេជាផ្លូវការ រួមទាំងការធ្វើរបាយការណ៍ប្រចាំត្រីមាស ស្តីពីភាពជឿនលឿនជូនដល់អ្នកពាក់ព័ន្ធទាំងអស់ | បញ្ជីមេអាចជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍ ឬការបញ្ចូលទៅក្នុងបណ្ណាល័យអេឡិចត្រូនិច និងជួយសម្រួលដល់ការចូលរួម ស្ថាបនារបស់សង្គមស៊ីវិល តាមការកំណត់។<br>អ.គ.គ កំពុងតែអភិវឌ្ឍបញ្ជីច្បាប់ដែលមិនទាន់អនុម័តដែលនឹងត្រូវបញ្ចូលទៅក្នុងបញ្ជីមេ ។ |
| ២.៣ ផ្តល់នូវដំណើរការធ្វើច្បាប់មួយមានប្រសិទ្ធភាព ស៊ីសង្វាក់គ្នា និងមានការចូលរួមផ្នែកលើឋានានុក្រមនៃច្បាប់ ដោយមានសេចក្តីណែនាំជាក់លាក់អំពីការធ្វើច្បាប់ និងមានបទដ្ឋានអំពីការពិនិត្យឡើងវិញផ្នែកបច្ចេកទេស រួមទាំងការយកចិត្តទុកដាក់ការអនុវត្តស្តង់ដាអន្តរជាតិ និងពង្រឹងអង្គភាពនានា ដែលពាក់ព័ន្ធ នៅក្នុងការអនុម័តច្បាប់ថ្មីៗ និងការធ្វើវិសោធនកម្មច្បាប់ ព្រមទាំងផ្តល់នូវការបណ្តុះបណ្តាលអំពីការព្រាងច្បាប់ដល់មន្ត្រីពាក់ព័ន្ធនៅក្នុងសកម្មភាពនេះ នៅក្នុងជួររដ្ឋាភិបាលទាំងមូល | | | | | |

| | | | | | |
|---|---|---|---|---|---|
| ២.៣.១ ច្បាប់/នីតិវិធី/សេចក្តីណែនាំសម្រាប់ការធ្វើច្បាប់ ដោយផ្តោតជាពិសេសទៅលើការធានានូវការចូលរួម និង តម្លាភាព | ទី.គ.មន្ត្រី<br>ក្រសួងនានា | KAF<br>UNDP | ២០០៤- ២០០៥ | ១-បង្កើតក្រុមការងារ ដើម្បីធ្វើឱ្យកាន់តែប្រសើរឡើងនូវគោលនយោបាយ និងដំណើរការតាក់តែងច្បាប់<br>២-រៀបចំសៀវភៅក្បួនសម្រាប់ប្រើប្រាស់ក្នុងសេវាសាធារណៈ និងរដ្ឋបាលស្តីពីការអភិវឌ្ឍគោលនយោបាយ និងការធ្វើច្បាប់ ដោយសង្កត់ទៅលើការចូលរួមដ៏ទូលំទូលាយ ក្នុងការអភិវឌ្ឍគោលនយោបាយ ការធ្វើឱ្យប្រសើរឡើងនូវភាពស៊ីសង្វាក់គ្នាក្នុងការព្រាងច្បាប់ និងការរៀបរយនូវដំណើរការធ្វើច្បាប់ | ក្រុមការងារបានបង្កើតរួចហើយ ហើយជួបជុំគ្នាជាមូល-ដ្ឋានមួយដងក្នុងមួយសប្តាហ៍ ដើម្បីអភិវឌ្ឍរៀបចំមគ្គុទេសក៍មួយសម្រាប់ធ្វើច្បាប់ឱ្យឯក-ភាពគ្នា ។ KAF និង UNDP បានរៀបចំកម្មវិធីបណ្តុះបណ្តាលស្តីពីការធ្វើច្បាប់នេះជូនសមាជិកសភា និងស្ថាប័នពាក់ព័ន្ធដទៃទៀត |
| ២.៤ អត្ថិភាពច្បាប់ធានាឱ្យដំណើរការតុលាការ ក៏ដូចជាព័ត៌មានអំពីរដ្ឋបាលគ្រប់គ្រងបានជ្រួតជ្រាបជាសាធារណៈ លើកលែងតែមានច្បាប់ចែងច្បាស់លាស់អំពីអញ្ញត្រកម្ម | | | | | |
| ២.៤.១ ច្បាប់ស្តីពីលទ្ធភាពទទួលបាននូវព័ត៌មាន និងបទប្បញ្ញត្តិនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ព្រហ្មទណ្ឌ និងរដ្ឋបាល ដើម្បីធានាលទ្ធភាពទទួលបាននូវព័ត៌មានដល់សាធារណជន | ក្រ.យុត្តិធម៌<br>ក្រ.មហាផ្ទៃ<br>ទី.គ.មន្ត្រី<br>ក.ក.ច.ន.យ<br>គ្រប់ក្រសួង-ស្ថាប័ន | JICA<br>France | ២០០៤-២០០៦ | ១-បង្កើតក្រុមការងារបច្ចេកទេស ដើម្បីព្រាងច្បាប់មួយដែលធានាការស្របគ្នាជាមួយស្តង់ដាអន្តរជាតិ ហើយនិងស៊ីសង្វាក់គ្នា ជាមួយច្បាប់ពាក់ព័ន្ធដទៃទៀត<br>២-រៀបចំអភិវឌ្ឍសេចក្តីណែនាំស្តីពីលទ្ធភាពទទួលបានព័ត៌មានពីរបៀបរបបតុលាការ និងការគ្រប់គ្រងរដ្ឋបាល រួមទាំងចំណាយសាធារណៈ<br>៣-បង្កើតការិយាល័យទទួលសាធារណជន នៅសាលាជំរះក្តី និងស្ថាប័នយុត្តិធម៌ដទៃទៀត ។ | បទប្បញ្ញត្តិអំពីលទ្ធភាពទទួលបានព័ត៌មាន មិនចាំបាច់សរសេរនៅក្នុងក្រមទេ ប្រសិនបើមានច្បាប់មួយដោយឡែក ។ |

## អាទិភាពកំណត់:

៣.១.៣ ការធ្វើឱ្យមានការបោះពុម្ពផ្សាយជាទៀងទាត់ និងជាលក្ខណៈស្ថាប័ននូវរាជកិច្ច និងទិន្នន័យព័ត៌មានច្បាប់

៣.២.២ ការប្រមូល និងការបោះពុម្ពសេចក្ដីសម្រេចរបស់តុលាការកំពូល និងសេចក្ដីសម្រេចជាស្ថាពរនៃតុលាការផ្សេងទៀត

| **ទិសដៅយុទ្ធសាស្ត្រ:** ផ្ដល់លទ្ធភាពឱ្យទទួលបានព័ត៌មានអំពីច្បាប់ និងតុលាការ ឱ្យកាន់តែប្រសើរឡើង | | | **លទ្ធផលរំពឹងទុក:** ការយល់ដឹងជាសាធារណៈត្រូវបានលើកកម្ពស់ ហើយចំណេះដឹង និងលទ្ធភាពទទួលបានព័ត៌មានច្បាប់ និងយុត្តិធម៌កាន់តែប្រសើរ | | |
|---|---|---|---|---|---|
| **សកម្មភាពជាអាទិភាព** | **ស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ** | **ស្ថាប័នដទៃទៀតដែលកំពុងមានការពាក់ព័ន្ធ** | **រយៈពេល** | **សកម្មភាពដែលត្រូវធ្វើ** | **សេចក្ដីសង្កេតបន្ថែម** |
| ៣.១ បោះពុម្ពច្បាប់ទាំងឡាយដែលមាន និងនីតិកម្មពាក់ព័ន្ធទាំងអស់រួមទាំងសេចក្ដីណែនាំ និងទម្លាប់អនុវត្តជាភាសាខ្មែរ បោះពុម្ពច្បាប់ថ្មី និងនីតិកម្មពាក់ព័ន្ធទាំងអស់ជាផ្លូវការឱ្យទាន់ពេលវេលា និងសព្វគ្រប់ ឧទាហរណ៍ រាជកិច្ច សម្រាប់សេចក្ដីត្រូវការនៃចៅក្រម មេធាវី និស្សិតច្បាប់ មន្ត្រីរដ្ឋាភិបាល វិស័យឯកជន សង្គមស៊ីវិល និងភាគីមានផលប្រយោជន៍ដទៃទៀត | | | | | |
| ៣.១.៣ ការធ្វើឱ្យមានការបោះពុម្ពផ្សាយជាទៀងទាត់ និងជាលក្ខណៈស្ថាប័ននូវរាជកិច្ច និងទិន្នន័យព័ត៌មានច្បាប់ | ទី.គ.មន្ត្រី<br>អគ្គនាយកដ្ឋានរាជកិច្ច<br>ក.ក.ច.ន.យ<br>ក្រសួងនានា និង<br>ស្ថាប័នរដ្ឋាភិបាល | UNDP | ២០០៤-២០០៥ | ធ្វើការសិក្សារិះរកធ្វើឱ្យការផ្សព្វផ្សាយបច្ចុប្បន្ន បានប្រសើរឡើង និងកៀងគររកជំនួយសម្រាប់អនុវត្តអនុសាសន៍បានមកពីការសិក្សា (ការប្រមូលព័ត៌មានខ្លឹមសារ ការគ្រប់គ្រង ការត្រួតពិនិត្យយន្តការ ចែកចាយ មូលនិធិ បរិក្ខារចាំបាច់ ផែនការកម្ម ចីរភាព) | UNDP សិក្សាស្រាវជ្រាវនេះរួចហើយចំនួន ៣ សប្ដាហ៍ កាលពី ថ្ងៃទី២៨/០៦-១៦/០៧/២០០៣។ រាជរដ្ឋាភិបាលបានតម្លើងនាយកដ្ឋានរាជកិច្ចឱ្យទៅជាអគ្គនាយកដ្ឋាន និងបំពាក់បន្ថែមនូវធនធានមនុស្ស និងសម្ភារៈ។ |

| ៣.២ បោះពុម្ពសាលក្រមដែលមាន និងផលិតព្រឹត្តិបត្រសង្ខេបរឿងក្តី សម្រាប់បោះពុម្ព និងផ្សព្វផ្សាយសាលក្រម សេចក្តីសម្រេច និងវិធានផ្សេងៗរបស់តុលាការ និងធានាឱ្យសាលក្រមតុលាការ អាចរកបាននៅពេលមានការស្នើសុំ | | | | | |
|---|---|---|---|---|---|
| ៣.២.២ ការប្រមូល និងការបោះពុម្ពសេចក្តីសម្រេចរបស់តុលាការតុលាការកំពូល និងសេចក្តីសម្រេចជាស្ថាពរនៃតុលាការផ្សេងទៀត | តុលាការកំពូល<br>ឧត្តម.ចៅក្រម<br>ក្រ.យុត្តិធម៌<br>សាលាជំរះក្តី<br>សា.ចៅក្រម<br>មជ្ឈមណ្ឌល.មេធាវី | ប្រទេសបារាំង<br>UNDP | ២០០៤-២០០៥ | ១-រចនាវិធីសាស្ត្រឯកភាពគ្នាមួយ ដើម្បីប្រមូល និងបោះពុម្ពសាលក្រមតុលាការ-កំពូលនិងសាលក្រមស្ថាពរនៃតុលាការផ្សេងទៀត និងធ្វើការផ្សព្វផ្សាយជាសាធារណៈ<br>២- បញ្ចូលមុខវិជ្ជាសរសេរសេចក្តីសម្រេចរបស់តុលាការទៅក្នុងកម្មវិធីសិក្សាសាលាភូមិន្ទចៅក្រម<br>៣-បង្កើតយន្តការតាមដាននៅក្នុងឧត្តម-ក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីពិនិត្យការអនុវត្ត និងជួយឱ្យការសរសេរសេចក្តីសម្រេចបានប្រសើរ<br>៤-រៀបចំកម្មវិធីបណ្តុះបណ្តាលបន្តសម្រាប់ចៅក្រមក្នុងតំណែង | មុខវិជ្ជាអំពីការសរសេរសេចក្តីសម្រេចត្រូវបានបញ្ចូលទៅក្នុងកម្មវិធីសិក្សានៃសាលា-ភូមិន្ទចៅក្រមរួចហើយ ការផ្សព្វផ្សាយនូវសេចក្តីសម្រេចគួរចាប់ផ្តើមពីតុលាការកំពូលនិងសាលាឧទ្ធរណ៍ និងតុលាការខេត្ត-ក្រុង ដែលមានរឿងក្តីច្រើន ហើយជាបន្តបន្ទាប់ទៅតុលាការទាំងអស់តែម្តង។<br>UNDP បានសន្យាជួយតុលា-ការកំពូលនេះរួចហើយ<br>មុខវិជ្ជាអំពីការវិភាគសេចក្តី-សម្រេចរបស់តុលាការ គួរតែបញ្ចូលទៅក្នុងកម្មវិធីសិក្សានៅតាមមហាវិទ្យាល័យច្បាប់នានា ។ |

**អាទិភាពកំណត់:**

៤.១.១ គោលនយោបាយ និងលិខិតបទដ្ឋានស្តីពីតំណាងផ្នែកច្បាប់ និងជំនួយផ្នែកច្បាប់ រួមទាំងការធានានូវសេរីភាពរបស់អង្គការមិនមែនរដ្ឋាភិបាលដើម្បីផ្តល់ជំនួយផ្នែកច្បាប់ (ដំណាក់កាលទី១)
៤.១.២ ធ្វើការស្ទង់មតិអំពីលទ្ធភាព និងសេចក្តីត្រូវការសម្រាប់ជំនួយផ្នែកច្បាប់ ឈរលើទស្សនៈដើម្បីបំពេញចន្លោះប្រហោង
៤.២.១ ការពិនិត្យឡើងវិញលើច្បាប់ស្តីពីលក្ខន្តិកៈមេធាវី និងការសម្រួលនីតិវិធីរួមទាំងលក្ខណៈវិនិច្ឆ័យមានតម្លាភាព ដើម្បីចូលជាសមាជិកគណៈមេធាវី
៤.២.២ ការធានាឱ្យមានមជ្ឈមណ្ឌលមានដំណើរការល្អប្រសើរសម្រាប់បណ្តុះបណ្តាលមេធាវី ដោយផ្តល់នូវការបណ្តុះបណ្តាលមូលដ្ឋាន ឯកទេស និងដំណោះស្រាយបញ្ហាដល់មេធាវីទាំងអស់

| **ទិសដៅយុទ្ធសាស្ត្រ:** ធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃដំណើររឿងក្តីនិងសេវាពាក់ព័ន្ធ | | **លទ្ធផលរំពឹងទុក:** ដំណើរការត្រឹមត្រូវចំពោះមុខស្ថាប័នរដ្ឋបាល និងតុលាការ និងសិទ្ធិនៃការប្តឹងតវ៉ារបស់ជនគ្រប់រូបត្រូវបានធានា | | | |
|---|---|---|---|---|---|
| **សកម្មភាពជាអាទិភាព** | **ស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ** | **ស្ថាប័នដទៃទៀតដែលកំពុងមានការពាក់ព័ន្ធ** | **រយៈពេល** | **សកម្មភាពដែលត្រូវធ្វើ** | **សេចក្តីសង្កេតបន្ថែម** |
| ៤.១ ផ្តល់សេវាកម្មជំនួយផ្នែកច្បាប់ មានគុណភាពខ្ពស់ ងាយរក ស្របទៅតាមសេចក្តីត្រូវការរបស់ពលរដ្ឋ | | | | | |
| ៤.១.១ គោលនយោបាយ និងលិខិតបទដ្ឋានស្តីពីតំណាងផ្នែកច្បាប់ និងជំនួយផ្នែកច្បាប់ រួមទាំងការធានានូវសេរីភាពរបស់អង្គការមិនមែនរដ្ឋាភិបាល ដើម្បីផ្តល់ជំនួយផ្នែកច្បាប់<br>+<br>៤.១.២ ធ្វើការស្ទង់មតិអំពីលទ្ធភាព និងសេចក្តីត្រូវការសម្រាប់ជំនួយផ្នែកច្បាប់ ដើម្បីបំពេញចន្លោះប្រហោង | ក្រ.យុត្តិធម៌<br>ក.ក.ច.ន.យ<br>គណៈរដ្ឋមន្ត្រី<br>ក្រ.មហាផ្ទៃ<br>គណៈមេធាវី<br>មជ្ឈមណ្ឌល.មេធាវី | ប្រទេសបារាំង<br>ប្រទេសជប៉ុន<br>CDP<br>LAC<br>BAC<br>EWMI<br>Licadho<br>Adhoc<br>Other NGO$_s$ | ដំណាក់កាលទី ១<br>២០០៤-២០០៥<br><br>(ដំណាក់កាលទី ២: សូមអានកម្មវិធីរយៈពេលមធ្យម) | បង្កើតក្រុមសម្របសម្រួលមួយ ដើម្បីសិក្សារៀបចំ និងអនុវត្តការស្ទង់មតិមួយលើលទ្ធភាព និងសេចក្តីត្រូវការបច្ចុប្បន្នផ្នែកជំនួយច្បាប់ ។ ការស្ទង់មតិត្រូវយកចិត្តទុកដាក់ចំពោះបញ្ហាភូមិសាស្ត្រ ភាសា និងវប្បធម៌របស់ប្រជាជន ។ | ការស្ទង់មតិគួរធ្វើនៅដើមឆ្នាំ ២០០៥ និង មានការសម្របសម្រួលជាមួយអង្គការជំនួយផ្នែកច្បាប់នានា។<br>CDP បានសម្តែងការគាំទ្រចំពោះគំនិតផ្តួចផ្តើមនេះ។ |

| | | | | | |
|---|---|---|---|---|---|
| ៤.២ បង្កើនចំនួនមេធាវី យោងតាមលក្ខណៈវិនិច្ឆ័យ ដែលរៀបចំសម្រាប់ផ្តល់យោបល់ផ្នែកច្បាប់ និងសេវាដទៃទៀតដល់អ្នកមានវិវាទ និងកូនក្តីដទៃទៀត សម្រាប់ប្រជាពលរដ្ឋទាំងអស់ក្នុងប្រទេស និងជនបរទេសដែលពាក់ព័ន្ធ ឬកំពុងតែពាក់ព័ន្ធនៅកម្ពុជា រួមមានការផ្តល់ការបណ្តុះបណ្តាលសមស្របដល់និស្សិតច្បាប់ កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈបន្ត ដើម្បីធានាឱ្យការផ្តល់យោបល់ជូនអតិថិជននូវជំនួយផ្នែកច្បាប់មានគុណភាពខ្ពស់តាមការដែលអាចធ្វើទៅបាន | | | | | |
| ៤.២.១ ការពិនិត្យឡើងវិញលើច្បាប់ស្តីពីលក្ខន្តិកៈមេធាវី និងការសម្រួលនីតិវិធី រួមទាំងលក្ខណៈវិនិច្ឆ័យមានតម្លាភាព ដើម្បីចូលជាសមាជិកគណៈមេធាវី | ក្រ.យុត្តិធម៌<br>ទី.គ.មន្ត្រី<br>គណៈមេធាវី<br>ស.នីតិសាស្ត្រ<br>ក.ក.ច.ន.យ<br>រដ្ឋសភា<br>ព្រឹទ្ធសភា | | ២០០៤-២០០៥ | ផ្តួចផ្តើមរៀបចំធ្វើវិសោធនកម្មលើច្បាប់ស្តីពីគណៈមេធាវី | អ្នកផ្តល់ជំនួយរួមមានអង្គការជំនួយផ្នែកច្បាប់ គប្បីចូលរួមក្នុងការត្រួតពិនិត្យឡើងវិញនូវច្បាប់នេះ។ |
| ៤.២.២ ការធានាឱ្យមានមជ្ឈមណ្ឌលដែលមានដំណើរការល្អប្រសើរសម្រាប់បណ្តុះបណ្តាលមេធាវី ដោយផ្តល់នូវការបណ្តុះបណ្តាលមូលដ្ឋាន ឯកទេស និងដំណោះស្រាយបញ្ហាដល់មេធាវីទាំងអស់ | គណៈមេធាវី<br>ក្រ.យុត្តិធម៌<br>មជ្ឈមណ្ឌល.មេធាវី<br>ឧត្តម.ចៅក្រម | JFBA<br>ABA<br>CBA<br>France<br>Aus-Aid<br>Asia Foundation | ២០០៤-២០០៦ | ១- បណ្តុះបណ្តាលមុខវិជ្ជាឯកទេសដល់មេធាវីទាំងអស់ រួមទាំងបណ្តុះ-បណ្តាលវិជ្ជាជីវៈបន្ត<br>២- ជ្រើសរើសមេធាវីឱ្យបានច្រើនស្របតាមលក្ខណៈវិនិច្ឆ័យកំណត់ | |

**អាទិភាពកំណត់៖**

៥.២.២ លក្ខន្តិកៈចៅក្រម និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលមានដំណើរការយ៉ាងពេញលេញ ដែលធានានូវតម្លាភាពក្នុងការតែងតាំង ការតម្លើងស័ក្តិ ប្រាក់បៀវត្ស និងការដាក់វិន័យចៅក្រម និងព្រះរាជអាជ្ញា(ដំណាក់កាលទី១)

៥.២.៤ រៀបចំក្រមសីលធមិសម្រាប់ចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីយុត្តិធមិ (ដំណាក់កាលទី ១)

៥.២.៦ វិធានការប្រឆាំងអំពើពុករលួយ រួមទាំងច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយ

៥.៣.២ វិធីសាស្ត្របង្កើតតុលាការគំរូ (ជាចង្កោមជាមួយសកម្មភាពលេខ ៥.៣.៣ និង ៥.៤.៣)

៥.៤.២ សាលាចៅក្រមនិងសាលាសម្រាប់មន្ត្រីយុត្តិធមិ រួមទាំងកម្មវិធីបណ្តុះបណ្តាលបន្តសម្រាប់អ្នកមានតួនាទីទាំងអស់ (ការបណ្តុះបណ្តាលមូលដ្ឋាន ឯកទេស និងដំណោះស្រាយបញ្ហា) ស្របទៅតាមសេចក្តីត្រូវការ

៥.៤.៤ វិធានការបង្កើតតុលាការ/សភាពាណិជ្ជកម្ម និងតុលាការ/សភាឯកទេសផ្សេងៗ រួមទាំងបែបបទតុលាការពាណិជ្ជកម្ម និងការបណ្តុះបណ្តាលអ្នកឯកទេសផ្នែកច្បាប់ពាណិជ្ជកម្ម

៥.៤.៥ វិធានាការបង្កើតតុលាការរដ្ឋបាល (ដំណាក់កាលទី ១)

៥.៥.១ ការស្ទង់មតិលើយន្តការអនុវត្តន៍ច្បាប់បច្ចុប្បន្ន ដើម្បីរកឱ្យឃើញចំណុចកែលំអ

| **ទិសដៅយុទ្ធសាស្ត្រ៖** ពង្រឹងសេវាកម្មយុត្តិធមិ រួមមានអំណាចតុលាការ និងសេវាកម្មអយ្យការ | | **លទ្ធផលរំពឹងទុក ៖** តុលាការឯករាជ្យ និងមានដំណើរការល្អប្រសើរត្រូវបានធានា | | | |
|---|---|---|---|---|---|
| **សកម្មភាពជាអាទិភាព** | **ស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ** | **ស្ថាប័នដទៃទៀតដែលកំពុងមានការពាក់ព័ន្ធ** | **រយៈពេល** | **សកម្មភាពដែលត្រូវធ្វើ** | **សេចក្តីសង្កេតបន្ថែម** |
| ៥.២ បង្កើតការទទួលខុសត្រូវ ដោយធានាឱ្យមានលទ្ធភាពទទួលបាននូវការវិនិច្ឆ័យត្រឹមត្រូវ យោងទៅតាមច្បាប់ពាក់ព័ន្ធអាចប្តឹងតវ៉ាបាន និងមានប្រព័ន្ធមួយ មានតម្លាភាពស្តីពីការតែងតាំងតម្លើងឋានន្តរសក្តិ និងថ្នាក់ ប្រាក់បៀវត្ស ចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីតុលាការដទៃទៀត និងវិធានការវិន័យដល់ព្រះរាជអាជ្ញា ចៅក្រម និងមន្ត្រីតុលាការដទៃទៀត ផ្អែកលើវិធាននិងលក្ខណៈវិនិច្ឆ័យ ដែលមានចែងក្នុងច្បាប់ និងដែលអនុវត្តតាមរយៈស្ថាប័នឯករាជ្យមួយ ដែលមានធនធានគ្រប់គ្រាន់ រួមមានការបង្កើតក្រមសីលធមិ និងវិធានស្តីពីទំនាស់ផលប្រយោជន៍សម្រាប់ចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីតុលាការដទៃទៀតទាំងអស់ គួបជាមួយនឹងវិធានការវិន័យពាក់ព័ន្ធ | | | | | |
| ៥.២.២ លក្ខន្តិកៈចៅក្រម និងឧត្តមក្រុមប្រឹក្សានៃអង្គ ចៅក្រមដែលមានដំណើរការយ៉ាងពេញលេញ ដែលធានានូវតម្លាភាព ក្នុងការតែងតាំង ការតម្លើងស័ក្តិ ប្រាក់បៀវត្ស និងការដាក់វិន័យចៅក្រម និងព្រះរាជអាជ្ញា | ក្រ.យុត្តិធមិ<br>ក.ក.ច.ន.យ<br>ឧត្តម.ចៅក្រម<br>រដ្ឋសភា<br>ព្រឹទ្ធសភា | Aus-Aid<br>UNDP | ដំណាក់កាលទី ១<br>២០០៤-២០០៦<br><br>(ដំណាក់កាលទី ២: សូមអានកម្មវិធីរយៈពេលមធ្យម) | ១- អនុម័តលក្ខន្តិកៈចៅក្រម (សូមអានទិសដៅយុទ្ធសាស្ត្រ # ២)<br>២- អនុម័តវិសោធនកម្មច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម (សូមអានទិសដៅយុទ្ធសាស្ត្រ #២)<br>៣- តាក់តែងកម្មវិធីលំអិតនៃសកម្មភាព | គួរតែបញ្ចូលសាលាជំរះក្តីទៅក្នុងការពិភាក្សា ឬការផ្តួចផ្តើមទាក់ទងទៅនឹងការពង្រឹងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ ភាពមិនលំអៀងរបស់ចៅក្រមគួរតែជាអាទិភាពក្នុងការពង្រឹង |

| | | | | | |
|---|---|---|---|---|---|
| | | | | ដើម្បីពង្រឹងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ផ្អែកលើអាណត្តិ និងមុខងាររបស់ស្ថាប័ននេះ ។ | អព្យាក្រឹតភាពឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម |
| ៥.២.៤ រៀបចំក្រមសីលធមិសំរាប់ចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីវិស័យយុត្តិធមិ | ឧត្តម.ចៅក្រម<br>សា.ចៅក្រម<br>ក្រ.យុត្តិធមិ<br>មហា.ច្បាប់<br>ក.ក.ច.ន.យ | Aus-AID<br>UNDP | ២០០៤-២០០៥<br>(ដំណាក់កាលទី ១) | ១- ផ្តួចផ្តើមពិភាក្សាជាមួយចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីយុត្តិធមិផ្សេងទៀត អំពីក្រមសីលធមិ<br>២- ផ្តួចផ្តើមធ្វើការលើក្រមសីលធមិជាមួយ និងអ្នកពាក់ព័ន្ធនិងវិស័យយុត្តិធមិ | កម្មវិធីកសាងសមត្ថភាពត្រូវបានផ្តល់ឱ្យមន្ត្រីថ្នាក់បច្ចេកទេសនៅក្នុងឧត្តមក្រុមប្រឹក្សានៃអង្គ-ចៅក្រម ក្នុងការត្រៀមខ្លួនធ្វើការកែទម្រង់<br>ដោយសហការជាមួយ UNDP ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានរៀបចំសិក្ខាសាលាបឋមមួយស្តីពីក្រមសីលធមិសម្រាប់ចៅក្រម នៅខែកក្កដា ឆ្នាំ២០០៤ ដោយមានការចូលរួមពីចៅក្រមមកពីទូទាំងប្រទេសចំនួន ៨០ នាក់ ។<br>ការតាមដានសិក្ខាសាលានេះកំពុងតែមានដំណើរការ ។ |

| | | | | | |
|---|---|---|---|---|---|
| ៥.២.៦ វិធានការប្រឆាំងអំពើពុករលួយ រួមទាំងច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយ | ក្រ.ទំនាក់ទំនង<br>ក.ក.ច.ន.យ<br>ក្រ.យុត្តិធម៌<br>ទី.គ.មន្ត្រី<br>ក្រ.អ្នកច្បាប់<br>ក.ក.រ | | ២០០៤-២០០៥ | រៀបចំ និងអនុម័តច្បាប់ប្រឆាំងអំពើពុក-រលួយដោយមានការចូលរួមពីគ្រប់ដៃគូសំខាន់ៗ ធានានូវភាពរលូនជាមួយស្តង់ដាអន្តរជាតិ និងរៀបចំសេចក្តីណែនាំគោលនយោបាយ ដើម្បីអនុវត្តច្បាប់ឱ្យបានសមស្រប ។ | ច្បាប់ប្រឆាំងអំពីពុករលួយ និងវិធានការផ្សេងៗទៀត ត្រូវបានរៀបចំតាំងពីឆ្នាំ១៩៩៩។ កម្ពុជាគួរចូលជាសមាជិកនៃ UN Convention against Corruption |
| ៥.៣ បញ្ចូលការគ្រប់គ្រងដូចគ្នាសម្រាប់រឿងក្តីដូចគ្នា និងបច្ចេកទេសគ្រប់គ្រងតុលាការ ដើម្បីធានាឱ្យដំណើរការមានតម្លាភាព និងតាមពេលកំណត់ រួមទាំងយន្តការប្តឹងតវ៉ាស៊ីសង្វាក់ | | | | | |
| ៥.៣.២ វិធីសាស្ត្របង្កើតតុលាការគំរូ | ក្រ.យុត្តិធម៌<br>ឧត្តម.ចៅក្រម<br>សាលាជំរះក្តី<br>ក.ក.ច.ន.យ | Aus-Aid<br>JICA<br>ប្រទេសបារាំង<br>ADB | ២០០៤-២០០៥ | គម្រោងកំពុងអនុវត្តនៅខេត្តកណ្តាល ផ្តោតលើការគ្រប់គ្រងរឿងក្តី និងបច្ចេកទេសគ្រប់គ្រងតុលាការជាទូទៅ | មានគម្រោងរៀបចំតុលាការគំរូ ១០ នៅតាមខេត្តផ្សេងទៀត ប៉ុន្តែមានការខ្វះខាតខាងថវិកា (គម្រោងនេះស្ថិតក្នុងចង្កោមជាមួយគម្រោង ៥.៣.៣ និង ៥.៤.៣) |
| ៥.៤ ផ្តល់មធ្យោបាយគ្រប់គ្រាន់ ឱ្យប្រព័ន្ធតុលាការបានទៅដល់ពលរដ្ឋកម្ពុជា រួមទាំងធានាផ្តល់ប្រៀវត្សគ្រប់គ្រាន់ជូនមន្ត្រីតុលាការ ផ្តល់ការអប់រំមានគុណភាព និងការសិក្សាចាំបាច់បន្ថែម ធ្វើឱ្យមានការិយាលយ័តុលាការគ្រប់គ្រាន់ បំពាក់ដោយសម្ភារៈមូលដ្ឋាន និងមានធនធានមនុស្សគ្រប់គ្រាន់ទូទាំងប្រទេស និងបង្កើតតុលាការពិសេសដែលមានចំណេះដឹងឯកទេសចាំបាច់ | | | | | |
| ៥.៤.២ សាលាចៅក្រម និងសាលាសម្រាប់មន្ត្រីយុត្តិធម៌ រួមទាំងកម្មវិធីបណ្តុះបណ្តាលជាបន្ត សម្រាប់អ្នកមានតួនាទីទាំងអស់ (ការបណ្តុះណ្តាលមូលដ្ឋាន ឯកទេស និងដំណោះស្រាយបញ្ហា) ស្របទៅតាមសេចក្តីត្រូវការ | សា.ចៅក្រម<br>ក្រ.យុត្តិធម៌<br>ឧត្តម.ចៅក្រម | ប្រទេសបារាំង<br>JICA<br>UNDP<br>GTZ | ២០០៤-២០០៦ | បន្តអនុវត្តកម្មវិធីសកម្មភាពសម្រាប់សាលាភូមិន្ទចៅក្រម:<br>១-បណ្តុះបណ្តាលគ្រូ<br>២-បណ្តុះបណ្តាលបន្តចៅក្រមក្នុងតំណែង | គម្រោងកំពុងមានដំណើរការ។ ការដាក់មានគ្រូបង្រៀនពេញម៉ោងនៅសាលាភូមិន្ទចៅក្រមសំខាន់ណាស់ ។ គួរពិចារណាជ្រើសរើសគ្រូពីចៅក្រម និងព្រះរាជអាជ្ញា ដែលមានសព្វថ្ងៃ។ |

| | | | | | |
|---|---|---|---|---|---|
| ៥.៤.៤វិធានការបង្កើតតុលាការ/សាភាពាណិជ្ជកម្ម និងតុលាការ/សភាឯកទេសផ្សេង១) រួមទាំងបែបបទតុលាការពាណិជ្ជកម្ម និងការបណ្តុះបណ្តាលអ្នកឯកទេសផ្នែកច្បាប់ពាណិជ្ជកម្ម | ក្រ.ពាណិជ្ជកម្ម<br>សា.ចៅក្រម<br>ស.នីតិសាស្ត្រ<br>ឧត្តម.ចៅក្រម<br>ក្រ.យុត្តិធម៌<br>ក.ក.ច.ន.យ | CIDA | ដំណាក់កាលទី ១<br>២០០៤-២០០៦<br>( ដំណាក់កាលទី ២ សូមអានកម្មវិធីរយៈពេលមធ្យម) | ១-សេចក្តីសម្រេចគោលនយោបាយថាតើបង្កើតសភាឯកទេសក្នុងរង្វង់រចនាសម្ព័ន្ធតុលាការបច្ចុប្បន្ន ឬមួយបង្កើតតុលាការឯក-ទេសមួយ ដោយធានាថា សេចក្តីព្រាងច្បាប់ថ្មីស៊ីចង្វាក់គ្នានឹងច្បាប់ផ្សេង១ទៀតដែលកំពុងរៀបចំជាពិសេសក្រមរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ នីតិវិធីនិងសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំតុលាការ<br>២- បញ្ចូលការបណ្តុះបណ្តាលច្បាប់ពាណិជ្ជកម្មក្នុងសាលាភូមិន្ទចៅក្រម | ការពិភាក្សារវាងស្ថាប័នពាក់ព័ន្ធកំពុងមានដំណើរការ។ |
| ៥.៤.៥ វិធានការបង្កើតតុលាការរដ្ឋបាល | ទី.ត.មន្ត្រី<br>ឧត្តម.ចៅក្រម<br>ក្រ.យុត្តិធម៌<br>តុលាការកំពូល<br>ក្រុ.អ្នកច្បាប់ | France | ដំណាក់កាលទី ១<br>២០០៥<br>( ដំណាក់កាលទី ២ សូមអានកម្មវិធីរយៈពេលមធ្យម) | ១-ផ្តួចផ្តើមពិភាក្សា សិក្សាស្រាវជ្រាវជាមួយស្ថាប័ន និងអ្នកឯកទេសពាក់ព័ន្ធ<br>២-ស្វែងយល់ការងារជាក់ស្តែងដោយបញ្ជូនសិក្ខាកាមទៅប្រទេសដែលមានបទពិសោធន៍ | ក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋបារាំង បានយល់ព្រមទទួលសិក្ខា-កាម ដើម្បីស្វែងយល់អំពីវិធាន-ការបង្កើតស្ថាប័ននេះ |
| ៥.៥ ធានាការឱ្យមានការអនុវត្តសេចក្តីសម្រេចរបស់តុលាការ និងឯករាជ្យភាពរបស់តុលាការ ដោយផ្តល់នូវក្របខ័ណ្ឌច្បាប់ និងស្ថាប័នដែលបង្គ្រប់បន្ថែមដោយធនធានចាំបាច់ និងធ្វើការហ្វឹកហ្វឺន | | | | | |
| ៥.៥.១ ការស្ទង់មតិលើយន្តការអនុវត្តច្បាប់បច្ចុប្បន្ន ដើម្បីរកឱ្យឃើញចំណុចកែលំអ | ក.ក.ច.ន.យ<br>ឧត្តម.ចៅក្រម<br>ក្រ.យុត្តិធម៌<br>ក្រ.មហាផ្ទៃ | ADB | ២០០៥ | បង្កើតក្រុមការងារបច្ចេកទេស ដើម្បីកំណត់វិស័យ និងរៀបចំការស្ទង់មតិ និងដាក់ចេញនូវអនុសាសន៍ ធានានូវភាពស៊ីចង្វាក់គ្នាជាមួយច្បាប់នានាដែលបានរៀបចំ និងកំពុងរៀបចំ | ADB បានជួយធ្វើការស្ទង់មតិលើយន្តការប្រតិបត្តិច្បាប់ពាណិជ្ជកម្ម |

**អាទិភាពកំណត់៖**

៦.១.១ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ដំណាក់កាលទី១)

៦.២.១ ស៊ើបអង្កេត កសាង និងពង្រឹងវិធីសាស្ត្រជាប្រពៃណីនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

| **ទិសដៅយុទ្ធសាស្ត្រ៖** បញ្ចូលយន្តការដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ | | **លទ្ធផលរំពឹងទុក ៖** ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដែលដំណើរការល្អប្រសើរ និងយន្តការសន្ទានកម្មត្រូវបានបង្កើតដើម្បីដោះស្រាយវិវាទពាណិជ្ជកម្ម និង វិវាទតូចតាចនៅក្នុងកម្រិតសហគមន៍ | | | |
|---|---|---|---|---|---|
| **សកម្មភាពជាអាទិភាព** | **ស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ** | **ស្ថាប័នដទៃទៀតដែលកំពុងមានការពាក់ព័ន្ធ** | **រយៈពេល** | **សកម្មភាពដែលត្រូវធ្វើ** | **សេចក្តីសង្កេតបន្ថែម** |
| ៦.១ បញ្ចូលមជ្ឈត្តកម្មពាណិជ្ជកម្ម និងវិធីសាស្ត្រដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដទៃទៀត រួមមានសន្ទានកម្ម ដើម្បីដោះស្រាយវិវាទពាណិជ្ជកម្ម | | | | | |
| ៦.១.១ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម | ក្រ.ពាណិជ្ជកម្ម<br>ក.ក.ច.ន.យ<br>ក្រ.យុត្តិធម៌<br>រដ្ឋសភា<br>ព្រឹទ្ធសភា<br>ក្រ.ទំនាក់ទំនង | CIDA<br>ADB | ដំណាក់កាលទី ១<br>២០០៤-២០០៥<br>(ដំណាក់កាលទី ២ សូមអានកម្មវិធីរយៈពេលមធ្យម) | ១-តាក់តែងសេចក្តីព្រាងច្បាប់ស្តីពីមជ្ឈត្តកម្មពាណិជ្ជកម្ម ឱ្យស៊ីសង្វាក់គ្នានឹងស្តង់ដារអន្តរជាតិ និងច្បាប់សំខាន់ៗដែលកំពុងរៀបចំ ដូចជាក្រមរដ្ឋប្បវេណី<br>២- បង្កើតមជ្ឈមណ្ឌលជាតិសម្រាប់មជ្ឈត្តកម្មពាណិជ្ជកម្ម | ច្បាប់ត្រូវបានព្រាង និងបញ្ជូនទៅរដ្ឋសភារួចហើយ |
| ៦.២ រៀបចំយន្តការដោះស្រាយវិវាទតូចតាច តាមរយៈសន្ទានកម្មឱ្យមានប្រសិទ្ធភាព | | | | | |

| | | | | | |
|---|---|---|---|---|---|
| ៦.២.១ ការស្វែងយល់ កសាង និង ពង្រឹងវិធីសាស្ត្រជាប្រពៃណី នៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ | ក.ក.ច.ន.យ<br>ក្រ.យុត្តិធម៌<br>ក្រ.មហាផ្ទៃ<br>ក្រុមប្រឹក្សាឃុំ-សង្កាត់ | ACT<br>SILAKA<br>CLEC<br>CDRI<br>UNDP | ២០០៤-២០០៥ | ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (ADR) នៅថ្នាក់មូលដ្ឋាន និងឃុំ-សង្កាត់<br>១-រៀបចំនិងអនុវត្តនូវការសិក្សាទូលំទូលាយមួយលើដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដើម្បីស្វែងយល់អំពីវិធីសាស្ត្រដែលមាន សព្វថ្ងៃនៅក្នុងប្រទេស អំពីវិសាលភាពនៃវិធីសាស្ត្រទាំងនេះ ព្រមទាំងអំពីអន្តរទំនាក់ទំនងរវាងប្រព័ន្ធផ្លូវការ និងមិនផ្លូវការ ។<br>២- សមត្ថភាពឃុំ-សង្កាត់ត្រូវពង្រឹង ដើម្បីជំរុញយន្តការ ADR សព្វថ្ងៃ និងត្រូវយកចិត្តទុកដាក់ជាពិសេសដល់ការផ្តល់ជូននូវកម្មវិធីយល់ដឹងអំពីច្បាប់ ។ | UNDP បានស្នើការជួយឧបត្ថម្ភក្នុងវិស័យនេះ ។ |
| | ក.ក.ច.ន.យ<br>ក្រ.សង្គមកិច្ច<br>ក្រ.យុត្តិធម៌<br>ក្រ.សេដ្ឋ.ហិរ<br>សាកលវិទ្យាល័យ<br>សា.ចៅក្រម | CLEC<br>សហជីពពាណិជ្ជកម្ម<br>វិស័យពាណិជ្ជកម្ម | ២០០៤-២០០៥ | ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងវិវាទការងារ<br>១-កំណត់សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាមជ្ឈត្តកម្មការងារ ជាពិសេសពាក់ព័ន្ធនិងសេចក្តីសំរេចថា តើរឿងក្តីណាជារឿងក្តីបុគ្គល រឿងក្តីណាជារឿងក្តីសមូហភាព។ ការសើរើច្បាប់បច្ចុប្បន្នមានសារៈសំខាន់សម្រាប់កំណត់អត្តសញ្ញាណផ្នែកច្បាប់ របស់ក្រុមប្រឹក្សាមជ្ឈត្តកម្មការងារ<br>២-បញ្ចោក់បំភ្លឺអំពីនីតិវិធីរបស់ក្រុមប្រឹក្សាមជ្ឈត្តកម្មការងារសម្រាប់មន្ត្រីក្នុងរង្វង់ប្រព័ន្ធ | អង្គការពលកម្មអន្តរជាតិកំពុងធ្វើការជាមួយក្រសួងយុត្តិធម៌ ដើម្បីរៀបចំសេចក្តីព្រាងសារាចរមួយអំពីនីតិវិធីមជ្ឈត្តកម្ម ដើម្បីជម្រាបជូនចៅក្រម និងព្រះរាជអាជ្ញាទាក់ទងទៅ នឹងករណីរឿងក្តីទាំងពីរ សមូហភាព និងឯកត្តជន ដែលត្រូវចូលទៅក្នុងដំណើរការសម្របសម្រួល ។ |

| | | | | | |
|---|---|---|---|---|---|
| | | | | ផ្លូវការ<br>៣-កំណត់បទប្បញ្ញត្តិពិសេសស្តីពីថវិកាសម្រាប់ក្រុមប្រឹក្សាមជ្ឈត្តកម្មការងារ | ក្រុមប្រឹក្សាមជ្ឈត្តកម្មការងារមានដំណើរការក្រោមការឧបត្ថម្ភថវិកាពីអង្គការពលកម្មអន្តរជាតិដល់ត្រឹមចុងឆ្នាំ ២០០៤ តែប៉ុណ្ណោះ ។ |
| | ក.ក.ច.ន.យ<br>ក្រ.រៀបចំ.ដី<br>ក្រ.យុត្តិធមិ<br>ក្រ.មហាផ្ទៃ<br>សា.ចៅក្រម<br>ក្រ.កិច្ចការនារី | CDRI<br>CLEC<br>ACT<br>SILAKA<br>ADHOC<br>KID-follow-up<br>CICP<br>Women Peace Makers<br>LICADHO<br>CDP<br><br>UNESCO (research)<br>UNHCHR(monitoring)<br>GTZ (land and women rights)<br>ADB (Land management<br>The South-East Asian<br>Conflict Studies Network (SEACSN-research)<br>SIDA-Sweden (research)<br>EWMI (Resarch) | ២០០៤-២០០៥ | ដំណោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការដោះស្រាយករណីមួយចំនួន ដែលពាក់ព័ន្ធនឹងយន្តការបច្ចុប្បន្ន | |
| | អង្គភាពទទួលពាក្យ-បណ្តឹងទីស្តីការគណ:-រដ្ឋមន្ត្រី | | | ដោះស្រាយវិវាទរដ្ឋបាលនៅទីស្តីការគណ:-រដ្ឋមន្ត្រី | |

**អាទិភាពកំណត់:**

៧.៤.១ បង្កើតប្រព័ន្ធពិនិត្យតាមដាននៃវិស័យយុត្តិធម៌ ដើម្បីវាស់វែងការអនុវត្តទូទៅ រួមទាំងរដ្ឋបាលនៃវិស័យនេះ ដើម្បីជាមគ្គុទេសក៍សម្រាប់កំណែទម្រង់ទាំងមូល

៧.៥.១ ការអភិវឌ្ឍនិងការរក្សានូវប្រព័ន្ធរួមមួយអំពីការធ្វើផែនការ ការរៀបចំថវិកា និងសវនកម្ម ការតាមដាន និងការធ្វើរបាយការណ៍ ស្របទៅតាមផែនការកម្មរបស់រាជរដ្ឋាភិបាល និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម (ដំណាក់កាលទី១)

៧.៥.២ ផែនការការងារសម្រាប់នគរបាល ប្រព័ន្ធពន្ធនាគារ អយ្យការ រដ្ឋបាលតុលាការ និងស្ថាប័នផ្សេងៗទៀតនៃវិស័យច្បាប់ និងតុលាការ រួមទាំងសាលារៀនរបស់វិស័យច្បាប់ និងតុលាការ (ដំណាក់កាលទី១)

៧.៧.១ កសាងសមត្ថភាពចាំបាច់របស់ស្ថាប័ននីមួយៗ ដើម្បីបំពេញអណត្តិរបស់ខ្លួន ដោយការអភិវឌ្ឍន៍គោលនយោបាយគ្រប់គ្រងធនធានមនុស្ស

| **ទិសដៅជាយុទ្ធសាស្ត្រ:** ពង្រឹងស្ថាប័នវិស័យយុត្តិធម៌ ដើម្បីបំពេញអាណត្តិរបស់ស្ថាប័នទាំងនោះ | | **លទ្ធផលរំពឹងទុក :** សមត្ថភាព និងមធ្យោបាយត្រូវបានផ្តល់នៅក្នុងវិស័យផែនការកម្ម និងធ្វើថវិកាត្រួតពិនិត្យតាមដានមើល និងការធ្វើរបាយការណ៍ ដើម្បីធ្វើឱ្យការអនុវត្ត មានការទទួលខុសត្រូវមានប្រសិទ្ធភាព និងគ្រប់គ្រាន់ | | | |
|---|---|---|---|---|---|
| **សកម្មភាពជាអាទិភាព** | **ស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ** | **ស្ថាប័នដទៃទៀតដែលកំពុងមានការពាក់ព័ន្ធ** | **រយៈពេល** | **សកម្មភាពដែលត្រូវធ្វើ** | **សេចក្តីសង្កេតបន្ថែម** |
| ៧.៤ វិស័យយុត្តិធម៌គួរអភិវឌ្ឍន៍នូវប្រព័ន្ធត្រួតពិនិត្យដែលអាចវាស់វែងនូវរបៀបដែលអនុវត្តកយុត្តិធម៌ (រួមទាំងវិធាននានា ដំណើរការ ស្ថាប័ន និងយន្តការនៃការអនុវត្ត ដើម្បីរកយុត្តិធម៌) ហើយនៅក្នុងពេលជាមួយគ្នានេះដែរ បង្ហាញពីបញ្ហា និងកត្តារាំងស្ទះឯទៀតនៅក្នុងការគ្រប់គ្រប់រដ្ឋបាលយុត្តិធម៌ | | | | | |
| ៧.៤.១ បង្កើតប្រព័ន្ធពិនិត្យតាមដាននៃវិស័យយុត្តិធម៌ ដើម្បីវាស់វែងការអនុវត្តទូទៅ រួមទាំងរដ្ឋបាលនៃវិស័យនេះ ដើម្បីជាមគ្គុទេសក៍សម្រាប់កំណែទម្រង់ទាំងមូល | ក.ក.ច.ន.យ<br>ក្រ.យុត្តិធម៌<br>ឧត្តម.ចៅក្រម<br>ក្រ.មហាផ្ទៃ<br>(នគរបាល + ពន្ធនាគារ) | Aus-Aid | ២០០៤-២០០៦ | ១-ផ្តែកលើផែនការសកម្មភាព រៀបចំសូចនាករនៃការអនុវត្តសម្រាប់ប្រព័ន្ធយុត្តិធម៌ និងកំណត់មធ្យោបាយសម្រាប់ប្រមូលទិន្នន័យ និងធ្វើរបាយការណ៍<br>២- ផ្តួចផ្តើមការពិភាក្សារៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ស្ថាប័ននីមួយៗ ក៏ដូចជាសម្រាប់វិស័យយុត្តិធម៌ទាំងមូល ផ្សារភ្ជាប់ទៅ នឹងថវិការដ្ឋ | |

| | | | | | |
|---|---|---|---|---|---|
| ៧.៥ វិស័យយុត្តិធម៌គួរអភិវឌ្ឍន៍ និងរក្សានូវផែនការកម្ម ថវិកាកម្ម និងសវនកម្មមួយ ប្រព័ន្ធតាមដានត្រួតពិនិត្យគម្រោងនានាពាក់ព័ន្ធ និងធ្វើរបាយការណ៍ និងយុត្តិសាស្ត្រ រួមទាំងប្រព័ន្ធផែនការការងារ ៣ ឆ្នាំ ភ្ជាប់ និងគោរពទៅតាមផែនការកម្មរាជរដ្ឋាភិបាល និងប្រព័ន្ធក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ។ ភាសាគ្រប់គ្រងរួមបែបនេះ នឹងគាំទ្រសហប្រតិបត្តិការរវាងស្ថាប័ន នឹងអាចឱ្យវិស័យនេះសម្រេចអំពីអាទិភាព ដោយមិនបង្កគ្រោះថ្នាក់ដល់ឯករាជ្យភាពនៃស្ថាប័ននីមួយៗ ស្របទៅតាមតម្លៃនៃវិស័យយុត្តិធម៌ និងអាណត្តិស្ថាប័ន ។ | | | | | |
| ៧.៥.១ ការអភិវឌ្ឍ និងការរក្សានូវប្រព័ន្ធរួមមួយអំពីការធ្វើផែនការ ការរៀបចំថវិកា និងសវនកម្ម ការតាមដាន និងការធ្វើរបាយការណ៍ ស្របទៅតាមផែនការកម្មរបស់រាជរដ្ឋាភិបាល និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម | ក.ក.ច.ន.យ<br>ក្រ.សេដ្ឋ.ហិរ<br>វិទ្យាស្ថានស្ថិតិ<br>ក្រ.ផែនការ | DIHR<br>Aus-Aid | ដំណាក់កាលទី១<br>២០០៤-២០០៦<br>(ដំណាក់កាលទី២ សូមអានកម្មវិធីរយៈពេលមធ្យម) | ១- អភិវឌ្ឍន៍មូលដ្ឋានផែនការកម្មមួយលើយន្តការផែនការកម្មដែលមានសព្វថ្ងៃក្នុងក្របខ័ណ្ឌនៃវិស័យយុត្តិធម៌ កំណែទម្រង់រដ្ឋបាល និងកំណែទម្រង់ដទៃទៀត រួមទាំង MTEF ផង ។<br>២- ធ្វើការស្ទង់មតិអំពីសេចក្តីត្រូវការផ្នែកបណ្តុះបណ្តាល (ចំពោះមន្ត្រីសំខាន់ៗផ្នែកគ្រប់គ្រងនៅតាមស្ថាប័ននីមួយៗនៃវិស័យយុត្តិធម៌)<br>៣- ការអភិវឌ្ឍសៀវភៅបង្រៀនរួមមួយសម្រាប់ស្ថាប័នវិស័យយុត្តិធម៌អំពីយន្តការ និងវិធីសាស្ត្រធ្វើផែនការ ធ្វើកម្មវិធី រៀបចំថវិកា តាមដាន ធ្វើសវនកម្ម និងធ្វើរបាយ-ការណ៍ | DIHR បានផ្តើមកិច្ចពិភាក្សាអំពីគម្រោងឧបត្ថម្ភ PCB និង PMU ក្នុងផ្នែកនេះ ។ គម្រោងឧបត្ថម្ភភ្ជាប់ទៅនឹងគម្រោងឧបត្ថម្ភរបស់ AusAid / CCJAP ក្នុងសកម្មភាព ៧.៥.២ |

| | | | | | |
|---|---|---|---|---|---|
| ៧.៥.២ ផែនការការងារសម្រាប់នគរបាល ប្រព័ន្ធពន្ធនាគារ អយ្យការ រដ្ឋបាលតុលាការ និងស្ថាប័នផ្សេងៗទៀតនៃវិស័យច្បាប់ និងតុលាការ រួមទាំងសាលារៀនរបស់វិស័យច្បាប់ និងតុលាការ | ក.ក.ច.ន.យ<br>ក្រ.យុត្តិធម៌<br>ក្រ.មហាផ្ទៃ<br>សាលាបណ្តុះបណ្តាល | DIHR<br>Aus-Aid | ដំណាក់កាលទី ១ ២០០៤-២០០៦ (ដំណាក់កាលទី២ សូមអានកម្មវិធីរយៈពេលមធ្យម) | ១-ផ្តល់ការបណ្តុះបណ្តាលជូនស្ថាប័នយុត្តិធម៌ អំពីយន្តការ និងវិធីសាស្ត្រធ្វើផែនការ រៀបចំថវិកា តាមដាន ធ្វើសវនកម្ម និងរបាយការណ៍<br>២-រៀបចំផែនការការងារសម្រាប់នគរបាល ប្រព័ន្ធពន្ធនាគារ អយ្យការ រដ្ឋបាលតុលាការ និងស្ថាប័នវិស័យយុត្តធម៌ផ្សេងទៀតរួមទាំងសាលាបណ្តុះបណ្តាលវិស័យនេះផង | AusAid បានជួយឧបត្ថម្ភក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ (នាយកដ្ឋានពន្ធនាគារ) និង PMU ក្នុងការអភិវឌ្ឍន៍ផែនការយុទ្ធសាស្ត្រ និងកម្មវិធីថវិកា ។ គម្រោងឧបត្ថម្ភនេះភ្ជាប់ជាមួយ និងសកម្មភាព ៧.៥.១ |
| ៧.៧ អភិវឌ្ឍគោលនយោបាយគ្រប់គ្រងធនធានមនុស្សដែលគួសបញ្ជាក់ពីការជ្រើសរើស និងគោលនយោបាយអាជីព និងសេចក្តីណែនាំដែលពាក់ព័ន្ធ និងលក្ខណៈវិនិច្ឆ័យសម្រាប់ការតែងតាំង ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់ ការផ្លាស់ប្តូរ ការដាក់វិន័យគោលនយោបាយ បណ្តុះបណ្តាល និងការវាយតម្លៃ សេចក្តីត្រូវការជាប្រព័ន្ធដែលពាក់ព័ន្ធ និងកម្មវិធីបណ្តុះបណ្តាលនៅក្នុងវិស័យដូចតទៅ ការបញ្ចូលដល់និយោជិតថ្មី ការបណ្តុះបណ្តាលនិយោជិតដែលតម្លើងឋានៈថ្មី និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស ការបណ្តុះបណ្តាលជំនាញគ្រប់គ្រង និងភាពជាអ្នកដឹកនាំ និងការយល់ដឹងទូទៅ និងការអនុវត្តក្រមសីលធម៌ ។ ជាចុងក្រោយ គោលនយោបាយគួររួមបញ្ចូលនូវប្រព័ន្ធតម្លាភាព ដាក់វិន័យនូវរបៀបឱ្យស្ថាប័នប្រឆាំងនឹងអំពើពុករលួយ និងជំរុញឱ្យប្រសើរឡើងនូវសីលធម៌ ។ | | | | | |
| ៧.៧.១ កសាងសមត្ថភាពចាំបាច់របស់ស្ថាប័ននីមួយៗ ដើម្បីបំពេញអាណត្តិរបស់ខ្លួន ដោយការអភិវឌ្ឍគោលនយោបាយគ្រប់គ្រងធនធានមនុស្ស | ក.ក.ច.ន.យ<br>ក្រ.យុត្តិធម៌<br>ឧត្តម.ចៅក្រម<br>ក្រ.មហាផ្ទៃ<br>(នគរបាល + ពន្ធនាគារ)<br>សា.ចៅក្រម<br>មជ្ឈមណ្ឌល-មេធាវី<br>ក.ក.រ | DIHR<br>Aus-Aid | ២០០៤-២០០៦ | ១- ពង្រឹង PMU& PCB ពាក់ព័ន្ធដល់ការងារសម្របសម្រួល និងតួនាទីលេខា-ធិការដ្ឋាន ក្នុងដំណើរការកែទម្រង់ (សូមអានសកម្មភាព ៧.៦.២)<br>២- អភិវឌ្ឍគោលនយោបាយគ្រប់គ្រងធនធានមនុស្ស និងផែនការសកម្មភាព | |

# កម្មវិធីសកម្មភាព

# រយៈពេលមធ្យម

# សកម្មភាពអាទិភាពរយៈពេលមធ្យម

■១.១.១ កម្មវិធីលើកកម្ពស់ការយល់ដឹង តាមរយៈការបណ្តុះបណ្តាលការអប់រំ ។ ល ។ ពាក់ពន្ធ័ទៅនឹងសិទ្ធិមូលដ្ឋាន នៅកម្រិតសហគមន៍ និងគ្រឹះស្ថាន សហគ្រាស រួមទាំងអំពីយន្តការរបាយការណ៍

◆១.៤.១ ច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាល

◆១.៤.២ ច្បាប់ស្តីពីរបបសារព័ត៌មាន

◆១.៥.១ ការបង្កើតប្រព័ន្ធសុរិយោដី/សារការី ។ល។

●១.៦.១ ការបង្កើតការិយាល័យសិទ្ធិប្រជាពលរដ្ឋ (OMBUDSMAN)

●១.៧.១ ការបង្កើតវិទ្យាស្ថានឧក្រិដ្ឋវិទ្យា

●២.១.១ ក្រមរដ្ឋបាល និងក្រមនីតិវិធីរដ្ឋបាល

■២.១.២ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ( ដំណាក់កាលទី ២ )

■២.១.៣ ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ ( ដំណាក់កាលទី ២ )

◆២.១.៤ ច្បាប់អង្គការស្តីពីការរៀបចំតុលាការ ( ដំណាក់កាលទី ២ )

●២.១.៥ ច្បាប់ស្តីពីរដ្ឋបាលរបស់តុលាការ

●២.១.៦ ច្បាប់ស្តីពីនគរបាល

●២.១.៧ បទប្បញ្ញត្តិច្បាប់ដើម្បីធានាឯករាជ្យភាពនៃសេវាអយ្យការ

◆២.១.៨ ច្បាប់ស្តីពីប្រព័ន្ធពន្ធនាគារ និងការស្តារនីតិសម្បទា

◆២.១.១០ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម ( ដំណាក់កាលទី ២ )

◆២.១.១១ ច្បាប់អង្គការស្តីពីការគ្រប់គ្រងខេត្ត ក្រុង ។ល។

●២.១.១២ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជជាតិ

◆២.៣.៤ បង្កើតអង្គភាពនីតិកម្មនៅក្នុងក្រសួងនីមួយៗ

◆៣.១.២ ការផ្តល់សទ្ទានុក្រមជាបីភាសា

●៣.៣.២ ការទទួលសាធារណជន ( ការិយាល័យ ) និងមុខងារព័ត៌មាននៅក្នុងតុលាការ

◆៤.១.១ គោលនយោបាយ និងលិខិតបទដ្ឋានស្តីពីតំណាងផ្នែកច្បាប់ និងជំនួយផ្នែកច្បាប់ រួមទាំងការធានានូវសេរីភាពរបស់អង្គការមិនមែនរដ្ឋាភិបាល ដើម្បីផ្តល់ជំនួយផ្នែកច្បាប់ ( ដំណាក់កាលទី ២ )

◆៤.២.៣ ការកែលំអសីលធម៌សម្រាប់មេធាវី រួមទាំងការដាក់វិន័យមានប្រសិទ្ធភាព ដោយក្រុមប្រឹក្សាវិន័យនៅក្នុងគណៈមេធាវី ស្របតាមគោលការណ៍សីលធម៌ ដែលបានផ្តល់ឱ្យសម្រាប់មេធាវី

◆៥.២.២ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលមានដំណើរការយ៉ាងពេញលេញ ដើម្បីធានានូវតម្លាភាពក្នុងការ តែងតាំង ការតម្លើងស័ក្តិ ប្រាក់បៀវត្ស និងការដាក់វិន័យចៅក្រម និងព្រះរាជអាជ្ញា (ដំណាក់កាលទី ២)

◆៥.២.៤ រៀបចំក្រមសីលធម៌សម្រាប់ចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីយុត្តិធម៌ (ដំណាក់កាលទី ២)

◆៥.៣.៣ សេចក្តីណែនាំអំពីការគ្រប់គ្រងសំណុំរឿងក្តី និងតុលាការដែលបង្កើតឡើង ស្របទៅតាមបទបញ្ញត្តិច្បាប់នៃក្រមនីតិវិធី និងច្បាប់អង្គការស្តីពីការរៀបចំតុលាការ និងច្បាប់ស្តីពីរដ្ឋបាលតុលាការ ស្របទៅតាមសេចក្តីត្រូវការ

◆៥.៤.១ គោលនយោបាយរដ្ឋស្តីពីការបែងចែកថវិកាឱ្យតុលាការ (ភាគរយកំណត់របស់ថវិកាជាតិ)

●៥.៤.៣ បំពាក់សម្ភារៈបរិក្ខារជូនតុលាការឱ្យបានគ្រប់គ្រាន់ ទាន់សម័យ រួមទាំងបរិក្ខារបច្ចេកវិទ្យាព័ត៌មានដែលពាក់ព័ន្ធ

◆៥.៤.៤ វិធានការបង្កើតតុលាការ/សភាពាណិជ្ជកម្ម និងតុលាការ/សភាឯកទេសផ្សេងទៀត រួមទាំងបែបបទតុលាការពាណិជ្ជកម្ម និងការបណ្តុះបណ្តាលអ្នកឯកទេសផ្នែកច្បាប់ពាណិជ្ជកម្ម (ដំណាក់កាលទី ២)

●៥.៤.៥ វិធានការបង្កើតតុលាការរដ្ឋបាល (ដំណាក់កាលទី ២)

◆៥.៥.២ បង្កើតស្ថាប័នសម្រាប់អនុវត្តសាលក្រម

◆៥.៥.៥ បញ្ចូលគោលការណ៍សីលធម៌នៅក្នុងកម្មវិធីសម្រាប់ការអប់រំមន្ត្រីតុលាការ នគរបាល មន្ត្រីពន្ធនាគារ និងមន្ត្រីរាជការឯទៀត

◆៦.១.១ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ដំណាក់កាលទី ២)

●៧.៥.១ ការអភិវឌ្ឍនិងការរក្សានូវប្រព័ន្ធរួមមួយអំពីផែនការ ការរៀបចំថវិកានិងសវនកម្ម ការតាមដាន និងការធ្វើរបាយការណ៍ ស្របទៅតាមផែនការកម្មរបស់រាជរដ្ឋាភិបាល និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម (ដំណាក់កាលទី ២)

◆៧.៥.២ រៀបចំផែនការការងារសម្រាប់នគរបាល ប្រព័ន្ធពន្ធនាគារ អយ្យការ រដ្ឋបាលតុលាការ និងស្ថាប័នផ្សេងៗទៀតនៃវិស័យច្បាប់ និងតុលាការ រួមទាំងសាលាបណ្តុះបណ្តាលនៃវិស័យច្បាប់ និងតុលាការ(ដំណាក់កាល២)

●៧.៦.១ រៀបចំអង្គភាពផែនការផ្ទៃក្នុង ដើម្បីជំនួយដល់ការបំពេញអាណត្តិរបស់ស្ថាប័ន និងរៀបចំប្រមូលព័ត៌មានប្រតិបត្តិ (ទិន្នន័យស្ថិតិ)

●៧.៦.២ ការធ្វើឱ្យមានទស្សនៈរួមគ្នារវាងស្ថាប័ននៃវិស័យយុត្តិធម៌ ជាពិសេសទាក់ទងនឹងការទទួលព័ត៌មានប្រតិបត្តិ

**កំណត់សំគាល់**

■ សកម្មភាពរយៈពេលមធ្យមដែលជឿនលឿនទៅមុខបានស្រួលបួលហើយ

◆ សកម្មភាពរយៈពេលមធ្យមដែលកំពុងដំណើរការ ប៉ុន្តែត្រូវការអន្តរាគមន៍បន្ថែមជំនួយឧបត្ថម្ភ ។ល ។

● សកម្មភាពរយៈពេលមធ្យមដែលពុំទាន់បានចាប់ផ្តើមនៅឡើយ ។

# តារាងសង្ខេបអាទិភាពរយៈពេលមធ្យម

## ទិទិសដៅជាយុទ្ធសាស្ត្រ ទី ១:ការពារសិទ្ធិ-សេរីភាពរបស់បុគ្គល

- ការផ្សព្វផ្សាយកម្មវិធីសិទ្ធិមនុស្សនៅតាមសហគមន៍
- ច្បាប់ស្តីពីអង្គការមិន-មែនរដ្ឋាភិបាល
- បង្កើតការិយាល័យការពារសិទ្ធិប្រជាពលរដ្ឋ (OMBUDSMAN)
- ច្បាប់ស្តីពីរបបសារព័ត៌មាន
- បង្កើតសារការី
- បង្កើតវិទ្យាស្ថានឧក្រិដ្ឋវិទ្យា

## ទិសដៅជាយុទ្ធសាស្ត្រ ទី ២:ធ្វើទំនើបកម្មក្របខ័ណ្ឌច្បាប់

- ក្រមរដ្ឋប្បវេណី និងក្រមព្រហ្មទណ្ឌ (ដំណាក់កាលទី ២)
- ក្រមរដ្ឋបាល
- ច្បាប់ស្តីពីការរៀបចំតុលាការ និងច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម (ដំណាក់កាលទី២)
- ច្បាប់ស្តីពីរដ្ឋបាលតុលាការ
- ច្បាប់ស្តីពីនគរបាល
- បទប្បញ្ញត្តិសម្រាប់ឯករាជ្យភាពនៃព្រះរាជអាជ្ញា
- ច្បាប់ស្តីពីប្រព័ន្ធពន្ធនាគារ និងការស្តារនីតិសម្បទា
- ច្បាប់អង្គការស្តីពីការគ្រប់គ្រងខេត្ត ក្រុង
- ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជជាតិ
- បង្កើតអង្គភាពនីតិកម្មនៅក្នុងក្រសួងនីមួយៗ

## ទិសដៅជាយុទ្ធសាស្ត្រទី ៣ ផ្តល់លទ្ធភាពឱ្យទទួលបានព័ត៌មានអំពីច្បាប់ និងតុលាការឱ្យកាន់តែប្រសើរឡើង

- ការបង្កើតសទ្ទានុក្រមបីភាសា
- ការិយាល័យទទួលសាធារណជន និងសេវាព័ត៌មាននៅតុលាការ

## ទិសដៅជាយុទ្ធសាស្ត្រទី ៤ ធ្វើឱ្យប្រសើរឡើងនូវគុណ-ភាពនៃដំណើររឿងក្តី និងសេវាពាក់ព័ន្ធ

- គោលនយោបាយ និងបទប្បញ្ញត្តិច្បាប់ស្តីពីជំនួយ និងតំណាងផ្នែកច្បាប់ (ដំណាក់កាលទី ២)
- ការលើកកម្ពស់សីលធម៌សំរាប់មេធាវី

## ទិសដៅជាយុទ្ធសាស្ត្រទី ៥ ពង្រឹងសេវាកម្មយុត្តិធម៌ រួមមានអំណាចតុលាការ និងសេវាកម្មអយ្យការ

- ការពង្រឹងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម (ដំណាក់កាលទី ២)
- ក្រមសីលធម៌សម្រាប់ចៅក្រមព្រះរាជអាជ្ញា និងមន្ត្រីយុត្តិធម៌
- សេចក្តីណែនាំការគ្រប់គ្រងសំណុំរឿងក្តី និងតុលាការ យោងតាមបទប្បញ្ញត្តិច្បាប់ និងការបំពាក់សម្ភារៈទំនើបសម្រាប់តុលាការ
- គោលនយោបាយរដ្ឋស្តីពីការបែងចែកថវិកាឱ្យប្រព័ន្ធតុលាការ
- នីតិវិធីបង្កើតតុលាការ/សភាពាណិជ្ជកម្ម (ដំណាក់កាលទី ២)
- វិធានការបង្កើតតុលាការរដ្ឋបាល (ដំណាក់កាលទី ២)
- បង្កើតអាជ្ញាសាលា

## ទិសដៅជាយុទ្ធសាស្ត្រទី ៦ បញ្ចូលយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

- ច្បាប់ស្តីពីមជ្ឈត្តកម្មពាណិជ្ជ-កម្ម (ដំណាក់កាលទី ២)

## ទិសដៅជាយុទ្ធសាស្ត្រទី ៧ ពង្រឹងស្ថាប័នវិស័យច្បាប់ និងតុលាការ ដើម្បីបំពេញអាណត្តិរបស់ខ្លួនបានសម្រេច

- អង្គភាពផែនការផ្ទៃក្នុងនៅក្នុងស្ថាប័នយុត្តិធម៌
- ការធ្វើឱ្យមានទស្សនៈរួមគ្នារវាងស្ថាប័ននៃវិស័យយុត្តិធម៌ ជាពិសេសទាក់ទងនិងការទទួលព័ត៌មានប្រតិបត្តិ
- ប្រព័ន្ធរួមអំពីការធ្វើផែនការ ការរៀបចំថវិកា ធ្វើសវនកម្ម តាមដាន និងរាយការណ៍ (ដំណាក់កាលទី២)
- ផែនការសកម្មភាពសម្រាប់ស្ថាប័នវិស័យយុត្តិធម៌ (ដំណាក់កាលទី២)

| ផែនការអនុវត្តរយៈពេលមធ្យម | | | | | |
|---|---|---|---|---|---|
| | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ |
| **ទិសដៅជាយុទ្ធសាស្ត្រទី ១ ការពារសិទ្ធិសេរីភាពរបស់បុគ្គល** | | | | | |
| ១.១.១ កម្មវិធីលើកកំពស់ការយល់ដឹង តាមរយៈការបណ្តុះបណ្តាល ការអប់រំ ។ល។ ពាក់ពន្ធ័ទៅនឹងសិទ្ធមូលដ្ឋាននៅក៏រិតសហគមន៍ និងគ្រឹះស្ថាន សហគ្រាស រួមទាំងអំពីយន្តការរបាយការណ៍ | | →→→→→→→→→→→→→→→→→X | | | |
| ១.៤.១ ច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាល | | →→→→→→→→→→→→→→→→→X | | | |
| ១.៤.២ ច្បាប់ស្តីពីរបបសារព័ត៌មាន | →→→→→→→→→→→→→→→→→→→→→→→→→→→→→→X | | | | |
| ១.៥.១ ការបង្កើតប្រព័ន្ធសុរិយោដី/សារការី ។ល។ | →→→→→→→→→→→→→→→→→→→→→→→→→→→→→→X | | | | |
| ១.៦ ១ ការបង្កើតការិយាល័យការពារសិទ្ធិប្រជាពលរដ្ឋ (OMBUDSMAN) | | →→→→→→→→→→→→→→→→→X | | | |
| ១.៧.១ ការបង្កើតវិទ្យាស្ថានឧក្រិដ្ឋវិទ្យា | | →→→→→→→→→→→→→→→→→→→→→→→→X | | | |
| **ទិសដៅជាយុទ្ធសាស្ត្រទី ២ ធ្វើទំនើបកម្មក្របខ័ណ្ឌច្បាប់** | | | | | |
| ២.១.១ ក្រមរដ្ឋបាល និងក្រមនីតិវិធីរដ្ឋបាល រួមទាំងវិធានច្បាប់សម្រាប់ការប្តឹងតវ៉ា ( ឧទ្ធរណ៍ ) នៅតុលាការ | | →→→→→→→→→→→→→→→→→→→→→→→→X | | | |
| ២.១.២ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ( ដំណាក់កាលទី ២ ) | | | →→→→→→→→→→→→→→→→→ X | | |
| ២.១.៣ ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ ( ដំណាក់កាលទី ២) | | | →→→→→→→→→→→→→→→→→ X | | |
| ២.១.៤ ច្បាប់អង្គការស្តីពីការរៀបចំតុលាការ ( ដំណាក់កាលទី ២ ) | | | →→→→→→→→→→→→→→→→→ X | | |
| ២.១.៥ ច្បាប់ស្តីពីរដ្ឋបាលរបស់តុលាការ | →→→→→→→→→→→→→→→→→→→→→→→→X | | | | |
| ២.១.៦ ច្បាប់ស្តីពីនគរបាល | →→→→→→→→→→→→→→→→→→→→→→→→→→→→→→X | | | | |
| ២.១.៧ បទប្បញ្ញត្តិច្បាប់ដើម្បីធានាឯករាជ្យភាពនៃសេវាអយ្យការ | | →→→→→→→→→→→→→→→→→→→→→→→→ X | | | |
| ២.១.៨ ច្បាប់ស្តីពីប្រព័ន្ធពន្ធនាគារ និងការស្តារនីតិសម្បទា | →→→→→→→→→→→→→→→→→→→→→→→→→→→→→→X | | | | |
| ២.១.១០ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម ( ដំណាក់កាលទី ២) | | | →→→→→→→→→→→X | | |

| | |
|---|---|
| ២.១.១១ ច្បាប់អង្គការស្ដីពីការគ្រប់គ្រងខេត្ត ក្រុង ។ល ។ | →→→→→→→→→→→→→→→→→→→→→→→→→→→→→X |
| ២.១.១២ ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជជាតិ | →→→→→→→→→→→→→→→→→→→→→→→→→X |
| ២.៣.៤ បង្កើតអង្គភាពនីតិកម្មនៅក្នុងក្រសួងនីមួយៗ | →→→→→→→→→→→→→→→→→→→→→→→→→X |
| **ទិសដៅជាយុទ្ធសាស្ត្រទី ៣ ផ្ដល់លទ្ធភាពឱ្យទទួលបានព័ត៌មានច្បាប់ និងតុលាការឱ្យកាន់តែប្រសើរឡើង** | |
| ៣.១.២ ការផ្ដល់សទ្ទានុក្រមជាបីភាសា | →→→→→→→→→→→→→→→→→→→→→→→→→→→→→X |
| ៣.៣.២ ការទទួលសាធារណជន ( ការិយាល័យ ) និងមុខងារព័ត៌មាននៅក្នុងតុលាការ | →→→→→→→→→→→→→→→→→→X |
| **ទិសដៅជាយុទ្ធសាស្ត្រទី ៤ ធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃរឿងក្ដី និងសេវាពាក់ព័ន្ធ** | |
| ៤.១.១ គោលនយោបាយ និងលិខិតបទដ្ឋាន ច្បាប់ស្ដីពីតំណាងផ្នែកច្បាប់ និងជំនួយផ្នែកច្បាប់ រួមទាំងការធានានូវសេរីភាពរបស់អង្គការមិនមែនរដ្ឋាភិបាលដើម្បីផ្ដល់ជំនួយផ្នែកច្បាប់ ( ដំណាក់កាលទី ២) | →→→→→→→→→→→→→→→→→X |
| ៤.២.៣ ការកែលំអសីលធមិសម្រាប់មេធាវី រួមទាំងការដាក់វិន័យមានប្រសិទ្ធភាពដោយក្រុមប្រឹក្សាសីលធម៌នៅក្នុងគណៈមេធាវីស្របតាមស្ដង់ដាសីលធមិ ដែលបានផ្ដល់ឱ្យសម្រាប់មេធាវី | →→→→→→→→→→→→→→→→→→→→→→→→→X |
| **ទិសដៅជាយុទ្ធសាស្ត្រទី ៥ ពង្រឹងសេវាយុត្តិធម៌ រួមមានអំណាចតុលាការ និងសេវាកម្មអយ្យការ** | |
| ៥.២.២ ច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលមានដំណើរការយ៉ាងពេញលេញ ដើម្បីធានានូវតម្លាភាព ក្នុងការតែងតាំងការតម្លើងស័ក្តិ ប្រាក់បៀវត្ស និងការដាក់វិន័យចៅក្រម និងព្រះរាជអាជ្ញា( ដំណាក់កាលទី ២) | →→→→→→→→→→→ X |
| ៥.២.៤ រៀបចំក្រមសីលធមិសម្រាប់ចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីយុត្តិធមិ ( ដំណាក់កាលទី ២) | →→→→→→→→→→→ X |
| ៥.៣.៣ រៀបចំសេចក្ដីណែនាំអំពីការគ្រប់គ្រងសំណុំរឿងក្ដី និងតុលាការ ស្របទៅតាមបទប្បញ្ញត្តិច្បាប់នៃក្រមនីតិវិធី និងច្បាប់អង្គការស្ដីពីការរៀបចំតុលាការ និងច្បាប់ស្ដីពីរដ្ឋបាលតុលាការ | →→→→→→→→→→→→→→→→→→→→→→→→→→→→→X |
| ៥.៤.១ គោលនយោបាយរដ្ឋស្ដីពីការបែងចែកថវិកាឱ្យតុលាការ ( ភាគរយកំណត់របស់ថវិកាជាតិ) | →→→→→→→→→→→→→→→→→→→→→→→→→→→→→X |
| ៥.៤.៣ បំពាក់សម្ភារៈបរិក្ខាជូនតុលាការឱ្យបានគ្រប់គ្រាន់ទាន់សម័យ រួមទាំងបរិក្ខា បច្ចេកវិទ្យាព័ត៌មានដែលពាក់ព័ន្ធ | →→→→→→→→→→→→→→→→→→→→→→→→→→→→→X |

| | | | |
|---|---|---|---|
| ៥.៤.៤ វិធានការបង្កើតតុលាការ/សភាពាណិជ្ជកម្ម និងតុលាការ/សភាឯកទេសផ្សេងទៀត រួមទាំងបែបបទតុលាការពាណិជ្ជកម្ម និងការបណ្តុះបណ្តាលអ្នកឯកទេសផ្នែកច្បាប់ពាណិជ្ជកម្ម ( ដំណាក់កាលទី ២ ) | | | →→→→→→→→→→→→ X |
| ៥.៤.៥ វិធានការបង្កើតតុលាការរដ្ឋបាល (ដំណាក់កាលទី ២) | | →→→→→→→→→→→→→→→→→ X | |
| ៥.៥.២ បង្កើតស្ថាប័នសម្រាប់អនុវត្តសាលក្រម | →→→→→→→→→→→→→→→→→→→→→→→→→→→→→X | | |
| ៥.៥.៥ បញ្ចូលគោលការណ៍ក្រមសីលធម៌ទៅក្នុងកម្មវិធីសម្រាប់ការអប់រំមន្ត្រីតុលាការ នគរបាល មន្ត្រីពន្ធនាគារ និងមន្ត្រីរាជការឯទៀត | →→→→→→→→→→→→→→→→→→→→→→→→X | | |
| **ទិសដៅជាយុទ្ធសាស្ត្រទី ៦ បញ្ចូលយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ** | | | |
| ៦.១.១ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជកម្ម ( ដំណាក់កាលទី ២ ) | | →→→→→→→→→→→X | |
| **ទិសដៅជាយុទ្ធសាស្ត្រទី ៧ ពង្រឹងស្ថាប័នវិស័យច្បាប់ និងតុលាការដើម្បីបំពេញអាណត្តិរបស់ខ្លួនបានសម្រេច** | | | |
| ៧.៥.១ ការអភិវឌ្ឍនិងការរក្សានូវប្រព័ន្ធរួមមួយអំពីការធ្វើផែនការ ការរៀបចំថវិកា និងសវនកម្ម ការតាមដាន និងការធ្វើរបាយការណ៍ ស្របទៅតាមផែនការរបស់រាជរដ្ឋាភិបាល និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម (ដំណាក់កាលទី២) | | | →→→→→→→→→→→X |
| ៧.៥.២ ផែនការការងារសម្រាប់នគរបាល ប្រព័ន្ធពន្ធនាគារ អយ្យការ រដ្ឋបាលតុលាការ និងស្ថាប័នផ្សេងៗទៀតនៃវិស័យច្បាប់និងតុលាការ រួមទាំងសាលារៀនរបស់វិស័យច្បាប់ និងតុលាការ ( ដំណាក់កាលទី២) | | | →→→→→→→→→→→X |
| ៧.៦.១ រៀបចំអង្គភាពផែនការផ្ទៃក្នុង ដើម្បីជំនួយដល់ការបំពេញអាណត្តិរបស់ស្ថាប័ន និងរៀបចំប្រមូលព័ត៌មានប្រតិបត្តិ (ទិន្នន័យស្ថិតិ) | →→→→→→→→→→→→→→→→→→→→→→→→→→→→ X | | |
| ៧.៦.២ ការធ្វើឱ្យមានទស្សនៈរួមគ្នារវាងស្ថាប័ននៃវិស័យយុត្តិធម៌ ជាពិសេសទាក់ទងនឹងការទទួលព័ត៌មានប្រតិបត្តិ | →→→→→→→→→→→→→→→→→→→→→→→→→→→→ X | | |

## តារាងកម្មវិធីសកម្មភាពរយៈពេលមធ្យម                                        ទិសដៅយុទ្ធសាស្ត្រទី ១

**អាទិភាពកំណត់:**

១.១.១ កម្មវិធីលើកកម្ពស់ការយល់ដឹងតាមរយៈការបណ្តុះបណ្តាល ការអប់រំ ។ ល ។ ពាក់ព័ន្ធទៅនឹងសិទ្ធិមូលដ្ឋាននៅកម្រិតសហគមន៍ និងគ្រឹះស្ថាន សហគ្រាស រួមទាំងអំពីយន្តការរបាយការណ៍

១.៤.១ ច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាល ( សម្រាប់ធានាសង្គមស៊ីវិល)

១.៤.២ ច្បាប់ស្តីពីរបបសារព័ត៌មាន

១.៥.១ ការបង្កើតប្រព័ន្ធសុរិយោដី/សារការី ។ល។

១.៦.១ ការបង្កើតការិយាល័យការពារសិទ្ធប្រជាពលរដ្ឋ (OMBUDSMAN)

១.៧.១ ការបង្កើតវិទ្យាស្ថានឧក្រិដ្ឋវិទ្យា

| **ទិសដៅយុទ្ធសាស្ត្រ:** ពង្រឹងការការពារសិទ្ធិនិងសេរីភាពរបស់បុគ្គល | | **លទ្ធផលរំពឹងទុក :** សិទ្ធិ និងសេរីភាពបុគ្គលត្រូវបានជំរុញ និងបង្កលក្ខណៈ | | | |
|---|---|---|---|---|---|
| **សកម្មភាពជាអាទិភាព** | **ស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ** | **ស្ថាប័នដទៃទៀតដែលកំពុងមានការពាក់ព័ន្ធ** | **រយៈពេល** | **សកម្មភាពដែលត្រូវធ្វើ** | **សេចក្តីសង្កេតបន្ថែម** |
| ១.១ ផ្តល់ការបណ្តុះបណ្តាលហ្វឹកហ្វឺន និងកម្មវិធីយល់ដឹងអំពីសិទ្ធិមនុស្ស និងសិទ្ធិជាបឋមនៅកម្រិតសហគមន៍ គ្រឹះស្ថាន សហគ្រាស ដោយយកចិត្តទុកដាក់ជាពិសេសទៅលើស្ត្រី កុមារ និងអ្នកបាត់បង់ឱកាស រួមទាំងការបង្កើន និងការយល់ដឹងអំពីការចុះបញ្ជីសិទ្ធិ និងយន្តការបណ្តឹង | | | | | |
| ១.១.១ កម្មវិធីលើកកំពស់ការយល់ដឹង តាមរយៈការបណ្តុះបណ្តាលការអប់រំ ។ ល ។ ពាក់ព័ន្ធទៅនឹងសិទ្ធិមូលដ្ឋាននៅកម្រិតសហគមន៍ និងគ្រឹះស្ថាន សហគ្រាស រួមទាំងអំពីយន្តការរបាយ-ការណ៍ | ក្រ.អប់រំ<br>ក.ក.ច.ន.យ<br>ក្រ.យុត្តិធម៌<br>ក្រ.មហាផ្ទៃ<br>ក្រុមប្រឹក្សាឃុំ.សង្កាត់<br>ក្រ.អភិវឌ្ឍន៍កម្ពុជា<br>ក្រ.កិច្ចការនារី<br>ក្រ.ពាណិជ្ជ<br>ក្រ.ក.ប | សង្គមស៊ីវិល | ២០០៥-២០០៧ | បង្កើតទិន្នន័យស្តីពីកម្មវិធីយល់ដឹងបច្ចុប្បន្ន ដែលបាន និងកំពុងអនុវត្ត ដើម្បីឱ្យដឹងថា ស្រទាប់ប្រជាពលរដ្ឋណា ក្នុងតំបន់ណា ដែលជាមុខសញ្ញាសម្រាប់ធ្វើការបណ្តុះបណ្តាល ។ កិច្ចការនេះ អាចអនុញ្ញាតឱ្យមានអន្តរាគមន៍ច្រើនថែមទៀតពី អង្គការសង្គមស៊ីវិល អង្គការអន្តរជាតិ និងស្ថាប័នប្រព័ន្ធយុត្តិធម៌ (រួមទាំងបញ្ហា ដីធ្លី ការងារ ។ ល ។)ដែលអនុវត្ត ឬមាន បំណងអនុវត្តកម្មវិធីបណ្តុះបណ្តាលនៅថ្នាក់ឃុំ សង្កាត់ | |

| | | | | | |
|---|---|---|---|---|---|
| ១.៤ អនុម័ត និងពិនិត្យឡើងវិញនូវច្បាប់ការពារសិទ្ធិរបស់បុគ្គល ក្នុងការរៀបចំអង្គការចូលជាសមាគម សម្តែងមតិ និងទទួលព័ត៌មាន ធានាឱ្យប្រព័ន្ធផ្សព្វផ្សាយ ស្ថាប័នស្រាវជ្រាវ និងសង្គមស៊ីវិល អាចអនុវត្តការត្រួតពិនិត្យមើល ប្រកបដោយប្រសិទ្ធភាពលើរចនាសម្ព័ន្ធរបស់រដ្ឋ អាចធ្វើរបាយការណ៍អំពីបញ្ហានោះ រួមទាំងផ្តល់ជាគំនិតដល់ដំណើរការនយោបាយ និង ផ្តល់ចំណេះដឹង ដោយមន្ត្រីអនុវត្តច្បាប់ ដើម្បីការពារសិទ្ធិទាំងនេះ | | | | | |
| ១.៤.១ ច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាល | ក្រ.មហាផ្ទៃ<br>ក.ក.ច.ន.យ<br>ក្រ.ពាណិជ្ជ<br>ក្រ.អ្នកច្បាប់<br>រដ្ឋសភា<br>ព្រឹទ្ធសភា | OHCHR-LAU<br>Star Kampuchea<br>Raj<br>KAF<br>KID<br>LICADHO<br>ADHOC<br>NGO Forum<br>CCC<br>Ponleu Khmer | ២០០៥-២០០៧ | ពិនិត្យមើលឡើងវិញនូវច្បាប់ដែលមានស្រាប់ ហើយសម្របសម្រួលទៅតាមស្តង់ដាអន្តរជាតិ | |
| ១.៤.២ ច្បាប់ស្តីពីរបបសារព័ត៌មាន | ក្រ.ព័ត៌មាន<br>ក្រ.មហាផ្ទៃ<br>ក្រ.វប្បធម៌ និងវិចិត្រសិល្បៈ<br>ក្រ.ទេសចរណ៍ | | ២០០៤-២០០៨ | ១-បង្កើតគណៈកម្មការពិភាក្សា កំណត់គោលនយោបាយ ស្តីពីរបបសារព័ត៌មាន<br>២-រៀបចំព្រាងច្បាប់ពាក់ព័ន្ធ<br>៣-ពិនិត្យ និងអនុម័តសេចក្តីព្រាច្បាប់ | ច្បាប់សារព័ត៌មានត្រូវបានសភាអនុម័តតាំងពីឆ្នាំ ១៩៩៥ ហើយសមាគមអ្នកសារព័ត៌មានក៏ត្រូវបានបង្កើតរួចហើយដែរព្រមទាំងក្រមសីលធម៌ |
| ១.៥ អត្ថិភាពនីតិវិធីនៅក្នុងក្របខ័ណ្ឌស្ថាប័នមួយឯករាជ្យ និងមានប្រសិទ្ធភាពសម្រាប់ចុះបញ្ជីកម្មសិទ្ធិ | | | | | |
| ១.៥.១ ការបង្កើតប្រព័ន្ធសុរិយោដី/សារការី ។ល។ | ក្រ.យុត្តិធម៌<br>ក្រ.មហាផ្ទៃ<br>តុលាការ<br>គណៈមេធាវី | | ២០០៤-២០០៨ | ១-ព្រាង និងអនុម័តច្បាប់ស្តីពីសារការី<br>២-ជ្រើសរើស និងបណ្តុះបណ្តាលសារការី | |

| | | | | | |
|---|---|---|---|---|---|
| ១.៦ អាទិភាពនៃមុខងារការពារសិទ្ធិប្រជាពលរដ្ឋ （OMBUDSMAN） | | | | | |
| ១.៦.១ ការបង្កើតការិយាល័យការពារសិទ្ធិប្រជាពលរដ្ឋ （OMBUDSMAN） | ក.ក.ច.ន.យ<br>ក្រសួងនានា | | ២០០៥-២០០៧ | ១- ផ្តួចផ្តើមការពិភាក្សាជាមួយអ្នកពាក់-ព័ន្ធទាំងអស់ រួមទាំងសង្គមស៊ីវិលលើមុខងារអំប៊ុសម៉ែន សម្រាប់បរិបទកម្ពុជា<br>២- លើមូលដ្ឋានអនុសាសន៍ខាងលើរៀបចំនីតិវិធីសម្រាប់ការតែងតាំងអំប៊ុសម៉ែន និងកំណត់ភារកិច្ចរបស់អំប៊ុសម៉ែន | |
| ១.៧ វិធានការប្រឆាំងនឹងឧក្រិដ្ឋកម្ម | | | | | |
| ១.៧.១ ការបង្កើតវិទ្យាស្ថានឧក្រិដ្ឋវិទ្យា | ក្រ.មហាផ្ទៃ<br>ក្រ.យុត្តិធម៌<br>ក្រុមអ្នកច្បាប់<br>ក.ក.ច.ន.យ<br>គណៈមេធាវី | | ២០០៤-២០០៨ | បង្កើតគណៈកម្មការពិនិត្យ ពិចារណាអំពីលទ្ធភាពបង្កើតវិទ្យាស្ថានឧក្រិដ្ឋវិទ្យា និងរៀបចំគម្រោងផែនការពាក់ព័ន្ធ | |

# ទិសដៅជាយុទ្ធសាស្ត្រទី ២

## អាទិភាពកំណត់៖

២.១.១ ក្រមរដ្ឋបាល និងក្រមនីតិវិធីរដ្ឋបាល

២.១.២ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី (ដំណាក់កាលទី ២)

២.១.៣ ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ (ដំណាក់កាលទី ២)

២.១.៤. ច្បាប់អង្គការស្តីពីការរៀបចំតុលាការ (ដំណាក់កាលទី ២)

២.១.៥ ច្បាប់ស្តីពីរដ្ឋបាលរបស់តុលាការ (ដំណាក់កាលទី ២)

២.១.៦ ច្បាប់ស្តីពីនគរបាល

២.១.៧ បទប្បញ្ញត្តិច្បាប់ដើម្បីធានាឯករាជ្យភាពនៃសេវាអយ្យការ

២.១.៨ ច្បាប់ស្តីពីប្រព័ន្ធពន្ធនាគារ និងការស្តារនីតិសម្បទា

២.១.១០ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម (ដំណាក់កាលទី ២)

២.១.១១ ច្បាប់អង្គការស្តីពីការគ្រប់គ្រងខេត្ត ក្រុង ។ល។

២.១.១២ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជជាតិ

២.៣.៤ បង្កើតអង្គភាពនីតិកម្មនៅក្នុងក្រសួងនីមួយៗ

| | | | | | |
|---|---|---|---|---|---|
| **ទិសដៅជាយុទ្ធសាស្ត្រ៖** ធ្វើទំនើបកម្មក្របខ័ណ្ឌច្បាប់ | | **លទ្ធផលរំពឹងទុក៖** ដំណើរការធ្វើច្បាប់ និងក្របខ័ណ្ឌច្បាប់ ត្រូវបានធ្វើទំនើបកម្ម ក្នុងគោលបំណងអនុវត្តនីតិរដ្ឋ ផ្អែកលើប្រព័ន្ធ-ឋានានុក្រមនៃច្បាប់ | | | |
| **សកម្មភាពជាអាទិភាព** | **ស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ** | **ស្ថាប័នដទៃទៀតដែលកំពុងមានការពាក់ព័ន្ធ** | **រយៈពេល** | **សកម្មភាពដែលត្រូវធ្វើ** | **សេចក្តីសង្កេតបន្ថែម** |
| ២.១ បង្កើយក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធវិសយ័យុត្តិធម៌ រួមទាំងច្បាប់រៀបចំអង្គការ សម្រាប់ស្ថាប័នវិសយ័យុត្តិធម៌ និងច្បាប់ដែលរដ្ឋធម្មនុញ្ញតម្រូវឱ្យធ្វើ ហើយនិងអនុវត្តការបែកមុខងារដាច់ពីគ្នារវាងអំណាចនានា | | | | | |
| ២.១.១ ព្រាង អនុម័ត និងអនុវត្ត ក្រមរដ្ឋបាល និងក្រម-នីតិវិធរដ្ឋបាល រួមទាំងវិធានច្បាប់សម្រាប់ការប្តឹងតវ៉ា | ក្រ.យុត្តិធម៌<br>ទី.គ.មន្ត្រី | | ២០០៥-២០០៨ | ១-បង្កើតក្រុមការងារបច្ចេកទេស ដើម្បីពិភាក្សាអំពីច្បាប់រដ្ឋបាល ហើយនិងអំពី | |

| | | | | | |
|---|---|---|---|---|---|
| (ឧទ្ធរណ៍) នៅតុលាការ | ក.ក.ច.ន.យ<br>ឧត្តម.ចៅក្រម | | | របៀបបញ្ចូលទៅក្នុងប្រព័ន្ធច្បាប់កម្ពុជា<br>២-ព្រាងក្រមដោយសហការយ៉ាងជិតស្និទ្ធ ជាមួយក្រសួងយុត្តិធម៌<br>៣-ចែកចាយក្រមដើម្បីសុំយោបល់<br>៤-ពិនិត្យនិងបញ្ជូនសេចក្តីព្រាងក្រមទៅ រដ្ឋសភាដើម្បីអនុម័ត<br>៥-អនុវត្តច្បាប់ : បណ្តុះបណ្តាលចៅក្រម មេធាវី សាស្ត្រាចារ្យច្បាប់<br>៦-បញ្ចូលក្រមទៅក្នុងកម្មវិធីសិក្សានៃសាលា បណ្តុះបណ្តាលវិជ្ជាជីវៈ និងសាកលវិទ្យាល័យ | |
| ២.១.២ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី | ក្រ.យុត្តិធម៌<br>ទី.គ.មន្ត្រី<br>ក្រុម.អ្នកច្បាប់<br>ក.ក.ច.ន.យ<br>រដ្ឋសភា<br>សាលាភូមិន្ទចៅក្រម<br>មជ្ឈមណ្ឌល.មេធាវី | | ដំណាក់កាលទី ២<br>២០០៦-២០០៨ | ១-អនុវត្តក្រម : បណ្តុះបណ្តាលចៅក្រម មេធាវី សាស្ត្រាចារ្យច្បាប់<br>២-បញ្ចូលក្រមទៅក្នុងកម្មវិធីសិក្សានៃ សាលា បណ្តុះបណ្តាលវិជ្ជាជីវៈ និង សាកលវិទ្យាល័យ | |
| ២.១.៣ ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ | ក្រ.យុត្តិធម៌<br>ទី.គ.មន្ត្រី<br>ក្រុម.អ្នកច្បាប់<br>ក.ក.ច..ន.យ<br>រដ្ឋសភា<br>សាលាភូមិន្ទចៅក្រម<br>មជ្ឈមណ្ឌល.មេធាវី | | ដំណាក់កាលទី ២<br>២០០៦-២០០៨ | ១-អនុវត្តក្រម : បណ្តុះបណ្តាលចៅក្រម មេធាវី សាស្ត្រាចារ្យច្បាប់<br>២-បញ្ចូលក្រមទៅក្នុងកម្មវិធីសិក្សានៃ សាលា បណ្តុះបណ្តាលវិជ្ជាជីវៈ និង សាកលវិទ្យាល័យ | |

| | | | | | |
|---|---|---|---|---|---|
| ២.១.៤ ច្បាប់អង្គការស្តីពីការរៀបចំតុលាការ | ក្រ.យុត្តិធម៌<br>ឧត្តម.ចៅក្រម<br>សា.ចៅក្រម<br>មជ្ឈមណ្ឌល.មេធាវី<br>សកលវិទ្យាល័យ<br>ក.ក.ច.ន.យ | | ដំណាក់កាលទី ២<br>២០០៦-២០០៨ | ១-រៀបចំរចនាសម្ព័ន្ធតុលាការឡើងវិញទៅតាមច្បាប់ថ្មី<br>២-បណ្តុះបណ្តាលមន្ត្រីតុលាការទៅ តាមខ្លឹមសារនៃច្បាប់ថ្មី | |
| ២.១.៥ ច្បាប់ស្តីពីរដ្ឋបាលរបស់តុលាការ | ក្រ.យុត្តិធម៌<br>ក.ក.ច.ន.យ<br>ឧត្ត.ចៅក្រម<br>ក្រ.ពាណិជ្ជ | | ២០០៤-២០០៧ | ១-ធ្វើការសិក្សាជាមូលដ្ឋានមួយមុននឹងតាក់តែងច្បាប់ដើម្បីស្វែងយល់ថាតើគួរធ្វើច្បាប់មួយដោយឡែក ឬបញ្ចូលបទបញ្ញត្តិសំខាន់ៗអំពីរដ្ឋបាលនេះទៅក្នុងក្រមថ្មីៗទាំងឡាយ<br>២-រៀបចំស្ថាប័នដែលទទួលបន្ទុកតាមផ្លូវច្បាប់នូវកាងាររដ្ឋបាលតុលាការ | ធានាថាគំនិតផ្តួចផ្តើមពាក់ព័ន្ធទាំងអស់ស៊ីសង្វាក់គ្នាជាមួយនឹងគំនិត ដែលមានរួចហើយចំពោះច្បាប់ដ៏ទៃទៀត |
| ២.១.៦ ច្បាប់ស្តីពីនគរបាល | ក្រ.សួងមហាផ្ទៃ<br>ក្រ.យុត្តិធម៌<br>តុលាការ<br>គណៈមេធាវី<br>ក្រុមអ្នកច្បាប់ | | ២០០៤-២០០៨ | ១-សិក្សាស្វែងយល់អំពីស្ថានភាពបច្ចុប្បន្ននៃនគរបាលជាតិ<br>២-រៀបចំព្រាង និងអនុម័តច្បាប់<br>៣-កែសំរួលលិខិតបទដ្ឋានពាក់ព័ន្ធទៅនឹងលក្ខខ័ណ្ឌជ្រើសរើសនគរបាល និងធ្វើការបណ្តុះបណ្តាលឱ្យមានគុណភាពល្អ | |
| ២.១.៧ បទប្បញ្ញត្តិច្បាប់ដើម្បីធានាឯករាជ្យភាពនៃសេវាអយ្យការ | ក្រ.យុត្តិធម៌<br>អយ្យការតុលាការ<br>ឧត្តម. ចៅក្រម<br>ក.ក.ច.ន.យ | ប្រទេសបារាំង | ២០០៥-២០០៨ | រៀបចំឯកសារស្តីពីជម្រើសនយោបាយដាក់ជូនអង្គភាពសម្របសម្រួលធ្វើការពិចារណា និងពិនិត្យផលប៉ះពាល់ដល់ក្រុមសំខាន់នានា | |

| | | | | | |
|---|---|---|---|---|---|
| ២.១.៨ ច្បាប់ស្តីពីប្រព័ន្ធពន្ធនាគារ និងការស្តារនីតិសម្បទា | ក្រ.មហាផ្ទៃ<br>ក្រ.យុត្តិធម៌<br>តុលាការ<br>គណៈមេធាវី<br>ក្រុមអ្នកច្បាប់<br>មជ្ឈមណ្ឌល-មេធាវី | | ២០០៤-២០០៨ | ១-សិក្សាស្វែងយល់ពីស្ថានភាពពន្ធនាគារបច្ចុប្បន្ន<br>២-កំណត់គោលនយោបាយអំពីប្រព័ន្ធពន្ធនាគារសម្រាប់កម្ពុជា<br>៣-សិក្សារៀបចំព្រាង និងអនុម័តច្បាប់ | |
| ២.១.១០ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម | ឧត្តម.ចៅក្រម<br>ក្រ.យុត្តិធម៌<br>សាលាជំរះក្តី<br>រដ្ឋសភា<br>ព្រឹទ្ធសភា<br>សា.ចៅក្រម<br>មជ្ឈមណ្ឌល.មេធាវី<br>សកលវិទ្យាល័យ | | ដំណាក់កាលទី ២<br>២០០៦-២០០៧ | ១-រៀបចំលក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើសចៅក្រម និងព្រះរាជអាជ្ញាឱ្យមានតម្លាភាព<br>២-បណ្តុះបណ្តាលចៅក្រម និងព្រះរាជអាជ្ញាតាមខ្លឹមសារនៃច្បាប់ថ្មី និងបញ្ចូលច្បាប់ថ្មីទៅក្នុងកម្មវិធីសិក្សាសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ និងមហាវិទ្យាល័យច្បាប់នានា | |
| ២.១.១១ ច្បាប់អង្គការស្តីពីការគ្រប់គ្រងខេត្ត ក្រុង ។ល។ | ក្រ.មហាផ្ទៃ<br>ក្រុមអ្នកច្បាប់<br>ទី.គ.មន្ត្រី<br>ក.ក.រ<br>ក្រ.សេដ្ឋកិច្ច<br>ក.ក.ថ.ន.យ<br>គ្រប់ក្រសួងស្ថាប័នឯទៀត | | ២០០៤-២០០៨ | ១-កំណត់គោលនយោបាយជាតិស្តីពីការគ្រប់គ្រងខេត្ត ក្រុង ស្រុក ខ័ណ្ឌ<br>២-ព្រាង និងអនុម័តច្បាប់<br>៣-អប់រំ និងបណ្តុះបណ្តាលមន្ត្រីពាក់ព័ន្ធអំពីខ្លឹមសារនៃច្បាប់ថ្មី<br>៤-កំណត់ និងដាក់ឱ្យអនុវត្តនូវវិធានការចាំបាច់នានា ដើម្បីអនុវត្តច្បាប់ | |

| | | | | | |
|---|---|---|---|---|---|
| ២.១.១២ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃសមាជជាតិ | ទី.គ.រដ្ឋមន្ត្រី<br>ក្រ.មហាផ្ទៃ<br>ក្រ.យុត្តិធម៌<br>ក្រ.ព័ត៌មាន | | ២០០៤-២០០៨ | ១-ព្រាង និងអនុម័តច្បាប់<br>២-ពង្រឹងអង្គភាពទទួលខុសត្រូវការងារសមាជជាតិតាមការកំណត់របស់ច្បាប់ | |
| ២.៣ ផ្តល់នូវដំណើរការធ្វើច្បាប់មួយមានប្រសិទ្ធភាព ស៊ីសង្វាក់គ្នា និងមានការចូលរួមផ្អែកលើឋានានុក្រមនៃច្បាប់ ដោយមានសេចក្តីណែនាំជាក់លាក់ អំពីការធ្វើច្បាប់ និងមានបទដ្ឋានអំពីការពិនិត្យឡើងវិញផ្នែកបច្ចេកទេស រួមទាំងការយកចិត្តទុកដាក់ការអនុវត្តស្តង់ដាអន្តរជាតិ និងពង្រឹងអង្គភាពនានា ដែលពាក់ព័ន្ធនៅក្នុងការអនុម័តច្បាប់ថ្មីៗ និងការធ្វើវិសោធនកម្មច្បាប់ ព្រមទាំងផ្តល់នូវការបណ្តុះបណ្តាលអំពីការព្រាងច្បាប់ដល់មន្ត្រីពាក់ព័ន្ធនៅក្នុងសកម្មភាពនេះនៅក្នុងរដ្ឋាភិបាលទាំងមូល | | | | | |
| ២.៣.៤ បង្កើតអង្គភាពនីតិកម្មនៅក្នុងក្រសួងនីមួយៗ | ក្រ.អ្នកច្បាប់<br>ទី.គ.មន្ត្រី<br>គ្រប់ក្រសួង-ស្ថាប័នទាំងអស់ | | ២០០៤-២០០៧ | ១-ធ្វើផែនការតាក់តែងច្បាប់ ឱ្យស្របតាមបញ្ជីមេ (សូមអានសកម្មភាពលេខ២.៣.១)<br>២-រៀបចំកម្មវិធីពង្រឹងអង្គភាពមានស្រាប់ទៅតាមក្រសួងនីមួយៗ រួមទាំងកម្មវិធីបណ្តុះបណ្តាលការងារតាក់តែងច្បាប់ (សូមអានសកម្មភាពលេខ ២.៣.១ និងទិសដៅលេខ៧)<br>៣-បញ្ចូនីតិវិធីតាក់តែងច្បាប់ និងមគ្គុទេសក៏ស្តីពីការតាក់តែងច្បាប់ និងធានាភាពរលូនក្នុងការធ្វើច្បាប់ (សូមអានសកម្មភាពលេខ ២.៣.១)<br>៤- រៀបចំយន្តការច្បាស់លាស់សម្រាប់សម្របសម្រួល និងទំនាក់ទំនងការងារជាមួយអគ្គ-នាយកដ្ឋានរាជកិច្ចទីស្តីការគណៈរដ្ឋមន្ត្រី | កិច្ចការនេះបានចាប់ផ្តើម រួចហើយនៅទីស្តីការគណៈរដ្ឋមន្ត្រី |

**អាទិភាពកំណត់៖**

៣.១.២ ការផ្តល់សទ្ទានុក្រមជាបីភាសា

៣.៣.២ ការទទួលសាធារណជន (ការិយាល័យ) និងមុខងារព័ត៌មាននៅក្នុងតុលាការ

| **ទិសដៅយុទ្ធសាស្ត្រ៖** ផ្តល់លទ្ធភាពឱ្យទទួលព័ត៌មានអំពីច្បាប់ និងតុលាការឱ្យកាន់តែប្រសើរឡើង | | **លទ្ធផលរំពឹងទុក៖** ការយល់ដឹងជាសាធារណៈត្រូវបានលើកកំពស់ ហើយចំណេះដឹង និងលទ្ធភាពទទួលបានព័ត៌មានច្បាប់ និងយុត្តិធម៌ កាន់តែប្រសើរ | | | |
|---|---|---|---|---|---|
| **សកម្មភាពជាអាទិភាព** | **ស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ** | **ស្ថាប័នដទៃទៀតដែលកំពុងមានការពាក់ព័ន្ធ** | **រយៈពេល** | **សកម្មភាពដែលត្រូវធ្វើ** | **សេចក្តីសង្កេតបន្ថែម** |
| ៣.១ បោះពុម្ពច្បាប់ទាំងឡាយដែលមាន និងនីតិកម្មពាក់ព័ន្ធទាំងអស់ រួមទាំងសេចក្តីណែនាំ និងទម្លាប់អនុវត្ត ជាភាសាខ្មែរ ការបោះពុម្ពច្បាប់ថ្មី និងនីតិកម្មពាក់ព័ន្ធទាំងអស់ជាផ្លូវការ ឱ្យទាន់ពេលវេលា និងបានសព្វគ្រប់ ដូចជារាជកិច្ច សម្រាប់សេចក្តីត្រូវការរបស់ចៅក្រម មេធាវី និស្សិតច្បាប់ មន្ត្រីរដ្ឋាភិបាល ផ្នែកឯកជន សង្គមស៊ីវិល និងភាគីមានផលប្រយោជន៍ដទៃទៀត | | | | | |
| ៣.១.២ ការផ្តល់សទ្ទានុក្រមជាបីភាសា | ទី.គ.មន្ត្រី<br>ក្រ.យុត្តិធម៌<br>ក្រុ.អ្នកច្បាប់ | KAF<br>JICA | ២០០៤-២០០៨ | ១-បន្តការងាររបស់គណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់<br>២- រៀបចំសេចក្តីណែនាំ លើការប្រើសទ្ទានុក្រម | គម្រោងកំពុងមានដំណើរការ<br><br>សេចក្តីព្រាងសទ្ទានុក្រម បានចាប់ផ្តើមនៅខែមេសា ឆ្នាំ ២០០៣ ជាមួយនឹងការបង្កើតគណៈកម្មាធិការសទ្ទានុក្រម ដោយអនុក្រឹត្យលេខ ៣៦ ចុះថ្ងៃទី ១៤ ខែឧសភាឆ្នាំ២០០៣ គណៈកម្មាធិការខាងលើជួបប្រជុំរៀងរាល់សប្តាហ៍ |

| ៣.៣ ជំរុញឱ្យស្ថាប័នពាក់ព័ន្ធនីមួយៗផ្តល់ព័ត៌មានពាក់ព័ន្ធ និងការណែនាំដល់សាធារណជន និងអ្នកប្រើប្រាស់តុលាការ និងស្ថាប័នរដ្ឋបាល | | | | | |
|---|---|---|---|---|---|
| ៣.៣.២ ការទទួលសាធារណជន (ការិយាល័យ) និងមុខងារព័ត៌មាននៅក្នុងតុលាការ | សាលាជំរះក្តី<br>ក្រ.យុត្តិធម៌<br>ឧត្តម.ចៅក្រម | | ២០០៥-២០០៧ | រចនាសៀវភៅព័ត៌មានឯកភាពគ្នាមួយ (តាមប្រព័ន្ធកុំព្យូទ័រ) សម្រាប់បញ្ចូលទៅក្នុងប្រព័ន្ធតុលាការ ។ ព័ត៌មានប្រមូលបាននៅក្នុងសៀវភៅនេះប្រើសម្រាប់រៀបចំស្ថិតិអំពីប្រព័ន្ធតុលាការ និងសម្រាប់រៀបចំ ប្រព័ន្ធផែនការធ្វើឱ្យប្រសើរឡើងនូវរដ្ឋបាលតុលាការ (សូមអានទិសដៅ-លេខ ២ និងលេខ ៥) ។ | សៀវភៅព័ត៌មានសម្រាប់សាធារណ-ជន មានប្រើនៅក្នុងសាលាជំរះក្តីខេត្តកណ្តាល និងសាលាជំរះក្តីដទៃទៀតតែពុំដូចគ្នាឡើយ ។ |

**អាទិភាពកំណត់:**

៤.១.១ គោលនយោបាយ និងលិខិតបទដ្ឋានស្តីពីតំណាងផ្នែកច្បាប់ និងជំនួយផ្នែកច្បាប់ រួមទាំងការធានានូវសេរីភាពរបស់អង្គការមិនមែនរដ្ឋាភិបាលដើម្បីផ្តល់ជំនួយផ្នែកច្បាប់ ( ដំណាក់កាលទី ២ )

៤.២.៣ ការកែលំអសីលធម៌សម្រាប់មេធាវី រួមទាំងការដាក់វិន័យឱ្យមានប្រសិទ្ធភាព ដោយក្រុមប្រឹក្សាវិន័យនៅក្នុងគណៈមេធាវីស្របតាមគោលការណ៍សីលធម៌ ដែលបានផ្តល់ឱ្យសម្រាប់មេធាវី

| **ទិសដៅយុទ្ធសាស្ត្រ:** ធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃដំណើររឿងក្តីនិងសេវាពាក់ព័ន្ធ | | **លទ្ធផលរំពឹងទុក:** ដំណើរការត្រឹមត្រូវចំពោះមុខស្ថាប័នរដ្ឋបាល និងតុលាការ និងសិទ្ធិនៃការប្តឹងតវ៉ារបស់ជនគ្រប់រូបត្រូវបានធានា | | | |
|---|---|---|---|---|---|
| **សកម្មភាពជាអាទិភាព** | **ស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ** | **ស្ថាប័នផ្សេងទៀតដែលកំពុងមានការពាក់ព័ន្ធ** | **រយៈពេល** | **សកម្មភាពដែលត្រូវធ្វើ** | **សេចក្តីសង្កេតបន្ថែម** |
| ៤.១ ផ្តល់សេវាកម្មជំនួយផ្នែកច្បាប់ មានគុណភាពខ្ពស់ ងាយរក ស្របទៅតាមសេចក្តីត្រូវការរបស់ពលរដ្ឋ | | | | | |
| ៤.១.១ គោលនយោបាយ និងលិខិតបទដ្ឋានស្តីពីតំណាងផ្នែកច្បាប់ និង ជំនួយផ្នែកច្បាប់រួមទាំងការធានានូវសេរីភាពរបស់អង្គការមិនមែនរដ្ឋាភិបាលដើម្បីផ្តល់ជំនួយផ្នែកច្បាប់ | ក្រ.យុត្តិធម៌<br>គណៈមេធាវី<br>ក.ក.ច.ន.យ<br>មជ្ឈមណ្ឌល.មេធាវី | ប្រទេសបារាំង<br>ប្រទេសជប៉ុន<br>CDP<br>LAC<br>CLEC<br>EWMI<br>Licadho<br>Adhoc<br>Other NGOs | ដំណាក់កាលទី២<br>២០០៦-២០០៨ | រៀបចំគោលនយោបាយ និងបទប្បញ្ញត្តិស្តីពីតំណាងផ្នែកច្បាប់ និងជំនួយផ្នែកច្បាប់លើមូលដ្ឋាននៃការស្ទង់មតិក្នុងដំណាក់កាលទី១ និងរៀបចំកម្មវិធីបណ្តុះបណ្តាលទៅតាមតម្រូវការ ធ្វើវិមជ្ឈការកម្មវិធីជំនួយផ្នែកច្បាប់ ។ | |

| ៤.២. បង្កើនចំនួនមេធាវីយោងតាមលក្ខណៈវិនិច្ឆ័យដែលរៀបចំសម្រាប់ផ្តល់យោបល់ផ្នែកច្បាប់ និងសេវាដទៃទៀតដល់គូវិវាទ និងកូនក្តីដទៃទៀត សម្រាប់ប្រជាពលរដ្ឋទាំងអស់ក្នុងប្រទេស និងជនបរទេសដែលពាក់ព័ន្ធ ឬកំពុងតែពាក់ព័ន្ធនៅកម្ពុជា រួមមានការផ្តល់ការបណ្តុះបណ្តាលសមស្របដល់និស្សិតច្បាប់ កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈបន្ត ដើម្បីធានាឱ្យការផ្តល់យោបល់ជូនអតិថិជននូវជំនួយផ្នែកច្បាប់មានគុណភាពខ្ពស់ តាមការដែលអាចធ្វើទៅបាន | | | | | |
|---|---|---|---|---|---|
| ៤.២.៣ ការកែលំអសីលធមិសម្រាប់មេធាវី រួមទាំងការដាក់វិន័យឱ្យមានប្រសិទ្ធភាព ដោយក្រុមប្រឹក្សាវិន័យនៅក្នុងគណៈមេធាវីស្របតាមគោលការណ៍សីលធមិ ដែលបានផ្តល់ឱ្យសម្រាប់មេធាវី | ក្រ.យុត្តិធមិ<br>មជ្ឈមណ្ឌល.មេធាវី<br>គណៈមេធាវី | | ២០០៤-២០០៧ | ១-ពិនិត្យច្បាប់ស្តីពីលក្ខន្តិកៈមេធាវីឡើងវិញ<br>២-ពង្រឹងក្រុមប្រឹក្សាវិន័យរបស់គណៈមេធាវី និងបទបញ្ជាផ្ទៃក្នុង<br>៣-បញ្ចូលគោលការណ៍សីលធមិក្នុងកម្មវិធីសិក្សាមជ្ឈមណ្ឌលបណ្តុះ-បណ្តាលមេធាវី និងកម្មវិធីបណ្តុះបណ្តាលបន្ត | គម្រោងកំពុងមានដំណើរការ |

## ទិសដៅយុទ្ធសាស្ត្រទី ៥

**អាទិភាពកំណត់:**

៥.២.២ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលមានដំណើរការពេញលេញធានាបាននូវតម្លាភាពក្នុងការតែងតាំង ការតម្លើងស័ក្តិ បៀវត្ស និងការដាក់វិន័យចៅក្រម និងព្រះរាជអាជ្ញា (ដំណាក់កាលទី២)

៥.២.៤ រៀបចំក្រមសីលធម៌សម្រាប់ចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីយុត្តិធម៌ (ជាចង្កោមជាមួយសកម្មភាពលេខ ៥.៥.៥ )

៥.៣.៣ រៀបចំសេចក្តីណែនាំអំពីការគ្រប់គ្រងសំណុំរឿងក្តី និងតុលាការស្របទៅតាមបទប្បញ្ញត្តិ នៃក្រមនីតិវិធី ច្បាប់អង្គការស្តីពីការរៀបចំតុលាការ និងច្បាប់ស្តីពីរដ្ឋបាលតុលាការ (ជាចង្កោមជាមួយសកម្មភាព ៥,៣,២ និង ៥,៤,៣)

៥.៤.១ គោលនយោបាយរដ្ឋស្តីពីការបែងចែកថវិកាឱ្យតុលាការ (ភាគរយកំណត់របស់ថវិការដ្ឋាភិបាល)

៥.៤.៣ បំពាក់សម្ភារៈបរិក្ខារជូនតុលាការគ្រប់គ្រាន់ទាន់សម័យ រួមទាំងបរិក្ខារបច្ចេកវិទ្យាព័ត៌មានដែលពាក់ព័ន្ធ (ជាចង្កោមជាមួយសកម្មភាព ៥,៣,២ និង ៥,៣,៣)

៥.៤.៤ វិធានការបង្កើតតុលាការ/សភាពាណិជ្ជកម្ម និងតុលាការ/សភាឯកទេសផ្សេងទៀត រួមទាំងបែបបទ តុលាការពាណិជ្ជកម្ម និងការបណ្តុះបណ្តាលអ្នកឯកទេសផ្នែកច្បាប់ពាណិជ្ជកម្ម (ដំណាក់កាលទី ២)

៥.៤.៥ វិធានការបង្កើតតុលាការរដ្ឋបាល (ដំណាក់កាលទី ២)

៥.៥.២ បង្កើតស្ថាប័នសម្រាប់អនុវត្តសាលក្រម

៥.៥.៥ បញ្ចូលគោលការណ៍ក្រមសីលធម៌ទៅក្នុងកម្មវិធីសម្រាប់ការអប់រំមន្ត្រីតុលាការ នគរបាល មន្ត្រីពន្ធនាគារ និងមន្ត្រីរាជការឯទៀត

<table>
<tr><td colspan="3">ទិសដៅយុទ្ធសាស្ត្រៈ ពង្រឹងសេវាកម្មយុត្តិធម៌រួមមានអំណាចតុលាការ និងសេវាកម្មអយ្យការ</td><td colspan="3">លទ្ធផលរំពឹងទុក : តុលាការឯករាជ្យ និងមានដំណើរការល្អប្រសើរត្រូវបានធានា</td></tr>
<tr><th>សកម្មភាពជាអាទិភាព</th><th>ស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ</th><th>ស្ថាប័នដទៃទៀតដែលកំពុងមានការពាក់ព័ន្ធ</th><th>រយៈពេល</th><th>សកម្មភាពដែលត្រូវធ្វើ</th><th>សេចក្តីសង្កេតបន្ថែម</th></tr>
<tr><td colspan="6">៥.២ បង្កើនការទទួលខុសត្រូវ ដោយធានាឱ្យមានលទ្ធភាពទទួលបាននូវការវិនិច្ឆ័យត្រឹមត្រូវ យោងទៅតាមច្បាប់ពាក់ព័ន្ធ អាចប្តឹងតវ៉ាបាន និងមានប្រព័ន្ធមួយមានតម្លាភាពស្តីពីការតែងតាំង ការតម្លើងឋានន្តរស័ក្តិនិងថ្នាក់ប្រាក់បៀវត្សចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីតុលាការដទៃទៀត និងវិធានការវិន័យដល់ព្រះរាជអាជ្ញា ចៅក្រម និងមន្ត្រីតុលាការដទៃទៀត ផ្អែកលើវិធាននិងលក្ខណវិនិច្ឆ័យ ដែលមានចែងក្នុងច្បាប់ និងដែលអនុវត្តតាមរយៈស្ថាប័នឯករាជ្យមួយ ដែលមានធនធានគ្រប់គ្រាន់ រួមមានការបង្កើតក្រមសីលធម៌ និងវិធានស្តីពីទំនាស់ផលប្រយោជន៍ សម្រាប់ចៅក្រម ព្រះរាជអាជ្ញានិងមន្ត្រីតុលាការដទៃទៀតទាំងអស់ គួបជាមួយនឹងវិធានការវិន័យពាក់ព័ន្ធ</td></tr>
</table>

| | | | | | |
|---|---|---|---|---|---|
| ៥.២.២ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលមានដំណើរការពេញលេញធានាបាននូវតម្លាភាព ក្នុងការតែងតាំង ការតម្លើងស័ក្តិ បៀវត្ស និងការដាក់វិន័យចៅក្រម និងព្រះរាជអាជ្ញា | ឧត្តម,ចៅក្រម<br>ក្រ .យុត្តិធម៌<br>សាលាចៅក្រម<br>ក.ក.ច.ន.យ<br>ក្រ.សេដ្ឋ.ហិរ<br>រដ្ឋសភា<br>ព្រឹទ្ធសភា | **Aus-Aid**<br>UNDP | ដំណាក់កាលទី ២<br>២០០៧-២០០៨ | ១-រៀបចំគម្រោងសកម្មភាពពង្រឹងឧត្តម-ក្រុមប្រឹក្សានៃអង្គចៅក្រម ដោយផ្តោតជាពិសេសលើការអនុវត្តច្បាប់ យន្តការធ្វើផែនការ ការផ្តល់ថវិកា<br>( សូមអានទិសដៅ យុទ្ធសាស្ត្រទី ៧ )<br>២-រៀបចំលក្ខណៈវិនិច្ឆ័យ/ប្រព័ន្ធឯកភាពគ្នាមួយសម្រាប់ការតែងតាំង ការតម្លើងថ្នាក់ និង ឋានន្តរស័ក្តិ ការដាក់វិន័យ និងប្រាក់បៀវត្សចៅក្រម ព្រះរាជអាជ្ញា និងធានាតម្លាភាព ក្នុងគ្រប់សកម្មភាព<br>៣-រៀបចំ និងអនុវត្តប្រព័ន្ធសុចរិតភាពតុលាការ និងការត្រួតពិនិត្យការគ្រប់គ្រងរឿងក្តី ធានាឱ្យមានការគាំទ្រផ្នែកព័ត៌មានវិទ្យា និងការពិគ្រោះយោបល់/ការបណ្តុះបណ្តាលជាមួយចៅក្រម<br>៤-ពង្រឹងយន្តការសម្របសម្រួលអន្តរស្ថាប័នដែលមានស្រាប់ ជាពិសេសជាមួយក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ និង ក.ក.ច.ន.យ | |
| ៥.២.៤ រៀបចំក្រមសីលធម៌សម្រាប់ចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីយុត្តិធម៌ | ឧត្តម.ចៅក្រម<br>ក្រ.យុត្តិធម៌<br>សា.ចៅក្រម<br>ស.នីតិសាស្ត្រ<br>ក.ក.ច.ន.យ | Aus-Aid | ២០០៦-២០០៧<br>( ដំណាក់កាលទី ២) | ១-រៀបចំក្រមសីលធម៌សម្រាប់ចៅក្រម និងព្រះរាជអាជ្ញា<br>២-បញ្ចូលក្រមសីលធម៌ទៅក្នុងកម្មវិធីសិក្សានៅសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ និងមហាវិទ្យាល័យច្បាប់នានា | កម្មវិធីកសាងសមត្ថភាព បានធ្វើជូនមន្ត្រីបច្ចេកទេសនៅលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងការរៀបចំដើម្បីធ្វើការកែទម្រង់( ជាចង្កោមជាមួយសកម្មភាពលេខ ៥.៥.៥ ) |

| | | | | | |
|---|---|---|---|---|---|
| ៥.៣ បញ្ចូលការគ្រប់គ្រងដូចគ្នាសម្រាប់រឿងក្តីដូចគ្នា និងបច្ចេកទេសគ្រប់គ្រងតុលាការ ដើម្បីធានាឱ្យដំណើរការមានតម្លាភាព និងតាមពេលកំណត់ រួមទាំងយន្តការប្តឹងតវ៉ាស៊ីសង្វាក់គ្នា | | | | | |
| ៥.៣.៣ រៀបចំសេចក្តីណែនាំអំពីការគ្រប់គ្រងសំណុំរឿងក្តី និង តុលាការស្របទៅតាមបទបញ្ញត្តិនៃក្រមនីតិវិធីច្បាប់ អង្គការស្តីពីការរៀបចំតុលាការ និងច្បាប់ស្តីពីរដ្ឋបាលតុលាការ | ក្រ.យុត្តិធម៌ ឧត្តម.ចៅក្រម សាលាជំរះក្តី ក.ក.ច.ន.យ | Aus-Aid | ២០០៤-២០០៨ | រៀបចំសេចក្តីណែនាំឯកភាពគ្នាមួយលើការគ្រប់គ្រងរឿងក្តី និងតុលាការ ផ្សារភ្ជាប់ទៅនឹងគំនិតផ្តួចផ្តើមនាពេលបច្ចុប្បន្នចំពោះរឿងនេះ (ដូចជាករណីនៅខេត្តកណ្តាល) និងដោយយកចិត្តទុកដាក់ចំពោះនីតិវិធីដែលត្រូវបញ្ចូលតាមរយៈក្រមថ្មី និងបទប្បញ្ញត្តិនានានៃច្បាប់ស្តីពីការរៀបចំតុលាការ និងច្បាប់ស្តីពីរដ្ឋបាលតុលាការ | (ជាចង្កោមជាមួយសកម្មភាពលេខ ៥៣២ និង ៥៤៣) |
| ៥.៤ ផ្តល់មធ្យោបាយគ្រប់គ្រាន់ ឱ្យប្រព័ន្ធតុលាការបានទៅដល់ពលរដ្ឋកម្ពុជា រួមទាំងធានាផ្តល់បៀវត្សគ្រប់គ្រាន់ជូនមន្ត្រីតុលាការ ផ្តល់ការអប់រំមានគុណភាព និងការសិក្សាចាំបាច់បន្ថែម ធ្វើឱ្យមានការិយាល័យតុលាការគ្រប់គ្រាន់ បំពាក់ដោយសម្ភារៈមូលដ្ឋាន និងមានធនធានមនុស្សគ្រប់គ្រាន់ទូទាំងប្រទេស និងបង្កើតតុលាការពិសេស ដែលមានចំណេះដឹងឯកទេសចាំបាច់ | | | | | |
| ៥.៤.១ គោលនយោបាយរដ្ឋស្តីពីការបែងចែកថវិកាឱ្យតុលាការ (ភាគរយកំណត់ក្នុងថវិការដ្ឋ) | ទី.គ.មន្ត្រី ក្រ.សេដ្ឋ.ហិរ ក្រ.យុត្តិធម៌ ឧត្តម.ចៅក្រម ក.ក.ច.ន.យ | Aus-Aid | ២០០៤-២០០៨ | ១-តាក់តែងគោលនយោបាយរដ្ឋស្តីពីថវិកាសម្រាប់តុលាការ ដែលឆ្លុះបញ្ចាំងនូវការយកចិត្តទុកដាក់ដល់ឯករាជ្យភាពតុលាការ<br>២-តម្លើងជាលំដាប់នូវថវិកាជូនតុលាការឱ្យបានគ្រប់គ្រាន់ស្របតាមអាណត្តិកំណត់<br>៣-រៀបចំប្រព័ន្ធផែនការកម្មថវិកាសម្រាប់តុលាការ | ប្រាក់បៀវត្សចៅក្រម ត្រូវបានតម្លើងដោយអនុក្រឹត្យលេខ ១១៣ ចុះថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ២០០២ |

| | | | | | |
|---|---|---|---|---|---|
| ៥.៤.៣ បំពាក់សម្ភារៈបរិក្ខារជូនតុលាការឱ្យបានគ្រប់គ្រាន់ ទាន់សម័យ រួមទាំងបរិក្ខារបច្ចេកវិទ្យាព័ត៌មានដែលពាក់ព័ន្ធ | ក្រ.យុត្តិធម៌<br>ឧត្តម,ចៅក្រម<br>សាលាដំរះក្តី<br>ក.ក.ច.ន.យ | Ausd-Aid | ២០០៤-២០០៨ | ១-រៀបចំគម្រោងមូលដ្ឋានមួយកែទម្រង់រចនាសម្ព័ន្ធតុលាការបច្ចុប្បន្ន ធានាភាពស៊ីសង្វាក់គ្នាជាមួយសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំតុលាការ និងច្បាប់ពាក់ព័ន្ធផ្សេងៗទៀត ផ្អែកលើបទពិសោធន៍ដែលទទួលបានពីការរៀបចំតុលាការគំរូនៅខេត្តកណ្តាលរួមមាន តម្រូវការផ្អែកហេដ្ឋារចនាសម្ព័ន្ធទំនើប ការបណ្តុះ-បណ្តាលមន្ត្រីតុលាការ បញ្ញាថវិកា ។ល។<br>២-បន្តការកែទម្រង់ជាជំហានៗក្នុងប្រព័ន្ធតុលាការ | ជាចង្កោមជាមួយសកម្មភាព ៥.៣.២ និង ៥.៣.៣ |
| ៥.៤.៤ វិធានការបង្កើតតុលាការ/សភាពាណិជ្ជកម្ម និងតុលាការ/សភាឯកទេសផ្សេងទៀត រួមទាំងបែបបទតុលាការពាណិជ្ជកម្ម និងការបណ្តុះបណ្តាលអ្នកឯកទេសផ្នែកច្បាប់ពាណិជ្ជកម្ម | ក្រ.ពាណិជ្ជ<br>សា,ចៅក្រម<br>មហា.ច្បាប់<br>ឧត្តម,ចៅក្រម<br>ក្រ.យុត្តិធម៌<br>ក.ក.ច.ន.យ | CIDA | ដំណាក់កាលទី ២<br>២០០០៧-២០០៨ | បញ្ចូលការបណ្តុះបណ្តាលឯកទេសច្បាប់ពាណិជ្ជកម្មក្នុងមហាវិទ្យាល័យច្បាប់និងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ | សេចក្តីព្រាងច្បាប់បានធ្វើហើយ |
| ៥.៤.៥ វិធានការបង្កើតតុលាការរដ្ឋបាល | ទី.គ.មន្ត្រី<br>ឧត្តម.ចៅក្រម<br>ក្រ.យុត្តិធម៌<br>តុលាការកំពូល<br>ក្រុ.អ្នកច្បាប់ | ប្រទេសបារាំង | ២០០៦-២០០៨<br>(ដំណាក់កាលទី ២) | ១-រៀបចំបង្កើតតុលាការរដ្ឋបាល<br>២- បញ្ចូលការបណ្តុះបណ្តាលឯកទេសច្បាប់រដ្ឋបាល ក្នុងមហាវិទ្យាល័យច្បាប់និងសាលាវិជ្ជាជីវៈ | |

| | | | | | |
|---|---|---|---|---|---|
| ៥.៥ ធានាការអនុវត្តសេចក្តីសម្រេចរបស់តុលាការ និងឯករាជ្យភាពរបស់តុលាការដោយផ្តល់ នូវក្របខ័ណ្ឌច្បាប់ និងស្ថាប័ន បន្ថែមដោយធនធាន និងការបណ្តុះបណ្តាលចាំបាច់ និងធ្វើការបណ្តុះបណ្តាលអំពីការអនុវត្តសាលក្រម ហើយនិងយន្តការអនុវត្តសម្រាប់ដាក់ទណ្ឌកម្មដល់ការខ្វះខាតចំពោះការអនុវត្ត និងការដាក់ទណ្ឌកម្មដល់ការជ្រៀតជ្រែកដល់ការងាររបស់មន្ត្រីតុលាការ | | | | | |
| ៥.៥.២ បង្កើតស្ថាប័នសម្រាប់អនុវត្តសាលក្រម | ក្រ.សួងយុត្តិធម៌<br>តុលាការ<br>ក្រុមអ្នកច្បាប់ | | ២០០៤-២០០៨ | ១-ព្រាង និងអនុម័តច្បាប់ ស្តីពីអាជ្ញាសាលា<br>២-បណ្តុះបណ្តាលអាជ្ញាសាលា | |
| ៥.៥.៥ ញួលគោលការណ៍ក្រមសីលធម៌ទៅក្នុងកម្មវិធីសម្រាប់ការអប់រំមន្ត្រីតុលាការ នគរបាល មន្ត្រីពន្ធនាគារ និងមន្ត្រីរាជការឯទៀត | ក្រ.មហាផ្ទៃ<br>សា.ចៅក្រម<br>សាលាផ្សេងទៀតនៃវិស័យយុត្តិធម៌ | | ២០០៤-២០០៧ | រៀបចំស្តង់ដាក្រមសីលធម៌ឱ្យស្របគ្នានឹងស្តង់ដាអន្តរជាតិ | (ជាចង្កោមជាមួយសកម្មភាព លេខ ៥.៤.២) |

**អាទិភាពកំណត់:**

៦.១.១ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ( ដំណាក់កាលទី ២ )

| **ទិសដៅជាយុទ្ធសាស្ត្រ:** បញ្ចូលយន្តការដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ | | **លទ្ធផលរំពឹងទុក :** ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដែលដំណើរការល្អប្រសើរ និងយន្តការសន្ទានកម្មត្រូវបានបង្កើតដើម្បីដោះស្រាយវិវាទពាណិជ្ជកម្ម និងវិវាទតូចតាចនៅក្នុងកម្រិតសហគមន៍ | | | |
|---|---|---|---|---|---|
| **សកម្មភាពជាអាទិភាព** | **ស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ** | **ស្ថាប័នដទៃទៀតដែលកំពុងមានការពាក់ព័ន្ធ** | **រយៈពេល** | **សកម្មភាពដែលត្រូវធ្វើ** | **សេចក្តីសង្កេតបន្ថែម** |
| ៦.១. បញ្ចូលមជ្ឈត្តកម្មពាណិជ្ជកម្ម និងយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដទៃទៀត រួមមានសន្ទានកម្ម ដើម្បីដោះស្រាយវិវាទពាណិជ្ជកម្ម | | | | | |
| ៦.១.១ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ( ដំណាក់កាលទី ២ ) | ក្រ.ពាណិជ្ជ<br>ក្រ.យុត្តិធម៌<br>ក.ក.ច.ន.យ<br>រដ្ឋសភា<br>ព្រឹទ្ធសភា | CIDA | ២០០៦-២០០៧<br>( ដំណាក់កាលទី ២) | ១-ផ្សព្វផ្សាយច្បាប់ធានាការសម្របសម្រួលជាមួយប្រព័ន្ធផ្សព្វផ្សាយ ជាមួយវិស័យពាណិជ្ជកម្ម និងសង្គមស៊ីវិល បើសិនជាចាំបាច់<br>២-តាក់តែងកម្មវិធីបណ្តុះបណ្តាលសម្រាប់ចៅក្រម មេធាវី សាស្ត្រាចារ្យច្បាប់ និងក្រសួងពាក់ព័ន្ធ( ជាពិសេសក្រសួងពាណិជ្ជ-កម្ម និងយុត្តិធម៌) អំពីខ្លឹមសារនៃច្បាប់<br>៣-តាក់តែងកម្មវិធីសិក្សានៅសកលវិទ្យា-ល័យ សាលាភូមិន្ទចៅក្រម និងមជ្ឈមណ្ឌលបណ្តុះបណ្តាលមេធាវី ដើម្បីបញ្ចូលច្បាប់ពាណិជ្ជកម្ម និងច្បាប់ហិរញ្ញវត្ថុ | |

**អាទិភាពកំណត់:**

៧.៥.១ ការអភិវឌ្ឍ និងការរក្សានូវប្រព័ន្ធរួមមួយអំពីការធ្វើផែនការ ការរៀបចំថវិកា និងសវនកម្ម ការតាមដាន និងការធ្វើរបាយការណ៍ ស្របទៅតាមផែនការរបស់រាជរដ្ឋាភិបាល និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម (ដំណាក់កាលទី២)

៧.៥.២ ផែនការការងារសម្រាប់នគរបាល ប្រព័ន្ធពន្ធនាគារ អយ្យការ រដ្ឋបាលតុលាការ និងស្ថាប័នផ្សេងៗទៀតនៃវិស័យច្បាប់ និងតុលាការ រួមទាំងសាលារៀនរបស់វិស័យច្បាប់ និងតុលាការ (ដំណាក់កាលទី២)

៧.៦.១ រៀបចំអង្គភាពផែនការផ្ទៃក្នុង ដើម្បីជួយដល់ការបំពេញអាណត្តិរបស់ស្ថាប័ន និងរៀបចំប្រមូលព័ត៌មានប្រតិបត្តិការ (ទិន្នន័យស្ថិតិ)

៧.៦.២ ការធ្វើឱ្យមានទស្សនៈរួមគ្នារវាងស្ថាប័ននៃវិស័យយុត្តិធម៌ ជាពិសេសទាក់ទងនឹងការទទួលព័ត៌មានប្រតិបត្តិ

| **ទិសដៅជាយុទ្ធសាស្ត្រ:** ពង្រឹងស្ថាប័នវិស័យយុត្តិធម៌ ដើម្បីបំពេញអាណត្តិរបស់ខ្លួនបានសម្រេច | | **លទ្ធផលរំពឹងទុក :** សមត្ថភាព និងមធ្យោបាយត្រូវបានផ្តល់នៅក្នុងវិស័យផែនការកម្ម និងធ្វើថវិកាត្រួតពិនិត្យតាមដានមើល និងការធ្វើរបាយការណ៍ ដើម្បីធ្វើឱ្យការអនុវត្ត មានការទទួលខុសត្រូវមានប្រសិទ្ធភាព និងគ្រប់គ្រាន់ | | | |
|---|---|---|---|---|---|
| **សកម្មភាពជាអាទិភាព** | **ស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ** | **ស្ថាប័នដទៃទៀតដែលកំពុងមានការពាក់ព័ន្ធ** | **រយៈពេល** | **សកម្មភាពដែលត្រូវធ្វើ** | **សេចក្តីសង្កេតបន្ថែម** |
| ៧.៥ វិស័យយុត្តិធម៌គួរអភិវឌ្ឍន៍ និងរក្សានូវប្រព័ន្ធរួមមួយអំពីការធ្វើផែនការ ការរៀបចំថវិកា និងសវនកម្ម ការតាមដាន និងការធ្វើរបាយការណ៍ រួមទាំងប្រព័ន្ធផែនការការងារ ៣ ឆ្នាំគោរពទៅតាមផែនការរាជរដ្ឋាភិបាល និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ។ ភាសាគ្រប់គ្រងរួមបែបនេះ នឹងគាំទ្រសហប្រតិបត្តិការរវាងស្ថាប័នតាមវិស័យ និងអាចឱ្យវិស័យនេះសម្រេចអំពីអាទិភាព ដោយមិនបង្កគ្រោះថ្នាក់ដល់ឯករាជ្យភាពនៃស្ថាប័ននីមួយៗស្របទៅតាមតម្លៃនៃវិស័យយុត្តិធម៌ និងអាណត្តិស្ថាប័ន។ | | | | | |
| ៧.៥.១ ការអភិវឌ្ឍ និងការរក្សានូវប្រព័ន្ធរួមមួយអំពីការធ្វើផែនការ ការរៀបចំថវិកា និងសវនកម្ម ការតាមដាន និងការធ្វើរបាយការណ៍ ស្របទៅតាមផែនការរបស់រាជរដ្ឋាភិបាល និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម | ក.ក.ច.ន.យ<br>ក្រ.សេដ្ឋ.ហិរ<br>វិទ្យាស្ថានស្ថិតិ<br>ក្រ.ផែនការ<br>ក្រ.ទំនាក់ទំនង | Aus-Aid<br>DIHR | ដំណាក់កាលទី២<br>២០០៧-២០០៨ | អនុវត្តអនុសាសន៍ដាក់ចេញពីដំណាក់កាលទី១ | |

| | | | | | |
|---|---|---|---|---|---|
| ៧.៥.២ ផែនការការងារសម្រាប់នគរបាល ប្រព័ន្ធពន្ធនាគារ អយ្យការ រដ្ឋបាលតុលាការ និងស្ថាប័នផ្សេងៗទៀតនៃវិស័យច្បាប់ និងតុលាការ រួមទាំងសាលារៀនរបស់វិស័យច្បាប់ និងតុលាការ | ក្រ.មហាផ្ទៃ<br>ក្រ.យុត្តិធម៌<br>សាលារៀននានា<br>។ល។ | Aus-Aid<br>DIHR | ដំណាក់កាលទី២<br>២០០៧-២០០៨ | បន្តការងារដំណាក់កាលទី ១ | |
| ៧.៦ ស្ថាប័នវិស័យយុត្តិធម៌គួរមានរចនាសម្ព័ន្ធ និងការរៀបចំផ្តោតទៅលើការងារស្នូល និងដំណើរការពាក់ព័ន្ធបង្កលក្ខណៈឱ្យមានការអភិវឌ្ឍធនធានមនុស្សប្រណ្តុះបណ្តាល និងត្រួតពិនិត្យ ( មានទាំងតាមរយៈការទិតៀនស្ថាបនាពីខាងក្រៅ) ក្នុងគោលបំណងទទួលនូវការទិទៀនស្ថាបនា នៅក្នុងការគ្រប់គ្រងគ្រប់កម្រិតទាំងអស់ និងការអនុវត្តវិន័យឱ្យបានសមស្រប | | | | | |
| ៧.៦.១ រៀបចំអង្គភាពផែនការផ្ទៃក្នុងដើម្បីជួយដល់ការបំពេញអាណត្តិរបស់ស្ថាប័ន និងរៀបចំប្រមូលព័ត៌មានប្រតិបត្តិការ ( ទិន្នន័យស្ថិតិ ) | ក.ក.ច.ន.យ<br>ក្រ.យុត្តិធម៌<br>ឧត្តម.ចៅក្រម<br>សាលាជំរះក្តី<br>ក្រ.មហាផ្ទៃ<br>( នគរបាល និង<br>ប្រព័ន្ធពន្ធនាគារ) | | ២០០៥-២០០៨ | បង្កើតមុខងារធ្វើផែនការក្នុងស្ថាប័ននីមួយៗ និងផ្តល់ការកសាងសមត្ថភាពទៅតាមតម្រូវការ | |
| ៧.៦.២ ការធ្វើឱ្យមានទស្សនៈរួមគ្នារវាងស្ថាប័ននៃវិស័យយុត្តិធម៌ ជាពិសេសទាក់ទងនឹងការទទួលព័ត៌មានប្រតិបត្តិ | ក.ក.ច.ន.យ<br>ក្រ.យុត្តិធម៌<br>ឧត្តម.ចៅក្រម<br>សាលាជំរះក្តី<br>ក្រ.មហាផ្ទៃ<br>( នគរបាល និង<br>ប្រព័ន្ធពន្ធនាគារ) | DIHR<br>Aus.Aid | ២០០៤-២០០៨ | ១- ពិនិត្យមើលឡើងវិញអំពីប្រសិទ្ធភាព អ.ស.អ ក្នុងតួនាទីជាអង្គភាពសម្របសម្រួលគោលនយោបាយ<br>២- ពង្រឹងទំនាក់ទំនង និងការសម្របសម្រួលអន្តរស្ថាប័ន ដើម្បីចែករំលែកព័ត៌មានសម្រាប់កិច្ចប្រតិបត្តិការ និងកំណត់ឱ្យបាននូវគោលនយោបាយពាក់ព័ន្ធរបស់វិស័យ | |

# កម្មវិធីសកម្មភាព
# រយៈពេលវែង

# សកម្មភាពអាទិភាពរយៈពេលវែង

១.១.២ ការវិភាគលើការបណ្តុះបណ្តាល និងកម្មវិធីយល់ដឹងសម្រាប់ស្ត្រី កុមារ ជនជាតិភាគតិច និងអ្នកបាត់បង់ឱកាស ដើម្បីរកឱ្យឃើញនូវចន្លោះប្រហោង និងកន្លែងដែលត្រូវកែលំអ

១.១.៣ ការបោះពុម្ពផ្សាយឯកសារព័ត៌មានស្តីអំពីសិទ្ធិមូលដ្ឋាន និងនីតិវិធីផ្សេងៗដោយស្ថាប័នពាក់ព័ន្ធនានានៅក្នុងយុត្តាធិការរៀងៗខ្លួន រួមទាំងយន្តការរបាយការណ៍

១.២.១ ការអប់រំ និងការបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់

១.២.៤ ការបង្កើតផ្នែកពិសេសនៅក្នុងការិយាល័យនគរបាលដើម្បីដោះស្រាយបណ្តឹងរបស់ស្ត្រី និងកុមារ

១.៣.១ ក្រមនីតិវិធីរដ្ឋបាលរួមទាំងវិធានសម្រាប់ប្តឹងឧទ្ធរណ៍

១.៣.២ បង្កើតនីតិវិធីប្រកបដោយស្តង់ដាដើម្បីអនុវត្តករណីពាក់ព័ន្ធទៅនឹងសិទ្ធិមនុស្សដោយធ្វើជាសេចក្តីណែនាំ ស្របតាមក្រមនីតិវិធីរដ្ឋបាល និងដោយប្រើវិធីសាស្ត្រចូលរួម និងតាមរយៈការបណ្តុះបណ្តាល

១.៤.៣ ច្បាប់ស្តីពីលទ្ធភាពទទួលបានព័ត៌មាន

១.៤.៤ ពិនិត្យឡើងវិញនូវច្បាប់ជាធរមាន ដើម្បីធានាឱ្យមានការលើកកម្ពស់ និងការគោរពសិទ្ធិ ដើម្បីអនុវត្តសេរីភាពក្នុងការសម្តែងមតិ នៅគ្រប់ទិដ្ឋភាពទាំងអស់

២.២.១ ការពិនិត្យឡើងវិញឱ្យបានគ្រប់ជ្រុងជ្រោយនូវច្បាប់ដែលនៅជាធរមាន និងកម្មវិធីកំណែទម្រង់ច្បាប់

២.២.៣ ការអនុម័តច្បាប់ដើម្បីធានានូវការការពារសិទ្ធិមនុស្ស និងសិទ្ធិសម្រាប់ជនងាយរងគ្រោះដូចជាស្ត្រី យុវជន ។ល។

២.៣.២ ការធានាឱ្យច្បាប់មានភាពស្របគ្នា រួមទាំងការផ្តល់សទ្ទានុក្រមបីភាសា និងការពង្រឹងការពិនិត្យឡើងវិញផ្នែកបច្ចេកទេស

២.៣.៣ កម្មវិធីបណ្តុះបណ្តាលជាបន្ត (មូលដ្ឋាន ឯកទេស រយៈពេលវែង រយៈពេលខ្លី) ស្តីពីការរៀបចំច្បាប់ដល់មន្ត្រីពាក់ព័ន្ធក្នុងស្ថាប័នរដ្ឋាភិបាលទាំងមូល

៣.១.១ ច្បាប់ស្តីពីលទ្ធភាពទទួលបានព័ត៌មាន និងគោលនយោបាយស្តីពីការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងវិស័យច្បាប់ និងតុលាការ

៣.២.១ ការបង្កើតកម្រងអត្ថបទសង្ខេប អំពីច្បាប់តាមពេលកំណត់ដែលបោះពុម្ពតាមរយៈក្រុមអ្នកជំនាញ

៣.២.៣ បទប្បញ្ញត្តិច្បាប់ ស្តីពីលទ្ធភាពទទួលបាននូវសេចក្តីសម្រេចរបស់តុលាការ រួមទាំងការទទួលបាននូវសេវាការិយាល័យព័ត៌មានក្នុងតុលាការផងដែរ

៣.៣.១ គោលនយោបាយផ្សព្វផ្សាយព័ត៌មាននៅក្នុងរង្វង់រដ្ឋបាល

៣.៤.១ បង្កើតបណ្ណាល័យ និងប្រព័ន្ធឯកសារយោងសម្រាប់តុលាការ រួមទាំងប្រព័ន្ធ ដើម្បីធានាឱ្យមានការធ្វើបច្ចុប្បន្នភាពជាទៀងទាត់

៤.២.៤ កែតម្រូវកម្មវិធីសិក្សានានាសម្រាប់ការទទួលបាននូវសញ្ញាបត្រផ្នែកនីតិសាស្ត្រ ឱ្យត្រូវទៅតាមសេចក្តីត្រូវការនៃការផ្តល់យោបល់ផ្នែកច្បាប់

៤.៣.១ ការបង្កើតបទប្បញ្ញត្តិច្បាប់នៅក្នុងច្បាប់នានាដែលពាក់ព័ន្ធ( ក្រមនីតិវិធីរដ្ឋបាល ក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមនីតិវិធីព្រហ្មទណ្ឌ ច្បាប់អង្គការស្តីពីការរៀបចំតុលាការ ច្បាប់ស្តីពីក្រុមប្រឹក្សាធម្មនុញ្ញ ។ល។ ) ដើម្បីកំណត់អំពីដំណើរការត្រឹមត្រូវ

៤.៣.២ ការធានានូវលទ្ធភាពទទួលបានព័ត៌មាន ស្តីពីដំណើរការត្រឹមត្រូវ តាមរយៈបទប្បញ្ញត្តិច្បាប់ ( ក្រមនីតិវិធីរដ្ឋបាល ក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមនីតិវិធីព្រហ្មទណ្ឌ) និងតាមរយៈការិយាល័យទទួលសាធារណជន និងមុខងារផ្តល់ព័ត៌មាននៅក្នុងតុលាការ និងប័ណ្ណផ្សត់ចេញដោយស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ

៤.៣.៣ អត្ថិភាពនៃការិយាល័យការពារសិទ្ធិប្រជាពលរដ្ឋ **(OMBUDSMAN)**

៥.១.១ ការអនុម័តច្បាប់នានាពាក់ព័ន្ធនឹងអង្គតុលាការ និងអាណត្តិ និងភារកិច្ចនៃអ្នកមានតួនាទីនៅក្នុងតុលាការ( ច្បាប់អង្គការស្តីពីការរៀបចំតុលាការ ច្បាប់ធានាឯករាជ្យភាពរបស់សេវាកម្មអយ្យការ ច្បាប់លក្ខន្តិកៈចៅក្រម និងព្រះរាជាអាជ្ញា និងក្រមនីតិវិធីរដ្ឋប្បវេណី និងព្រហ្មទណ្ឌ ច្បាប់លក្ខន្តិកៈសម្រាប់មន្ត្រីតុលាការ ច្បាប់ស្តីពីសារការី)

៥.១.២ ក្រមសីលធម៌សម្រាប់មន្ត្រីរាជការ និងការពង្រឹងក្រុមប្រឹក្សាដាក់វិន័យមន្ត្រីរាជការ

៥.២.១ ការបង្កើតបទប្បញ្ញត្តិច្បាប់ នៅក្នុងក្រមនីតិវិធីសម្រាប់ធានាលទ្ធភាពទទួលបានសេចក្តីសម្រេចទាំងអស់របស់តុលាការ និងការប្តឹងឧទ្ធរណ៍

៥.២.៣ ការបង្កើតក្រុមប្រឹក្សាសេវាកម្មយុត្តិធម៌

៥.២.៥ បទប្បញ្ញត្តិច្បាប់ និងសេចក្តីណែនាំ ស្តីពីទំនាស់ផលប្រយោជន៍

៥.៣.១ ច្បាប់ស្តីពីរដ្ឋបាលតុលាការ

៥.៥.៣ ក្រមសីលធម៌សម្រាប់មន្ត្រីអនុវត្តច្បាប់ទាំងអស់ រួមទាំងនគរបាល មន្ត្រីពន្ធនាគារ មន្ត្រីរាជការ និងមន្ត្រីយុត្តិធម៌ពាក់ព័ន្ធ

៥.៥.៤ ក្រុមប្រឹក្សាវិន័យនានាសម្រាប់មន្ត្រីអនុវត្តច្បាប់

៦.១.២ អភិវឌ្ឍ និងបង្កើតសន្ទានកម្ម និងវិធីសាស្ត្រដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការផ្សេងៗទៀត ដើម្បីដោះស្រាយវិវាទពាណិជ្ជកម្ម និងផ្តល់ការបណ្តុះបណ្តាលចាំបាច់

៧.១.១ ការអនុម័តច្បាប់អង្គការ និងច្បាប់ស្តីពីស្ថាប័នរដ្ឋបាល និងស្ថាប័នយុត្តិធម៌ ( ការរៀបចំតុលាការ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្រុមប្រឹក្សាធម្មនុញ្ញ ក្រសួង និងស្ថាប័នប្រតិបត្តិដទៃទៀត នគរបាល ប្រព័ន្ធពន្ធនាគារ និងក្រុមប្រឹក្សាវិន័យ) ដែលធានាឱ្យមានការសម្របសម្រួលក្នុងការបំពេញអាណត្តិរបស់ស្ថាប័ននីមួយៗ

៧.២.១ ការអនុម័តក្រមនីតិវិធី រួមទាំងក្រមនីតិវិធីរដ្ឋបាល ច្បាប់ស្តីពីការិយាល័យការពារសិទ្ធិប្រជាពលរដ្ឋ **(OMBUDSMAN)** ច្បាប់ស្តីពីលទ្ធភាពទទួលបានព័ត៌មាន ដោយផ្តោតជាពិសេសទៅលើការធានានូវតម្លាភាព ក្នុងស្ថាប័នវិស័យយុត្តិធម៌

៧.៣.១ ក្រមសីលធម៌សម្រាប់នគរបាល មន្ត្រីពន្ធនាគារ មន្ត្រីតុលាការ (ចៅក្រម ព្រះរាជអាជ្ញា មន្ត្រីយុត្តិធម៌) និងមន្ត្រីរាជការឯទៀត បន្ថែមទៅដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលមានដំណើរការល្អ ក្រុមប្រឹក្សាសេវាយុត្តិធម៌ ក្រុមប្រឹក្សាវិន័យសម្រាប់មន្ត្រីនគរបាល ក្រុមប្រឹក្សាវិន័យសម្រាប់មន្ត្រីរាជការ ដើម្បីធានាឱ្យការអនុវត្តមានប្រសិទ្ធភាព

៧.៣.២ បទប្បញ្ញត្តិច្បាប់ និងសេចក្តីណែនាំអំពីទំនាស់ផលប្រយោជន៍

៧.៣.៣ បង្កើតបទដ្ឋានអប្បបរមាសម្រាប់ការទទួលបានសញ្ញាបត្រផ្នែកនីតិសាស្ត្រ ឬរដ្ឋបាលសាធារណៈ

៧.៣.៤ សាលាសម្រាប់ចៅក្រម មន្ត្រីតុលាការ នគរបាល ប្រព័ន្ធពន្ធនាគារ និងសម្រាប់ការអប់រំមូលដ្ឋានដល់មន្ត្រីរាជការ រួមទាំងកម្មវិធីបណ្តុះបណ្តាលបន្ត

៧.៣.៥ វិធានការប្រឆាំងអំពើពុករលួយ រួមទាំងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ

៧.៣.៦ អត្ថិភាពនៃមុខងាររបស់ការិយាល័យការពារសិទ្ធិប្រជាពលរដ្ឋ **(OMBUDSMAN)**

៧.៨.១ បទប្បញ្ញត្តិស្តីពីការរៀបចំបង្កើតរបាយការណ៍ប្រចាំឆ្នាំ សម្រាប់សេវាកម្មនៅក្នុងវិស័យយុត្តិធម៌

# តារាងសង្ខេបអាទិភាពរយៈពេលវែង

## ទិសដៅជាយុទ្ធសាស្ត្រទី ១: ការពារសិទ្ធិ-សេរីភាពរបស់បុគ្គល

- វិភាគលើការបណ្តុះបណ្តាល និងកម្មវិធីយល់ដឹងសម្រាប់ស្ត្រី និងកុមារ ជនជាតិភាគតិច និងអ្នកបាត់បង់ឱកាស
- ព័ត៌មានជាប្រព័ន្ធនិងការបោះពុម្ពផ្សាយឯកសារ ។ល។ អំពីសិទ្ធិជាមូលដ្ឋាន និងនីតិវិធី
- ការអប់រំជាប្រព័ន្ធ និងការបណ្តុះបណ្តាលមន្ត្រីរបស់ទីភ្នាក់ងារអនុវត្តច្បាប់
- ក្រមនីតិវិធីរដ្ឋបាលរួមទាំងវិធានច្បាប់សម្រាប់ការប្តឹងតវ៉ា (ឧទ្ធរណ៍) នៅតុលាការ
- ដោយប្រើវិធីសាស្ត្រចូលរួម និងតាមរយៈការបណ្តុះបណ្តាលបង្កើតជានីតិវិធីមានស្តង់ដា ដើម្បីអនុវត្តករណីពាក់ព័ន្ធទៅនឹងសិទ្ធិ ដែលពង្រឹងដោយសេចក្តីណែនាំ ស្របតាមក្រម

## ទិសដៅជាយុទ្ធសាស្ត្រទី ២: ធ្វើទំនើបកម្មក្របខ័ណ្ឌច្បាប់

- ការពិនិត្យឡើងវិញជាប្រព័ន្ធនូវច្បាប់ដែលនៅជាធរមាន និងកម្មវិធីកំណែទម្រង់ច្បាប់
- អនុម័តច្បាប់ដើម្បីធានានូវការការពារសិទ្ធិមនុស្ស

## ទិសដៅជាយុទ្ធសាស្ត្រទី ៣ ផ្តល់លទ្ធភាពឱ្យទទួលបានព័ត៌មានអំពីច្បាប់ និងតុលាការឱ្យកាន់តែប្រសើរឡើង

- ច្បាប់ស្តីពីលទ្ធភាពទទួលបានព័ត៌មាន និងគោលនយោបាយស្តីពីការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងវិស័យយុត្តិធម៌
- ការបង្កើតកម្រងអត្ថបទសង្ខេបអំពីច្បាប់តាមពេលកំណត់ដែលបោះពុម្ពតាមរយៈក្រុមប្រឹក្សាអ្នកជំនាញឯករាជ្យ
- បទប្បញ្ញត្តិច្បាប់ស្តីពីលទ្ធភាពទទួលបាននូវសេចក្តីសំរេចរបស់តុលាការ រួមទាំងការទទួលបាននូវសេវាការិយាល័យព័ត៌មានក្នុងតុលាការ
- គោលនយោបាយផ្សព្វផ្សាយព័ត៌មាននៅក្នុងរង្វង់រដ្ឋបាល

## ទិសដៅជាយុទ្ធសាស្ត្រទី ៤ ធ្វើឱ្យប្រសើរឡើងនូវគុណ-ភាពនៃដំណើររឿងក្តី និងសេវាពាក់ព័ន្ធ

- កែលំអកម្មវិធីសម្រាប់ការទទួលបាននូវសញ្ញាប័ត្រផ្នែកនីតិសាស្ត្រឱ្យត្រូវទៅតាមសេចក្តីត្រូវការនៃការផ្តល់យោបល់ផ្នែកច្បាប់
- បង្កើតបទប្បញ្ញត្តិច្បាប់នៅក្នុងច្បាប់នានាដែលពាក់ព័ន្ធ ដើម្បីកំណត់អំពីដំណើរការបទប្បញ្ញត្តិច្បាប់
- ធានានូវលទ្ធភាពទទួលបានព័ត៌មានតាមដំណើរការត្រឹមត្រូវ និងតាមរយៈការិ-យាល័យចាត់ចែងសាធារណៈនិងព័ត៌មាននៅក្នុងតុលាការ និងប័ណ្ណផ្ទត់ ចេញដោយស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ
- អត្ថិភាពនៃការិយាល័យការពារសិទ្ធិប្រជាពលរដ្ឋ Ombudsman

## ទិសដៅជាយុទ្ធសាស្ត្រទី ៥ ពង្រឹងសេវាកម្មយុត្តិធម៌ រួមមានអំណាចតុលាការ និងសេវាកម្មអយ្យការ

- អនុម័តច្បាប់នានាពាក់ព័ន្ធនឹងអង្គតុលាការ និងអាណត្តិភារកិច្ចនៃអ្នកមានតួនាទីក្នុងតុលាការ
- ក្រមសីលធម៌សម្រាប់មន្ត្រីរាជការ និងការពង្រឹងក្រុមប្រឹក្សាដាក់វិន័យមន្ត្រីរាជការ
- បទប្បញ្ញត្តិច្បាប់ ធានាលទ្ធភាពទទួលបានសេចក្តីសម្រេចទាំងអស់របស់តុលាការ និងការប្តឹងតវ៉ា
- បង្កើតក្រុមប្រឹក្សាសេវាកម្មយុត្តិធម៌
- បទប្បញ្ញត្តិច្បាប់ និងសេចក្តីណែនាំស្តីពីទំនាស់ផលប្រយោជន៍
- រដ្ឋបាលតុលាការ

## ទិសដៅជាយុទ្ធសាស្ត្រទី ៦ បញ្ចូលយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

- អភិវឌ្ឍន៍ និងបង្កើតសន្ទានកម្ម និងវិធីសាស្ត្រដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការផ្សេងៗទៀត ដើម្បីដោះស្រាយវិវាទពាណិជ្ជ - កម្ម និងផ្តល់ការបណ្តុះបណ្តាលដែលចាំបាច់

## ទិសដៅជាយុទ្ធសាស្ត្រទី ៧ ពង្រឹងស្ថាប័នវិស័យច្បាប់ និងតុលាការ ដើម្បីបំពេញអាណត្តិរបស់ខ្លួនបានសម្រេច

- បង្កើតក្របខ័ណ្ឌច្បាប់ដែលកំណត់ស្ថាប័នរចនាសម្ព័ន្ធ អាណត្តិជាក់លាក់ ព្រមទាំងការទទួលខុសត្រូវរបស់ស្ថាប័ននីមួយៗ
- ផ្តល់ក្របខ័ណ្ឌច្បាប់ដែលធានាថា នីតិវិធីសេចក្តីសម្រេច និងយន្តការប្តឹងឧទ្ធរណ៍របស់ស្ថាប័នមានការផ្សាយជាសាធារណៈ និងមានតម្លាភាព
- ធានាការអនុវត្តច្បាប់ លិខិតបទដ្ឋាន និងសេចក្តីសម្រេចរបស់តុលាការ ដោយស្ថាប័ននៃវិស័យយុត្តិធម៌
- ផ្តល់ក្របខ័ណ្ឌច្បាប់ដើម្បីឱ្យស្ថាប័នវិស័យយុត្តិធម៌អាចធ្វើការតាមដានត្រួតពិនិត្យការអនុវត្តប្រចាំឆ្នាំ ធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រសម្រាប់បីឆ្នាំ និងផែនការកែលំអសេវាកម្មប្រចាំឆ្នាំរបស់ខ្លួន

# តារាងកម្មវិធីសកម្មភាពរយៈពេលវែង



**អាទិភាពកំណត់៖**

១.១.២ ការវិភាគលើការបណ្តុះបណ្តាល និងកម្មវិធីយល់ដឹងសម្រាប់ស្ត្រី កុមារ ជនជាតិភាគតិច និងអ្នកបាត់បង់ឱកាស ដើម្បីរកឱ្យឃើញនូវចន្លោះប្រហោង និងកន្លែងដែលត្រូវកែលំអ

១.១.៣ ការបោះពុម្ពផ្សាយឯកសារព័ត៌មានស្តីអំពីសិទ្ធិមូលដ្ឋាន និងនីតិវិធីផ្សេងៗដោយស្ថាប័នពាក់ព័ន្ធនានានៅក្នុងយុត្តាធិការរៀងៗខ្លួន រួមទាំងយន្តការរបាយការណ៍

១.២.១ ការអប់រំ និងការបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់

១.២.៤ ការបង្កើតផ្នែកពិសេសនៅក្នុងការិយាល័យនគរបាលដើម្បីដោះស្រាយបណ្តឹងរបស់ស្ត្រី និងកុមារ

១.៣.១ ក្រមនីតិវិធីរដ្ឋបាលរួមទាំងវិធានសម្រាប់ប្តឹងឧទ្ធរណ៍

១.៣.២ បង្កើតនីតិវិធីប្រកបដោយស្តង់ដា ដើម្បីអនុវត្តករណីពាក់ព័ន្ធទៅនឹងសិទ្ធិមនុស្សដោយធ្វើជាសេចក្តីណែនាំ ស្របតាមក្រមនីតិវិធីរដ្ឋបាល និងដោយប្រើវិធីសាស្ត្រចូលរួម និងតាមរយៈការបណ្តុះបណ្តាល

១.៤.៣ ច្បាប់ស្តីពីលទ្ធភាពទទួលបានព័ត៌មាន

១.៤.៤ ពិនិត្យឡើងវិញនូវច្បាប់ជាធរមាន ដើម្បីធានាឱ្យមានការលើកកម្ពស់ និងការគោរពសិទ្ធិ ដើម្បីអនុវត្តសេរីភាពក្នុងការសម្តែងមតិ នៅគ្រប់ទិដ្ឋភាពទាំងអស់

| **ទិសដៅយុទ្ធសាស្ត្រ៖** ពង្រឹងការការពារសិទ្ធិ និងសេរីភាពរបស់បុគ្គល | | **លទ្ធផលរំពឹងទុក ៖** សិទ្ធិ និងសេរីភាពបុគ្គលត្រូវបានជំរុញ និងបង្កលក្ខណៈ | | | |
|---|---|---|---|---|---|
| **សកម្មភាពជាអាទិភាព** | **ស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ** | **ស្ថាប័នផ្សេងទៀតដែលកំពុងមានការពាក់ព័ន្ធ** | **រយៈពេល** | **សកម្មភាពដែលត្រូវធ្វើ** | **សេចក្តីសង្កេតបន្ថែម** |
| ១.១ ផ្តល់ការបណ្តុះបណ្តាលហ្វឹកហ្វឺន និងកម្មវិធីយល់ដឹងអំពីសិទ្ធិមនុស្សនិងសិទ្ធិជាមូលដ្ឋាន រួមទាំងសិទ្ធិពលរដ្ឋជាមូលដ្ឋានជាបឋមនៅកម្រិតសហគមន៍ គ្រឹះស្ថាន សហគ្រាសដោយយកចិត្តទុកដាក់ ជាពិសេសទៅលើស្ត្រី កុមារ និងអ្នកបាត់បង់ឱកាស រួមទាំងការបង្កើន និងការយល់ដឹងអំពីការចុះបញ្ជីសិទ្ធិ និងយន្តការបណ្តឹង | | | | | |
| ១.១.២ ការវិភាគលើការបណ្តុះបណ្តាល និងកម្មវិធីយល់ដឹងសម្រាប់ស្ត្រី កុមារ ជនជាតិភាគតិច និងអ្នកបាត់បង់ឱកាស ដើម្បីរកឱ្យឃើញនូវចន្លោះប្រហោង និងកន្លែងដែលត្រូវកែលំអ | ក្រ.ក.ប<br>ក្រ.កិច្ចការនារី<br>ក្រ.យុត្តិធម៌ | | | | |

| | | | | | |
|---|---|---|---|---|---|
| ១.១.៣ ការបោះពុម្ពផ្សាយឯកសារព័ត៌មាន ស្តីអំពីសិទ្ធិមូលដ្ឋាន និងនីតិវិធីផ្សេងៗដោយស្ថាប័នពាក់ព័ន្ធនានានៅក្នុងយុត្តាធិការរៀងៗខ្លួន រួមទាំងយន្តការរបាយការណ៍ | ក្រ.អប់រំ<br>ក្រ.មហាផ្ទៃ<br>ក្រ.ក.ប ។ល ។ | | | | |
| ១.២ ផ្តល់ការបណ្តុះបណ្តាលហ្វឹកហ្វឺន និងការយល់ដឹងដល់មន្ត្រីទាំងឡាយ នៅក្នុងទីភ្នាក់ងារអនុវត្តច្បាប់អំពីសិទ្ធិមូលដ្ឋាន រួមទាំងសិទ្ធិពលរដ្ឋជាមូលដ្ឋាន និងសិទ្ធិមនុស្សដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងសមត្ថភាពអនុវត្តស្តង់ដារអន្តរជាតិ នៅពេលគ្មានច្បាប់ជាតិ ឬក្នុងករណីវិធាន/ច្បាប់ មានខ្លឹមសារប្រឆាំងគ្នាទៅវិញទៅមក | | | | | |
| ១.២.១ ការអប់រំ និងការបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ | ក.ក.ច.ន.យ<br>ក្រសួងមហាផ្ទៃ<br>ពន្ធនាគារ<br>ក្រ.យុត្តិធម៌ | | | | |
| ១.២.៤ ការបង្កើតផ្នែកពិសេសនៅក្នុងការិយាល័យនគរ-បាល ដើម្បីដោះស្រាយបណ្តឹងរបស់ស្ត្រី និងកុមារ | ក្រ.មហាផ្ទៃ | | | | |
| ១.៣ បង្កើតសេចក្តីណែនាំ និងនីតិវិធីស្តង់ដា ដើម្បីធានានូវការលើកកម្ពស់សិទ្ធិបុគ្គល តាមរយៈទីភ្នាក់ងារអនុវត្តច្បាប់ | | | | | |
| ១.៣.១ ក្រមនីតិវិធីរដ្ឋបាលរួមទាំងវិធានសម្រាប់ប្តឹង-ឧទ្ធរណ៍ | ទី.គ.មន្ត្រី<br>ក.ក.រ<br>ក្រ.អ្នកច្បាប់ | | | | |
| ១.៣.២ បង្កើតនីតិវិធីប្រកបដោយស្តង់ដា ដើម្បីអនុវត្តករណីពាក់ព័ន្ធទៅនឹងសិទ្ធិមនុស្សដោយធ្វើជាសេចក្តីណែនាំស្របតាមក្រមនីតិវិធីរដ្ឋបាល និងដោយប្រើវិធីសាស្ត្រចូលរួម និងតាមរយៈការបណ្តុះបណ្តាល | ទី.គ.មន្ត្រី<br>ក្រ.មហាផ្ទៃ<br>ក្រ.យុត្តិធម៌ | | | | |
| ១.៤ អនុម័ត និងពិនិត្យឡើងវិញនូវច្បាប់ការពារសិទ្ធិរបស់បុគ្គលក្នុងការរៀបចំអង្គការ បង្កើតសមាគម សម្តែងមតិ និងទទួលព័ត៌មាន ធានាឱ្យប្រព័ន្ធផ្សព្វផ្សាយ ស្ថាប័នស្រាវជ្រាវ និងសង្គមស៊ីវិល អាចអនុវត្តការតាមដានត្រួតពិនិត្យ ប្រកបដោយប្រសិទ្ធភាពលើរចនាសម្ព័ន្ធរបស់រដ្ឋ និងធ្វើរបាយការណ៍អំពីបញ្ហានោះ រួមទាំងផ្តល់ជាគំនិតដល់ដំណើរការនយោបាយ និងផ្តល់ចំណេះដឹងដោយមន្ត្រីអនុវត្តច្បាប់ ដើម្បីការពារសិទ្ធិទាំងនេះ | | | | | |
| ១.៤.៣ ច្បាប់ស្តីពីលទ្ធភាពទទួលបានព័ត៌មាន | ទី.គ.មន្ត្រី<br>ក្រ.ព័ត៌មាន | | | | |

| | | | | | |
|---|---|---|---|---|---|
| ១.៤.៤ ពិនិត្យឡើងវិញនូវច្បាប់ជាធរមាន ដើម្បីធានាឱ្យមានការលើកកម្ពស់ និងការគោរពសិទ្ធិ ដើម្បីអនុវត្តសេរីភាពក្នុងការសម្តែងមតិ នៅគ្រប់ទិដ្ឋភាពទាំងអស់ | ទី.គ.មន្ត្រី<br>ក្រ.យុត្តិធម៌<br>ក្រ.មហាផ្ទៃ<br>ក្រុ.ធម្មនុញ្ញ<br>ក្រ.ព័ត៌មាន | | | | |

## **ទិសដៅជាយុទ្ធសាស្ត្រទី ២**

**អាទិភាពកំណត់:**

២.២.១ ការពិនិត្យឡើងវិញឱ្យបានគ្រប់ជ្រុងជ្រោយនូវច្បាប់ដែលនៅជាធរមាន និងកម្មវិធីកំណែទម្រង់ច្បាប់

២.២.៣ ការអនុម័តច្បាប់ដើម្បីធានានូវការការពារសិទ្ធិមនុស្ស និងសិទ្ធិសម្រាប់ជនងាយរងគ្រោះដូចជាស្ត្រី យុវជន ។ល។

២.៣.២ ការធានាឱ្យច្បាប់មានភាពស្របគ្នា រួមទាំងការផ្ដល់សទ្ទានុក្រមបីភាសា និងការពង្រឹងការពិនិត្យឡើងវិញផ្នែកបច្ចេកទេស

២.៣.៣ កម្មវិធីបណ្ដុះបណ្ដាលជាបន្ត ( មូលដ្ឋាន ឯកទេស រយៈពេលវែង រយៈពេលខ្លី) ស្ដីពីការរៀបចំច្បាប់ដល់មន្ត្រីពាក់ ព័ន្ធក្នុងស្ថាប័នរដ្ឋាភិបាលទាំងមូល

| **ទិសដៅជាយុទ្ធសាស្ត្រ:** ទំនើបកម្មក្របខ័ណ្ឌច្បាប់ | | **លទ្ធផលរំពឹងទុក:** ដំណើរការធ្វើច្បាប់ និងក្របខ័ណ្ឌច្បាប់ ត្រូវបានធ្វើទំនើបកម្ម ក្នុងគោលបំណងអនុវត្តនីតិរដ្ឋ ផ្អែកលើប្រព័ន្ធឋានានុក្រមនៃច្បាប់ | | | |
|---|---|---|---|---|---|
| **សកម្មភាពជាអាទិភាព** | **ស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ** | **ស្ថាប័នផ្សេងទៀតដែលកំពុងមានការពាក់ព័ន្ធ** | **រយៈពេល** | **សកម្មភាពដែលត្រូវធ្វើ** | **សេចក្ដីសង្កេតបន្ថែម** |
| ២.២ បញ្ចប់ច្បាប់ដែលធ្វើមិនទាន់រួច និងដោយប្រើវិធីសាស្ត្រនៃការចូលរួម និងតាមរបៀបគិតគូរជាវិស័យ កំណត់នូវចន្លោះប្រហោងក្នុងក្របខ័ណ្ឌច្បាប់ ហើយបំពេញចន្លោះប្រហោងនោះក្នុងគាលបំណងអនុវត្តនីតិរដ្ឋ | | | | | |
| ២.២.១ ការពិនិត្យឡើងវិញឱ្យបានគ្រប់ជ្រុងជ្រោយនូវច្បាប់ដែលនៅជាធរមាន និងកម្មវិធីកំណែទម្រង់ច្បាប់ | ទី.គ.មន្ត្រី<br>ក្រ.យុត្តិធម៌<br>ក្រ.មហាផ្ទៃ<br>ក្រុ.ធម្មនុញ្ញ | | | | |
| ២.២.៣ ការអនុម័តច្បាប់ដើម្បីធានានូវការការពារសិទ្ធិមនុស្ស និងសិទ្ធិសម្រាប់ជនងាយរងគ្រោះដូចជាស្ត្រី យុវជន ។ល។ | ទី.គ.មន្ត្រី<br>ក្រ.យុត្តិធម៌<br>ក្រ.ក.ប | | | | |
| ២.៣ ផ្ដល់នូវដំណើរការធ្វើច្បាប់មួយមានប្រសិទ្ធភាព ស៊ីសង្វាក់គ្នា និងមានការចូលរួមផ្អែកលើឋានានុក្រមនៃច្បាប់ ដោយមានសេចក្ដីណែនាំជាក់លាក់អំពីការធ្វើច្បាប់ និងមានបទដ្ឋានអំពីការពិនិត្យឡើងវិញផ្នែកបច្ចេកទេស រួមទាំងការយកចិត្តទុកដាក់ក្នុងការអនុវត្តស្តង់ដាអន្តរជាតិ និងពង្រឹងអង្គភាពនានា ដែលពាក់ព័ន្ធ នៅក្នុងការអនុម័តច្បាប់ថ្មីៗ និងការធ្វើវិសោធនកម្មច្បាប់ ព្រមទាំងផ្ដល់នូវការបណ្ដុះបណ្ដាលអំពីការព្រាងច្បាប់ដល់មន្ត្រីពាក់ព័ន្ធនៅក្នុងសកម្មភាពនេះ នៅក្នុងស្ថាប័នរដ្ឋាភិបាលទាំងមូល | | | | | |

| | | | | | |
|---|---|---|---|---|---|
| ២.៣.២ ការធានាឱ្យច្បាប់មានភាពស្របគ្នា រួមទាំងការផ្តល់សទ្ទានុក្រមបីភាសា និងការពង្រឹងការពិនិត្យឡើងវិញផ្នែកបច្ចេកទេស | ទី.ត.មន្ត្រី<br>អ.រ.ភ | | | | |
| ២.៣.៣ កម្មវិធីបណ្តុះបណ្តាលជាបន្ត ( មូលដ្ឋាន ឯកទេស រយៈពេលវែង រយៈពេលខ្លី) ស្តីពីការរៀបចំច្បាប់ដល់មន្ត្រីពាក់ព័ន្ធក្នុងស្ថាប័នរដ្ឋាភិបាលទាំងមូល | សា.ចៅក្រម<br>សាលាផ្សេងទៀតនៃវិស័យយុត្តិធម៌ | | | | |

## និសដៅជាយុទ្ធសាស្ត្រទី ៣

**អាទិភាពកំណត់:**

៣.១.១ ច្បាប់ស្តីពីលទ្ធភាពទទួលបានព័ត៌មាន និងគោលនយោបាយស្តីពីការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងវិស័យច្បាប់ និងតុលាការ

៣.២.១ ការបង្កើតកម្រងអត្ថបទសង្ខេប អំពីច្បាប់តាមពេលកំណត់ដែលបោះពុម្ព តាមរយៈក្រុមអ្នកជំនាញ

៣.២.៣ បទប្បញ្ញត្តិច្បាប់ស្តីពីលទ្ធភាពទទួលបាននូវសេចក្តីសម្រេចរបស់តុលាការ រួមទាំងការទទួលបាននូវសេវាការិយាល័យព័ត៌មានក្នុងតុលាការផងដែរ

៣.៣.១ គោលនយោបាយផ្សព្វផ្សាយព័ត៌មាននៅក្នុងរង្វង់រដ្ឋបាល

៣.៤.១ បង្កើតបណ្ណាល័យ និងប្រព័ន្ធឯកសារយោងសម្រាប់តុលាការ រួមទាំងប្រព័ន្ធដើម្បីធានាឱ្យមានការធ្វើបច្ចុប្បន្នភាពជាទៀងទាត់

| **និសដៅជាយុទ្ធសាស្ត្រ:** ផ្តល់លទ្ធភាពឱ្យទទួលបានព័ត៌មានអំពីច្បាប់ និងតុលាការ ឱ្យកាន់តែប្រសើរឡើង | | **លទ្ធផលរំពឹងទុក:** ការយល់ដឹងជាសាធារណៈត្រូវបានលើកកម្ពស់ ហើយចំណេះដឹង និងលទ្ធភាពទទួលបានព័ត៌មានច្បាប់ និងយុត្តិធម៌កាន់តែប្រសើរ | | | |
|---|---|---|---|---|---|
| **សកម្មភាពជាអាទិភាព** | **ស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ** | **ស្ថាប័នដទៃទៀតដែលកំពុងមានការពាក់ព័ន្ធ** | **រយៈពេល** | **សកម្មភាពដែលត្រូវធ្វើ** | **សេចក្តីសង្កេតបន្ថែម** |
| ៣.១ បោះពុម្ពច្បាប់ទាំងឡាយដែលមាន និងលិខិតបទដ្ឋានទាំងអស់ រួមទាំងសេចក្តីណែនាំ និងទម្លាប់អនុវត្តជាភាសាខ្មែរ បោះពុម្ពច្បាប់ថ្មី លិខិតបទដ្ឋានទាំងអស់ជាផ្លូវការឱ្យទាន់ពេលវេលា និងសព្វគ្រប់ ឧទាហរណ៍ រាជកិច្ច សម្រាប់សេចក្តីត្រូវការនៃចៅក្រម មេធាវី និស្សិតច្បាប់ មន្ត្រីរដ្ឋាភិបាល វិស័យឯកជន សង្គមស៊ីវិល និងអ្នកចិត្តទុកដាក់ដទៃទៀត | | | | | |
| ៣.១.១ ច្បាប់ស្តីពីលទ្ធភាពទទួលបានព័ត៌មាន និងគោលនយោ-បាយស្តីពីការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងវិស័យច្បាប់ និងតុលាការ | ទី.គ.មន្ត្រី<br>ក្រ.យុត្តិធម៌<br>ឧត្តម.ចៅក្រម | | | | |
| ៣.២ បោះពុម្ពសាលក្រមដែលមានស្រាប់ និងផលិតព្រឹត្តិបត្រសង្ខេបរឿងក្តី សម្រាប់បោះពុម្ព និងផ្សព្វផ្សាយសាលក្រម សេចក្តីសម្រេច និងវិធានផ្សេងៗរបស់តុលាការ និងធានាឱ្យសាលក្រមតុលាការអាចរកបាននៅពេលមានការស្នើសុំ | | | | | |
| ៣.២.១ ការបង្កើតកម្រងអត្ថបទសង្ខេបអំពីច្បាប់តាមពេលកំណត់ដែលបោះពុម្ព តាមរយៈក្រុមអ្នកជំនាញ | ក្រ.យុត្តិធម៌<br>ក្រ.ធម្មនុញ្ញ | | | | |

| | | | | | |
|---|---|---|---|---|---|
| ៣.២.៣ បទប្បញ្ញត្តិច្បាប់ស្តីពីលទ្ធភាពទទួលបាននូវសេចក្តីសម្រេចរបស់តុលាការ រួមទាំងការទទួលបាននូវសេវាការិយា-ល័យព័ត៌មានក្នុងតុលាការផងដែរ | ក្រ.យុត្តិធម៌ | | | | |
| ៣.៣ ជំរុញឱ្យស្ថាប័នតុលាការក៏ដូចជាស្ថាប័នរដ្ឋបាលនីមួយៗផ្តល់ព័ត៌មានពាក់ព័ន្ធ និងការណែនាំដល់សាធារណជន និងអ្នកប្រើប្រាស់តុលាការ និងស្ថាប័នរដ្ឋបាលអំពីស្ថាប័នរបស់ខ្លួន | | | | | |
| ៣.៣.១ គោលនយោបាយផ្សព្វផ្សាយព័ត៌មាននៅក្នុងរង្វង់រដ្ឋបាល | ទី.គ.មន្ត្រី | | | | |
| ៣.៤ ធានាឱ្យអ្នកមានមុខងារវិជ្ជាជីវៈតុលាការ មានលទ្ធភាពរកបាននូវច្បាប់ទាំងឡាយរបស់ប្រទេស របស់ស្ថាប័ន ច្បាប់អន្តរជាតិ អក្សរសាស្ត្រ វិជ្ជាជីវៈ និងយុត្តិសាស្ត្រ | | | | | |
| ៣.៤.១ បង្កើតបណ្ណាល័យ និងប្រព័ន្ធឯកសារយោងសម្រាប់តុលាការរួមទាំងប្រព័ន្ធ ដើម្បីធានាឱ្យមានការធ្វើបច្ចុប្បន្នភាពជាទៀងទាត់ | ក្រ.យុត្តិធម៌ | | | | |

**អាទិភាពកំណត់:**

៤.២.៤ កែតម្រូវកម្មវិធីសិក្សានានាសម្រាប់ការទទួលបាននូវសញ្ញាប័ត្រផ្នែកនីតិសាស្ត្រ ឱ្យត្រូវទៅតាមសេចក្តីត្រូវការនៃការផ្តល់យោបល់ផ្នែកច្បាប់

៤.៣.១ ការបង្កើតបទប្បញ្ញត្តិច្បាប់នៅក្នុងច្បាប់នានាដែលពាក់ព័ន្ធ( ក្រមនីតិវិធីរដ្ឋបាល ក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមនីតិវិធីព្រហ្មទណ្ឌ ច្បាប់អង្គការស្តីពីការរៀបចំតុលាការ ច្បាប់ស្តីពីក្រុមប្រឹក្សាធម្មនុញ្ញ ។ល។ ) ដើម្បីកំណត់អំពីដំណើរការត្រឹមត្រូវ

៤.៣.២ ការធានានូវលទ្ធភាពទទួលបានព័ត៌មាន ស្តីពីដំណើរការត្រឹមត្រូវ តាមរយៈបទប្បញ្ញត្តិច្បាប់ ( ក្រមនីតិវិធីរដ្ឋបាល ក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមនីតិវិធីព្រហ្មទណ្ឌ) និងតាមរយៈការិយាល័យទទួលសាធារណជន និងមុខងារផ្តល់ព័ត៌មាននៅក្នុងតុលាការ និងប័ណ្ណផ្សព្វផ្សាយចេញដោយស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ

៤.៣.៣ អត្ថិភាពនៃការិយាល័យការពារសិទ្ធិប្រជាពលរដ្ឋ **(OMBUDSMAN)**

<table>
<tr><td colspan="2">**ទិសដៅយុទ្ធសាស្ត្រ:** ធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃដំណើររឿងក្តីនិងសេវាពាក់ព័ន្ធ</td><td colspan="4">**លទ្ធផលរំពឹងទុក:** ដំណើរការត្រឹមត្រូវចំពោះមុខស្ថាប័នរដ្ឋបាល និងតុលាការ និងសិទ្ធិនៃការប្តឹងតវ៉ារបស់ជនគ្រប់រូបត្រូវបានធានា</td></tr>
<tr><th>សកម្មភាពជាអាទិភាព</th><th>ស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ</th><th>ស្ថាប័នផ្សេងទៀតដែលកំពុងមានការពាក់ព័ន្ធ</th><th>រយៈពេល</th><th>សកម្មភាពដែលត្រូវធ្វើ</th><th>សេចក្តីសង្កេតបន្ថែម</th></tr>
<tr><td colspan="6">៤.២ បង្កើនចំនួនមេធាវី យោងតាមលក្ខណៈវិនិច្ឆ័យ ដែលរៀបចំសម្រាប់ផ្តល់យោបល់ផ្នែកច្បាប់ និងសេវាដទៃទៀតដល់អ្នកមានវិវាទ និងកូនក្តីដទៃទៀត សម្រាប់ប្រជាពលរដ្ឋទាំងអស់ក្នុងប្រទេស និងជនបរទេសដែលពាក់ព័ន្ធ ឬកំពុងតែពាក់ព័ន្ធនៅកម្ពុជា រួមមានការផ្តល់ការបណ្តុះបណ្តាលសមស្របដល់និស្សិតច្បាប់ កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈបន្ត ដើម្បីធានាឱ្យការផ្តល់យោបល់ជូនអតិថិជននូវជំនួយផ្នែកច្បាប់មានគុណភាពខ្ពស់តាមការដែលអាចធ្វើទៅបាន</td></tr>
<tr><td>៤.២.៤ កែតម្រូវកម្មវិធីសិក្សានានាសម្រាប់ការទទួលបាននូវសញ្ញាប័ត្រផ្នែកនីតិសាស្ត្រ ឱ្យត្រូវទៅតាមសេចក្តីត្រូវការនៃការផ្តល់យោបល់ផ្នែកច្បាប់</td><td>ក្រ.អប់រំ<br>គណៈមេធាវី<br>ស.នីតិសាស្ត្រ<br>មជ្ឈមណ្ឌល.មេធាវី</td><td></td><td></td><td></td><td></td></tr>
<tr><td colspan="6">៤.៣ ធានាថា ដំណើរការត្រឹមត្រូវត្រូវ បានកំណត់ដោយច្បាប់ និងគោរពដោយចៅក្រម មេធាវី មន្ត្រីតុលាការ និងមន្ត្រីអនុវត្តច្បាប់ឯទៀត និងធានាថា មន្ត្រីពាក់ព័ន្ធមានព័ត៌មានគ្រប់គ្រាន់អំពីដំណើរការត្រឹមត្រូវ</td></tr>
</table>

| | | | | | |
|---|---|---|---|---|---|
| ៤.៣.១ ការបង្កើតបទប្បញ្ញត្តិច្បាប់នៅក្នុងច្បាប់នានាដែលពាក់ព័ន្ធ (ក្រមនីតិវិធីរដ្ឋបាល ក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមនីតិវិធីព្រហ្មទណ្ឌ ច្បាប់អង្គការស្តីពីការរៀបចំតុលាការ ច្បាប់ស្តីពីក្រុមប្រឹក្សាធម្មនុញ្ញ ។ល។) ដើម្បីកំណត់អំពីដំណើរការត្រឹមត្រូវ | ទី.គ.មន្ត្រី<br>ក្រ.យុត្តិធម៌<br>ក.ក.ច.ន.យ | | | | |
| ៤.៣.២ ការធានានូវលទ្ធភាពទទួលបានព័ត៌មាន ស្តីពីដំណើរការត្រឹមត្រូវ តាមរយៈបទប្បញ្ញត្តិច្បាប់ (ក្រមនីតិវិធីរដ្ឋបាល ក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមនីតិវិធីព្រហ្មទណ្ឌ) និងតាមរយៈការិយាល័យទទួលសាធារណជន និងមុខងារផ្តល់ព័ត៌មាននៅក្នុងតុលាការ និងប័ណ្ណផ្នត់ចេញដោយស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ | ទី.គ.មន្ត្រី<br>ក្រ.យុត្តិធម៌<br>ក្រ.អប់រំ ។ល។ | | | | |
| ៤.៣.៣ អត្ថិភាពនៃការិយាល័យការពារសិទ្ធិប្រជាពលរដ្ឋ **(OMBUDSMAN)** | ទី.គ.មន្ត្រី<br>ក្រ.ទំនាក់ទំនង | | | | |

## អាទិភាពកំណត់:

៥.១.១ ការអនុម័តច្បាប់នានាពាក់ព័ន្ធនឹងអង្គតុលាការ និងអាណត្តិ និងភារកិច្ចនៃអ្នកមានតួនាទីនៅក្នុងតុលាការ (ច្បាប់អង្គការស្តីពីការរៀបចំតុលាការ ច្បាប់ធានាឯករាជ្យភាពរបស់សេវាកម្មអយ្យការ ច្បាប់លក្ខន្តិកៈចៅក្រម និងព្រះរាជាអាជ្ញា និងក្រមនីតិវិធីរដ្ឋប្បវេណី និងព្រហ្មទណ្ឌ ច្បាប់លក្ខន្តិកៈសម្រាប់មន្ត្រីតុលាការ ច្បាប់ស្តីពីសារការី)

៥.១.២ ក្រមសីលធម៌សម្រាប់មន្ត្រីរាជការ និងការពង្រឹងក្រុមប្រឹក្សាដាក់វិន័យមន្ត្រីរាជការ

៥.២.១ ការបង្កើតបទប្បញ្ញត្តិច្បាប់ នៅក្នុងក្រមនីតិវិធីសម្រាប់ធានាលទ្ធភាពទទួលបាន សេចក្តីសម្រេចទាំងអស់របស់តុលាការ និងការប្តឹងឧទ្ធរណ៍

៥.២.៣ ការបង្កើតក្រុមប្រឹក្សាសេវាកម្មយុត្តិធម៌

៥.២.៥ បទប្បញ្ញត្តិច្បាប់ និងសេចក្តីណែនាំ ស្តីពីទំនាស់ផលប្រយោជន៍

៥.៣.១ ច្បាប់ស្តីពីរដ្ឋបាលតុលាការ

៥.៥.៣ ក្រមសីលធម៌សម្រាប់មន្ត្រីអនុវត្តច្បាប់ទាំងអស់ រួមទាំងនគរបាល មន្ត្រីពន្ធនាគារ មន្ត្រីរាជការ និងមន្ត្រីយុត្តិធម៌ពាក់ព័ន្ធ

៥.៥.៤ ក្រុមប្រឹក្សាវិន័យនានាសម្រាប់មន្ត្រីអនុវត្តច្បាប់

| **ទិសដៅយុទ្ធសាស្ត្រ:** ពង្រឹងសេវាកម្មយុត្តិធម៌ រួមមានអំណាចតុលាការ និងសេវាកម្មអយ្យការ | | **លទ្ធផលរំពឹងទុក :** តុលាការឯករាជ្យ និងមានដំណើរការល្អប្រសើរត្រូវបានធានា | | | |
|---|---|---|---|---|---|
| **សកម្មភាពជាអាទិភាព** | **ស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ** | **ស្ថាប័នដទៃទៀតដែលកំពុងមានការពាក់ព័ន្ធ** | **រយៈពេល** | **សកម្មភាពដែលត្រូវធ្វើ** | **សេចក្តីសង្កេតបន្ថែម** |
| ៥.១ ជំរុញឱ្យមានតុលាការមួយដែលឯករាជ្យ និងអាចជឿទុកចិត្តបាន ដែលកំណត់មុខងារ និងភារកិច្ចច្បាស់លាស់ តាមអាណត្តិផ្តល់ឱ្យដោយរដ្ឋធម្មនុញ្ញ និងមានការការពារដោយច្បាប់មិនឱ្យមានការជ្រៀតជ្រែកដល់រចនាសម្ព័ន្ធ តួនាទី និងបុគ្គលពីអំណាចផ្សេងទៀត រួមទាំងការធានានូវការកំណត់តួនាទីឱ្យបានច្បាស់លាស់រវាងតួអង្គនីមួយៗ នៅក្នុងស្ថាប័នតុលាការ ដើម្បីបង្កលក្ខណៈឱ្យបំពេញភារកិច្ចយុត្តិធម៌ ប្រកបដោយកម្រិតវិជ្ជាជីវៈខ្ពស់ ស្របតាមច្បាប់នានាដែលមានទាំងអស់ ។ | | | | | |

| | | | | | |
|---|---|---|---|---|---|
| ៥.១.១ ការអនុម័តច្បាប់នានាពាក់ព័ន្ធនឹងអង្គតុលាការ និង អាណត្តិ និងភារកិច្ចនៃអ្នកមានតួនាទីនៅក្នុងតុលាការ ( ច្បាប់អង្គការស្តីពីការរៀបចំតុលាការ ច្បាប់ធានាឯករាជ្យភាពរបស់សេវាកម្មអយ្យការ ច្បាប់លក្ខន្តិកៈចៅក្រម និងព្រះរាជាអាជ្ញា និងក្រមនីតិវិធីរដ្ឋប្បវេណី និងព្រហ្មទណ្ឌ ច្បាប់លក្ខន្តិកៈ សម្រាប់មន្ត្រីតុលាការ ច្បាប់ស្តីពីសារការី) | ក្រ.យុត្តិធម៌<br>ឧត្តម.ចៅក្រម | | | | |
| ៥.១.២ ក្រមសីលធម៌សម្រាប់មន្ត្រីរាជការ និងការពង្រឹងក្រុមប្រឹក្សាដាក់វិន័យមន្ត្រីរាជការ | ទី.គ.មន្ត្រី,<br>មុខងារសា-<br>ធារណៈ<br>ក.ក.រ | | | | |
| ៥.២ បង្កើតការទទួលខុសត្រូវ ដោយធានាឱ្យមានលទ្ធភាពទទួលបាននូវការវិនិច្ឆ័យត្រឹមត្រូវ យោងទៅតាមច្បាប់ពាក់ព័ន្ធដែលអាចប្ដឹងឧទ្ធរណ៍បាន និងធានាឱ្យមានប្រព័ន្ធមួយមានតម្លាភាពស្តីពីការតែងតាំង តម្លើងឋានន្តរសក្តិ និងផ្ទាក់ប្រាក់បៀវត្ស ចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីតុលាការដទៃទៀត និងវិធានការវិន័យដល់ព្រះរាជអាជ្ញា ចៅក្រម និងមន្ត្រីតុលាការដទៃទៀត ផ្អែកលើវិធាន និង លក្ខណៈវិនិច្ឆ័យ ដែលមានចែងក្នុងច្បាប់ និងដែលអនុវត្តតាមរយៈស្ថាប័នឯករាជ្យមួយ ដែលមានធនធានគ្រប់គ្រាន់ រួមមានការបង្កើតក្រមសីលធម៌ និងវិធានស្តីពីទំនាស់ផលប្រយោជន៍សម្រាប់ចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីតុលាការដទៃទៀតទាំងអស់ គួបជាមួយនឹងវិធានការវិន័យពាក់ព័ន្ធ | | | | | |
| ៥.២.១ ការបង្កើតបទប្បញ្ញត្តិច្បាប់ នៅក្នុងក្រមនីតិវិធីសម្រាប់ធានាលទ្ធភាពទទួលបាន សេចក្តីសម្រេចទាំងអស់របស់តុលាការ និងការប្តឹងឧទ្ធរណ៍ | ក្រ.យុត្តិធម៌<br>ឧត្តម.ចៅក្រម | | | | |
| ៥.២.៣ ការបង្កើតក្រុមប្រឹក្សាសេវាកម្មយុត្តិធម៌ | ក្រ.យុត្តិធម៌<br>ឧត្តម.ចៅក្រម | | | | |
| ៥.២.៥ បទប្បញ្ញត្តិច្បាប់ និងសេចក្តីណែនាំ ស្តីពីទំនាស់ផល-ប្រយោជន៍ | ទី.គ.មន្ត្រី<br>ក្រ.យុត្តិធម៌ | | | | |

| | | | | | |
|---|---|---|---|---|---|
| ៥.៣ បញ្ចូលការគ្រប់គ្រងដូចគ្នាសម្រាប់រឿងក្តីដូចគ្នា និងបច្ចេកទេសគ្រប់គ្រងតុលាការ ដើម្បីធានាឱ្យដំណើរការមានតម្លាភាព និងតាមពេលកំណត់ រួមទាំងយន្តការប្តឹងឧទ្ធរណ៍ស៊ីសង្វាក់គ្នា | | | | | |
| ៥.៣.១ ច្បាប់ស្តីពីរដ្ឋបាលតុលាការ | ក្រ.យុត្តិធម៌<br>ឧត្តម.ចៅក្រម | | | | |
| ៥.៥ ធានាការឱ្យមានការអនុវត្តសេចក្តីសម្រេចរបស់តុលាការ និងឯករាជ្យភាពរបស់តុលាការ ដោយផ្តល់នូវក្របខ័ណ្ឌច្បាប់ និងស្ថាប័នដែលបង្គ្រប់បន្ថែមដោយធនធានចាំបាច់ និងធ្វើការបណ្តុះបណ្តាលអំពីការអនុវត្តសាលក្រម  ហើយនិងយន្តការអនុវត្តសម្រាប់ដាក់ទណ្ឌកម្មដល់ការខ្វះខាតចំពោះការអនុវត្ត និងការដាក់ទណ្ឌកម្មដល់ការជ្រៀតជ្រែកដល់ការងាររបស់មន្ត្រីតុលាការ | | | | | |
| ៥.៥.៣ ក្រមសីលធម៌សម្រាប់មន្ត្រីអនុវត្តច្បាប់ទាំងអស់ រួមទាំងនគរបាល មន្ត្រីពន្ធនាគារ មន្ត្រីរាជការ និងមន្ត្រីយុត្តិធម៌ពាក់ព័ន្ធ | ទី.គ.មន្ត្រី<br>ក្រ.មហាផ្ទៃ<br>ក្រ.យុត្តិធម៌<br>ឧត្តម.ចៅក្រម | | | | |
| ៥.៥.៤ ក្រុមប្រឹក្សាវិន័យនានាសម្រាប់មន្ត្រីអនុវត្តច្បាប់ | ទី.គ.មន្ត្រី<br>ក្រ.យុត្តិធម៌<br>ឧត្តម.ចៅក្រម<br>ក្រ.មហាផ្ទៃ | | | | |

**អាទិភាពកំណត់:**

៦.១.២ អភិវឌ្ឍ និងបង្កើតសន្ទានកម្ម និងវិធីសាស្ត្រដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការផ្សេងៗទៀត ដើម្បីដោះស្រាយ វិវាទពាណិជ្ជកម្ម និងផ្តល់ការបណ្តុះបណ្តាលចាំបាច់

| **ទិសដៅយុទ្ធសាស្ត្រ:** បញ្ចូលយន្តការដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ | | **លទ្ធផលរំពឹងទុក :** ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដែលដំណើរការល្អប្រសើរ និងយន្តការសន្ទានកម្ម ត្រូវបានបង្កើតដើម្បីដោះស្រាយវិវាទពាណិជ្ជកម្ម និង វិវាទតូចតាចនៅក្នុងកម្រិតសហគមន៍ | | | |
|---|---|---|---|---|---|
| **សកម្មភាពជាអាទិភាព** | **ស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ** | **ស្ថាប័នដទៃទៀតដែលកំពុងមានការពាក់ព័ន្ធ** | **រយៈពេល** | **សកម្មភាពដែលត្រូវធ្វើ** | **សេចក្តីសង្កេតបន្ថែម** |
| ៦.១ បញ្ចូលមជ្ឈត្តកម្មពាណិជ្ជកម្ម និងវិធីសាស្ត្រ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដទៃទៀត រួមមានសន្ទានកម្ម ដើម្បីដោះស្រាយវិវាទពាណិជ្ជកម្ម | | | | | |
| ៦.១.២ អភិវឌ្ឍ និងបង្កើតសន្ទានកម្ម និងវិធីសាស្ត្រដោះស្រាយ វិវាទក្រៅប្រព័ន្ធតុលាការផ្សេងៗទៀត ដើម្បីដោះស្រាយ វិវាទ ពាណិជ្ជកម្ម និងផ្តល់ការបណ្តុះបណ្តាលចាំបាច់ | ក្រ.យុត្តិធម៌<br>ក្រ.ពាណិជ្ជ | | | | |

**អាទិភាពកំណត់:**

៧.១.១ ការអនុម័តច្បាប់អង្គការ និងច្បាប់ស្តីពីស្ថាប័នរដ្ឋបាល និងស្ថាប័នយុត្តិធម៌ (ការរៀបចំតុលាការ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្រុមប្រឹក្សាធម្មនុញ្ញ ក្រសួង និងស្ថាប័នប្រតិបត្តិដទៃទៀត នគរបាល ប្រព័ន្ធពន្ធនាគារ និងក្រុមប្រឹក្សាវិន័យ) ដែលធានាឱ្យមានការសម្របសម្រួលក្នុងការបំពេញអាណត្តិរបស់ស្ថាប័ននីមួយៗ

៧.២.១ ការអនុម័តក្រមនីតិវិធី រួមទាំងក្រមនីតិវិធីរដ្ឋបាល ច្បាប់ស្តីពីការិយាល័យការពារសិទ្ធិប្រជាពលរដ្ឋ (OMBUDSMAN) ច្បាប់ស្តីពីលទ្ធភាពទទួលបានព័ត៌មាន ដោយផ្តោតជាពិសេសទៅលើការធានានូវតម្លាភាពក្នុងស្ថាប័នវិស័យយុត្តិធម៌

៧.៣.១ ក្រមសីលធម៌សម្រាប់នគរបាល មន្ត្រីពន្ធនាគារ មន្ត្រីតុលាការ (ចៅក្រម ព្រះរាជអាជ្ញា មន្ត្រីយុត្តិធម៌) និងមន្ត្រីរាជការឯទៀត បន្ថែមទៅដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលមានដំណើរការល្អ ក្រុមប្រឹក្សាសេវាយុត្តិធម៌ ក្រុមប្រឹក្សាវិន័យសម្រាប់មន្ត្រីនគរបាល ក្រុមប្រឹក្សាវិន័យសម្រាប់មន្ត្រីរាជការ ដើម្បីធានាឱ្យការអនុវត្តមានប្រសិទ្ធភាព

៧.៣.២ បទប្បញ្ញត្តិច្បាប់និងសេចក្តីណែនាំ អំពីទំនាស់ផលប្រយោជន៍

៧.៣.៣ បង្កើតបទដ្ឋានអប្បបរមាសម្រាប់ការទទួលបានសញ្ញាបត្រផ្នែកនីតិសាស្ត្រ ឬរដ្ឋបាលសាធារណៈ

៧.៣.៤ សាលាសម្រាប់ចៅក្រម មន្ត្រីតុលាការ នគរបាល ប្រព័ន្ធពន្ធនាគារ និងសម្រាប់ការអប់រំមូលដ្ឋានដល់មន្ត្រីរាជការ រួមទាំងកម្មវិធីបណ្តុះបណ្តាលបន្ត

៧.៣.៥ វិធានការប្រឆាំងអំពើពុករលួយ រួមទាំងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ

៧.៣.៦ អត្ថិភាពនៃមុខងាររបស់ការិយាល័យការពារសិទ្ធិប្រជាពលរដ្ឋ (OMBUDSMAN)

៧.៨.១ បទប្បញ្ញត្តិស្តីពីការរៀបចំបង្កើតរបាយការណ៍ប្រចាំឆ្នាំ សម្រាប់សេវាកម្មនៅក្នុងវិស័យយុត្តិធម៌

| **ទិសដៅយុទ្ធសាស្ត្រ:** ពង្រឹងស្ថាប័នវិស័យយុត្តិធម៌ ដើម្បីបំពេញអាណត្តិរបស់ស្ថាប័នទាំងនោះ | | | **លទ្ធផលរំពឹងទុក :** សមត្ថភាព និងមធ្យោបាយត្រូវបានផ្តល់នៅក្នុងវិស័យផែនការកម្ម និងធ្វើថវិកាការត្រួតពិនិត្យតាមដាន និងការធ្វើរបាយការណ៍ ដើម្បីធ្វើឱ្យការអនុវត្តន៍ មានការទទួលខុសត្រូវ មានប្រសិទ្ធភាព និងគ្រប់គ្រាន់ | | |
|---|---|---|---|---|---|
| **សកម្មភាពជាអាទិភាព** | **ស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ** | **ស្ថាប័នដទៃទៀតដែលកំពុងមានការពាក់ព័ន្ធ** | **រយៈពេល** | **សកម្មភាពដែលត្រូវធ្វើ** | **សេចក្តីសង្កេតបន្ថែម** |
| ៧.១ បង្កើតក្របខ័ណ្ឌច្បាប់មួយដែលកំណត់ស្ថាប័ន និងរចនាសម្ព័ន្ធវិស័យយុត្តិធម៌ និងអាណត្តិជាក់លាក់ ព្រមទាំងការទទួលខុសត្រូវរបស់ស្ថាប័ននីមួយៗ ចៀសវាងដោយប្រុងប្រយ័ត្ននូវការងារជាន់គ្នា ដែលត្រូវអនុម័ត និងដែលត្រូវសម្របសម្រួល។ អាណត្តិ និងរចនាសម្ព័ន្ធ ត្រូវគោរពទាំងស្រុងតាមតម្លៃទាំងឡាយនៃវិស័យយុត្តិធម៌ ។ | | | | | |

| | | | | | |
|---|---|---|---|---|---|
| ៧.១.១ ការអនុម័តច្បាប់អង្គការ និងច្បាប់ស្តីពីស្ថាប័នរដ្ឋបាល និងស្ថាប័នយុត្តិធម៌ (ការរៀបចំតុលាការ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្រុមប្រឹក្សាធម្មនុញ្ញ ក្រសួង និងស្ថាប័នប្រតិបត្តិដ៏ទៃទៀតនគរបាល ប្រព័ន្ធពន្ធនាគារ និងក្រុមប្រឹក្សាវិន័យ) ដែលធានាឱ្យមានការសម្របសម្រួលក្នុងការបំពេញអាណត្តិរបស់ស្ថាប័ននីមួយៗ | ទី.គ.មន្ត្រី<br>ក្រ.យុត្តិធម៌<br>ក្រ.មហាផ្ទៃ<br>ឧត្តម.ចៅក្រម | | | | |
| ៧.២ ផ្តល់ក្របខ័ណ្ឌច្បាប់ដើម្បីធានាឱ្យនីតិវិធី សេចក្តីសម្រេច និងយន្តការប្តឹងឧទ្ធរណ៍នៃស្ថាប័នវិស័យយុត្តិធម៌ មានការផ្សព្វផ្សាយជាសាធារណៈ និងមានតម្លាភាព។ តទៅមុខទៀត ស្ថាប័នត្រួតពិនិត្យឯករាជ្យមួយត្រូវបង្កើតឡើងដោយច្បាប់ និងមានអាណត្តិ និងធនធានគ្រប់គ្រាន់សម្រាប់ដំណើរការ | | | | | |
| ៧.២.១ ការអនុម័តក្រមនីតិវិធី រួមទាំងក្រមនីតិវិធីរដ្ឋបាល ច្បាប់ស្តីពីការិយាល័យការពារសិទ្ធិប្រជាពលរដ្ឋ (OMBUDSMAN) ច្បាប់ស្តីពីលទ្ធភាពទទួលបានព័ត៌មាន ដោយផ្តោតជាពិសេសទៅលើការធានានូវតម្លាភាពក្នុងស្ថាប័នវិស័យយុត្តិធម៌ | ទី.គ.មន្ត្រី<br>ក្រ.យុត្តិធម៌<br>ក្រ.ទំនាក់ទំនង | | | | |
| ៧.៣ ធានាការអនុវត្តច្បាប់ លិខិតបទដ្ឋាន និងសេចក្តីសម្រេចរបស់តុលាការ ដោយស្ថាប័នវិស័យយុត្តិធម៌ទាំងអស់ ស្របទៅតាមអាណត្តិនិងភារកិច្ចរបស់វា ដោយផ្តល់នូវក្របខ័ណ្ឌច្បាប់ និងស្ថាប័ន ដែលបំពេញបន្ថែមដោយធនធានចាំបាច់ និងការបណ្តុះបណ្តាល។ តទៅមុខទៀត ត្រូវបង្កើតយន្តការដាក់ទណ្ឌកម្ម ចំពោះការខ្វះខាតក្នុងការអនុវត្ត រួមទាំងការដាក់ទណ្ឌកម្ម ចំពោះការរំលោភបំពានក្រមសីលធម៌ ឬវិធានស្តីពីទំនាស់ផលប្រយោជន៍ | | | | | |
| ៧.៣.១ ក្រមសីលធម៌សម្រាប់នគរបាល មន្ត្រីពន្ធនាគារ មន្ត្រីតុលាការ (ចៅក្រម ព្រះរាជអាជ្ញា មន្ត្រីយុត្តិធម៌) និងមន្ត្រីរាជការឯទៀត បន្ថែមទៅដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលមានដំណើរការល្អ ក្រុមប្រឹក្សាសេវាយុត្តិធម៌ ក្រុមប្រឹក្សាវិន័យសម្រាប់មន្ត្រីនគរបាល ក្រុមប្រឹក្សាវិន័យសម្រាប់មន្ត្រីរាជការ ដើម្បីធានាឱ្យការអនុវត្តមានប្រសិទ្ធភាព | ក្រ.មហាផ្ទៃ<br>ក្រ.យុត្តិធម៌<br>ឧត្តម.ចៅក្រម<br>ទី.គ.មន្ត្រី | | | | |
| ៧.៣.២ បទប្បញ្ញត្តិច្បាប់ និងសេចក្តីណែនាំ អំពីទំនាស់ផលប្រយោជន៍ | ទី.គ.មន្ត្រី | | | | |

| | | | | | |
|---|---|---|---|---|---|
| ៧.៣.៣ បង្កើតបទដ្ឋានអប្បបរមាសម្រាប់ ការទទួលបានសញ្ញា - បត្រផ្នែកនីតិសាស្ត្រ ឬរដ្ឋបាលសាធារណៈ | ក្រ.អប់រំ<br>ក្រ.យុត្តិធម៌<br>ទី.គ.មន្ត្រី | | | | |
| ៧.៣.៤ សាលាសម្រាប់ចៅក្រម មន្ត្រីតុលាការ នគរបាល ប្រព័ន្ធពន្ធនាគារ និងសម្រាប់ការអប់រំមូលដ្ឋានដល់មន្ត្រីរាជការ រួមទាំងកម្មវិធីបណ្តុះបណ្តាលបន្ត | ទី.គ.មន្ត្រី<br>ក្រ.មហាផ្ទៃ<br>ក្រ.យុត្តិធម៌ | | | | |
| ៧.៣.៥ វិធានការប្រឆាំងអំពើពុករលួយ រួមទាំងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ | ក្រ.ទំនាក់ទំនង | | | | |
| ៧.៣.៦ អត្ថិភាពនៃមុខងាររបស់ការិយាល័យការពារសិទ្ធិប្រជាពលរដ្ឋ **(OMBUDSMAN)** | ទី.គ.មន្ត្រី<br>ក្រ.ទំនាក់ទំនង | | | | |
| ៧.៨ ផ្តល់ក្របខ័ណ្ឌច្បាប់ អភិវឌ្ឍន៍ និងថែរក្សាប្រព័ន្ធគ្រប់គ្រងការអនុវត្ត ដែលជារៀងរាល់ឆ្នាំ ស្ថាប័នត្រូវត្រួតពិនិត្យការអនុវត្តរបស់ខ្លួន ហើយធ្វើបច្ចុប្បន្នភាព ផែនការយុទ្ធសាស្ត្របីឆ្នាំរបស់ខ្លួន និងដាក់ចេញនូវផែនការកែលំអសេវាកម្មប្រចាំឆ្នាំ | | | | | |
| ៧.៨.១ បទប្បញ្ញត្តិស្តីពីការរៀបចំបង្កើតរបាយការណ៍ប្រចាំឆ្នាំសម្រាប់សេវាកម្មនៅក្នុងវិស័យយុត្តិធម៌ | ក្រ.យុត្តិធម៌ | | | | |

# ដំណើរការនៅពេលខាងមុខ

- ស្ថាប័ននៃវិស័យច្បាប់ និងតុលាការ មានភារកិច្ចអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ ចំណែកឯអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ជាអ្នកសម្របសម្រួលការអនុវត្តយុទ្ធសាស្ត្រនេះ ។ អង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ មានអង្គភាពគ្រប់គ្រងគម្រោងជាជំនួយការ ហើយក្រុមគម្រោងនៃអង្គភាពគ្រប់គ្រងជាអ្នកសម្របសម្រួលទិសដៅជាយុទ្ធសាស្ត្រនីមួយៗ ។ អង្គភាពគ្រប់គ្រងគម្រោងកំពុងតែទទួលនូវការបណ្តុះបណ្តាលកសាងសមត្ថភាពរបស់ខ្លួន ដើម្បីអភិវឌ្ឍយុទ្ធសាស្ត្រ និងសកម្មភាពពាក់ព័ន្ធ ហើយអាចទទួលបាននូវជំនាញឯកទេសបើចាំបាច់ ។
- បន្ទាប់ពីកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការនេះ ត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រី បញ្ជីគម្រោងមួយ (Project Catalogue) នឹងត្រូវរៀបចំឡើង ដោយក្រុមគម្រោងអន្តរស្ថាប័នដែលមានការសម្របសម្រួលដោយអង្គភាពគ្រប់គ្រងគម្រោង ។ គម្រោង ឬសកម្មភាពនីមួយៗអាចអនុវត្តដោយស្ថាប័នជំនាញណាមួយនៃវិស័យយុត្តិធម៌ ឬក៏ជាចំណែកមួយនៃចង្កោមសកម្មភាពដែលទាមទារនូវការប្រឹងប្រែងស៊ីសង្វាក់គ្នាក្នុងវិស័យនេះ ។ ស្ថាប័ន ឬបុគ្គលផ្សេងទៀត អាចជួយជាជំនាញក្នុងករណីចាំបាច់ ។ អ្នកសម្របសម្រួលនៃអង្គភាពគ្រប់គ្រងគម្រោង គួរតែជាសមាជិកនៃក្រុមគម្រោងទាំងអស់នោះ ហើយតំណាងរបស់អង្គភាពគ្រប់គ្រងគម្រោង គួរតែជាលេខាធិការនៃក្រុមគម្រោងនោះដែរ ។ ប្រធានក្រុមគម្រោង គួរតែជាមន្ត្រីជាន់ខ្ពស់នៃស្ថាប័ននាំមុខ ដែលអនុវត្តទិសដៅជាយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ។ ចំណែកឯសមាជិកនៃក្រុមគម្រោង គឺជាមន្ត្រីដែលមកពីស្ថាប័នតំណាងនៅក្នុងក្រុមគម្រោង ។ អង្គភាពគ្រប់គ្រងគម្រោង ជាអ្នកសម្របសម្រួល ពិនិត្យតាមដាន និងធ្វើរបាយការណ៍ ពីគម្រោងនីមួយៗ ក៏ដូចជាពីកម្មវិធីកំណែទម្រង់ច្បាប់ និងតុលាការទាំងមូល ។ អង្គភាពគ្រប់គ្រងគម្រោង កំពុងតែដំណើរការអភិវឌ្ឍនូវទិន្នន័យ ដើម្បីជួយដល់ការសម្របសម្រួលគម្រោងទាំងនោះហើយ ។

បន្ថែមលើនេះ អនុលោមតាមអនុក្រឹត្យលេខ ១២៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០២ អង្គភាពគ្រប់គ្រងគម្រោងមានភារកិច្ចគ្រប់គ្រងកិច្ចការហិរញ្ញវត្ថុរបស់គម្រោងកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ( មាត្រា ២) ។ កិច្ចការនេះអាចតម្រូវឱ្យមាន ការតែងតាំងមន្ត្រីលទ្ធកម្មពីខាងក្រៅ ដើម្បីគ្រប់គ្រងជំនួយ និងឱ្យមានការកសាងសមត្ថភាពផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ នៅក្នុងអង្គភាពគ្រប់គ្រងគម្រោង ។

- អង្គភាពសម្របសម្រួលអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នឹងរៀបចំបង្កើតយន្តការសម្របសម្រួលជាផ្លូវការមួយ ជាមួយសហគមន៍អ្នកផ្តល់ជំនួយ ដើម្បីផ្តួចផ្តើមកៀងគរដៃគូ និងមូលនិធិចាំបាច់សម្រាប់ការអនុវត្តគម្រោង ។ គោលបំណងគឺ អភិវឌ្ឍយន្តការផ្លាស់ប្តូរព័ត៌មាន រវាងក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ អង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ និងអង្គភាពគ្រប់គ្រងគម្រោងកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងសហគមន៍អ្នកផ្តល់ជំនួយ ដើម្បីផ្តល់លទ្ធភាពឱ្យអ្នកផ្តល់ជំនួយពាក់ព័ន្ធ រៀបចំធ្វើផែនការសកម្មភាពរបស់ខ្លួនជុំវិញអាទិភាពនៃកំណែទម្រង់ និងអាចផ្តល់ជំនួយស្របតាមវិស័យជាក់លាក់នៃកម្មវិធីកំណែទម្រង់ ។ យន្តការនេះក៏ជួយមិនឱ្យការខំប្រឹងប្រែង

របស់អ្នកផ្តល់ជំនួយទាំងអស់នោះមានការជាន់គ្នាដែរ ។ មានការរំពឹងទុកថាក្រុមសម្របសម្រួល ត្រូវជួបប្រជុំពិភាក្សាគ្នារៀងរាល់ត្រីមាស ផ្អែកលើរបាយការណ៍ប្រចាំត្រីមាស ដែលរៀបចំឡើងដោយអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ និងអង្គភាពគ្រប់គ្រងគម្រោង ។

- កម្មវិធីសកម្មភាពមានកំណត់នូវរយៈពេលសម្រាប់អាទិភាពទាំងឡាយនៃកំណែទម្រង់ច្បាប់ និងតុលាការ ។ ជាការពិតណាស់ដែលថា កំណែទម្រង់ គឺជាដំណើរការមួយដែលត្រូវការពេលវេលាដ៏វែងឆ្ងាយ ប៉ុន្តែកម្មវិធីសកម្មភាពនេះមានកំណត់យ៉ាងច្បាស់លាស់នូវសកម្មភាពដែលនាំទៅរកការកែទម្រង់ទូលំទូលាយថែមទៀតនោះហើយ ។

រាជរដ្ឋាភិបាលយល់ច្បាស់ណាស់ថា ជោគជ័យនៃកំណែទម្រង់មិនអាស្រ័យទាំងស្រុង តែទៅលើមូលនិធិពីខាងក្រៅ ឬតែទៅលើការរៀបចំគម្រោងល្អៗប៉ុណ្ណោះនោះទេ ។ កម្មវិធីសកម្មភាពនេះ ទាមទារនូវការប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់ក្នុងការធ្វើកំណែទម្រង់ ទាំងខាងនីតិប្រតិបត្តិ នីតិបញ្ញត្តិ និងតុលាការ ។ រាជរដ្ឋាភិបាលបានប្តេជ្ញាហើយប្តេជ្ញាទៀត ចំពោះការបង្កើនល្បឿននៃកំណែទម្រង់នេះ ហើយកំពុងតែទទួលបាននូវការឧបត្ថម្ភគាំទ្រ និងគៀងគរការឧបត្ថម្ភគាំទ្របន្ថែមទៀតពីអ្នកផ្តល់ជំនួយសំខាន់ៗ ដើម្បីគ្រប់គ្រង និងសម្របសម្រួលការអនុវត្តដំណើរការកំណែទម្រង់ច្បាប់ និងតុលាការនេះឱ្យមានប្រសិទ្ធភាព ។